ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅ

ថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)

# របាយការណ៍

# ស្តីពី

# លទ្ធផលនៃការសិក្សាទិន្នន័យដើមគ្រាលើគុណភាព ការផ្តល់សេវាវិស័យអប់រំដែលបានផ្ទេរ ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ

រៀបចំដោយក្រុមការងារអន្តរក្រសួង
ខែកក្កដា ឆ្នាំ២០២៤
គាំទ្រដោយលេខាធិការដ្ឋាន គ.ជ.អ.ប. និងកម្មវិធី ISD/GIZ

# មាតិកានុក្រម


**អារម្ភកថា**........................................ ១

**សេចក្តីសង្ខេប**........................................ ៣

**១. សេចក្តីផ្តើម**........................................១១

**២. គោលបំណង**........................................១៣

**៣. វិសាលភាពគ្របដណ្តប់នៃការសិក្សា**........................................១៣

**៤. យន្តការដឹកនាំសម្របសម្រួលការសិក្សាទិន្នន័យដើមគ្រា**........................................១៤

**៥. វិធីសាស្ត្រនៃការវិភាគទិន្នន័យដើមគ្រា**........................................ ១៤

៥.១. ការសិក្សាលើបទដ្ឋានគតិយុត្ត........................................ ១៤

៥.២. ការសិក្សាលើទិន្នន័យ........................................ ១៥

៥.៣. ក្រុមគោលដៅ........................................ ១៦

**៦. របកគំហើញនៃការសិក្សាទិន្នន័យដើមគ្រា**........................................ ១៧

៦.១. ស្ថិតិ និងសូចនាករស្នូល (EMIS ២០២២-២០២៣)........................................ ១៧

៦.១.១. ស្ថិតិ និងសូចនាករស្នូលសម្រាប់អនុវិស័យការអប់រំកុមារតូច........................................ ១៧

៦.១.២. ស្ថិតិ និងសូចនាករសាលាមត្តេយ្យដែលបានជាប់ក្នុងកម្មវិធីប្រឡងប្រណាំងសាលាមត្តេយ្យស្តង់ដារគំរូ........................................ ១៩

៦.១.៣. ស្ថិតិ និងសូចនាករស្នូលសម្រាប់អនុវិស័យការអប់រំបឋមសិក្សា........................................ ១៩

៦.១.៤. ស្ថិតិ និងសូចនាករសាលាបឋមសិក្សាដែលបានជាប់ក្នុងកម្មវិធីប្រឡងប្រណាំង........ ២១

៦.១.៥. ស្ថិតិ និងសូចនាករស្នូលសម្រាប់អនុវិស័យការអប់រំក្រៅប្រព័ន្ធ........................................ ២២

៦.២. ទិន្នន័យដើមគ្រានៃការរកឃើញតាមរយៈការស្ទង់មតិ........................................ ២៣

៦.២.១. ក្រុមគោលដៅទី១ ៖ ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ........................................ ២៣

៦.២.២. ក្រុមអ្នកផ្តល់ព័ត៌មានជាអភិបាល ឬអភិបាលរងទទួលបន្ទុកការងារអប់រំក្រុង ស្រុក ខណ្ឌ........................................ ៣០

៦.២.៣. ក្រុមអ្នកផ្តល់ព័ត៌មានជាប្រធាន និងមន្ត្រីទទួលបន្ទុកផ្នែកពាក់ព័ន្ធ នៃការិយាល័យ អប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ..... ៤២
៦.២.៤. ក្រុមអ្នកផ្តល់ព័ត៌មានជាថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និង ប្រធានការិយាល័យពាក់ព័ន្ធ ..... ៥០
៦.២.៥. ក្រុមអ្នកផ្តល់ព័ត៌មានជានាយក/នាយិកាសាលាមត្តេយ្យសិក្សា ..... ៥៣
៦.២.៦. ក្រុមអ្នកផ្តល់ព័ត៌មានជានាយក/នាយិកាសាលាបឋមសិក្សា ..... ៥៩
៦.២.៧. ក្រុមអ្នកផ្តល់ព័ត៌មានជាប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍ ..... ៦៥
៦.២.៨. ក្រុមអ្នកផ្តល់ព័ត៌មានជាគ្រូបង្រៀន ..... ៦៧
៦.២.៩. ក្រុមអ្នកផ្តល់ព័ត៌មានមកពីមេឃុំ ចៅសង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ ..... ៧១
៦.២.១០. អ្នកផ្តល់ព័ត៌មានជាប្រធានគណៈកម្មការគ្រប់គ្រងសាលារៀន ..... ៧៧
**៧. សេចក្តីសន្និដ្ឋាននៃរបកគំហើញ** ..... ៧៩
៧.១. ការអប់រំកុមារតូច ..... ៨០
៧.២. ការអប់រំបឋមសិក្សា ..... ៨២
៧.៣. ការអប់រំក្រៅប្រព័ន្ធ ..... ៨៣
**ឯកសារយោង**
**តារាងឧបសម្ព័ន្ធ**

# អារម្ភកថា

របាយការណ៍ស្តីពីលទ្ធផលនៃការសិក្សាទិន្នន័យដើមគ្រាលើគុណភាពការផ្តល់សេវាវិស័យអប់រំ ដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមរយៈអនុក្រឹត្យលេខ២១៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ គឺជាសូចនាករដើមគ្រា និងជាឧបករណ៍សម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃលទ្ធផល និងសមិទ្ធផលនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ។

គោលបំណងនៃការសិក្សារៀបចំទិន្នន័យដើមគ្រានៃមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ គឺដើម្បីវាយតម្លៃលើស្ថានភាពនៃគុណភាពសេវាអប់រំនៅមុនពេលដែលរដ្ឋបាលក្រុង ស្រុក ខណ្ឌបានចាប់ផ្តើមអនុវត្តមុខងារក្នុងវិស័យអប់រំ តាមរយៈអនុក្រឹត្យលេខ២១៣ និងដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការវាយតម្លៃវឌ្ឍនភាពនៃគុណភាពសេវាអប់រំនាពេលអនាគត និងជាមូលដ្ឋានសម្រាប់លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងអប់រំ យុវជន និងកីឡាក្នុងការបន្តគាំទ្រ និងពង្រឹងសមត្ថភាពបន្ថែមទៀត សំដៅលើកកម្ពស់ការអនុវត្តមុខងារវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

របាយការណ៍ស្តីពីលទ្ធផលនៃការសិក្សាទិន្នន័យដើមគ្រាលើគុណភាពការផ្តល់សេវាវិស័យអប់រំ ដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌនេះ ត្រូវបានរៀបចំឡើងដោយផ្អែកទៅលើកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ (កជទី២) ផែនការអនុវត្តន៍រយៈពេល ៥ឆ្នាំលើកទី១ នៃកជទី២ ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៥ និងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធទៅនឹងការផ្ទេរមុខងារវិស័យអប់រំដែលមានជាធរមាន និងផ្អែកលើលទ្ធផលនៃការចុះសិក្សាស្រាវជ្រាវយ៉ាងលម្អិតជាមួយក្រុមប្រឹក្សា គណៈអភិបាល ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ នាយក/នាយិកាសាលាមត្តេយ្យសិក្សា សាលាបឋមសិក្សារដ្ឋ លោកគ្រូ អ្នកគ្រូ ប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍ មេឃុំ/ចៅសង្កាត់ តំណាងមាតាបិតាសិស្ស គណៈកម្មការគ្រប់គ្រងសាលារៀន តំណាងមន្ទីរអប់រំ យុវជន និងកីឡា និងមន្ត្រីទទួលបន្ទុកអនុវិស័យទាំងបី ដែលមានចំនួនសរុបប្រមាណជិត ៣,០០០នាក់។

ទន្ទឹមនឹងនេះ ដើម្បីធានានូវសង្គតិភាព និងសុក្រឹតភាព លទ្ធផលនៃការសិក្សាទិន្នន័យដើមគ្រាក្នុងវិស័យអប់រំនេះ ត្រូវបានដាក់ជូនកិច្ចពិភាក្សា និងការពិគ្រោះយោបល់យ៉ាងទូលំទូលាយទាំងក្នុងកម្រិតបច្ចេកទេស និងកម្រិតថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា និងលេខាធិការដ្ឋាន គ.ជ.អ.ប. ដោយមានការគាំទ្របច្ចេកទេសពីកម្មវិធី "ធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅប្រទេសកម្ពុជា" (ISD-GIZ) ព្រមទាំងទទួលបានការពិនិត្យ ពិភាក្សា និងឯកភាពក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកទី២ របស់ក្រុមការងារបច្ចេកទេសអន្តរក្រសួងនាថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៥។ របាយការណ៍ស្តីពីលទ្ធផលនៃការសិក្សាទិន្នន័យដើមគ្រាលើគុណភាពការផ្តល់សេវាវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌនេះ នឹងក្លាយជាមូលដ្ឋានសម្រាប់ការយល់ដឹងអំពីស្ថានភាពនៃមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡា

មុនពេលពង្រីកការប្រគល់ និងការផ្ទេរប្រតិភូកម្មមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសម្រាប់ការវាយតម្លៃវឌ្ឍនភាពនៃគុណភាពសេវាអប់រំនាពេលអនាគត ក្នុងគោលបំណង ដើម្បីផ្តល់ការគាំទ្រ និងពង្រឹងសមត្ថភាពបន្ថែមទៀត សំដៅលើកកម្ពស់ការអនុវត្តមុខងារវិស័យអប់រំដែល បានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌឱ្យកាន់តែមានប្រសិទ្ធភាព និងគុណភាពខ្ពស់។

ក្នុងនាមរាជរដ្ឋាភិបាល ក្នុងនាម គ.ជ.អ.ប. និងក្រសួងអប់រំ យុវជន និងកីឡា យើងខ្ញុំសូមថ្លែង អំណរគុណ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងអប់រំ យុវជន និងកីឡា លេខាធិការដ្ឋាន គ.ជ.អ.ប. រដ្ឋបាលរាជធានី ខេត្ត មន្ទីរអប់រំ យុវជន និងកីឡា រដ្ឋបាលក្រុង ស្រុក ខណ្ឌ ការិយាល័យអប់រំ យុវជន និងកីឡា ថ្នាក់ដឹកនាំសាលារៀន លោកគ្រូ អ្នកគ្រូ មេឃុំ ចៅសង្កាត់ មាតា បិតាសិស្ស គណៈកម្មការគ្រប់គ្រងសាលារៀន និងកម្មវិធី ISD-GIZ ដែលបានចូលរួម និងផ្តល់ការគាំទ្រដល់ កិច្ចដំណើរការសិក្សាទិន្នន័យដើមគ្រានេះឱ្យប្រព្រឹត្តទៅដោយរលូន ព្រមទាំងបានផ្តល់ជាតុចូលដ៏មានសារៈ សំខាន់ ដើម្បីជានាឱ្យរបកគំហើញ និងការវិភាគនៃការសិក្សាទិន្នន័យដើមគ្រានេះ កាន់តែមានភាពសុក្រឹត និងមានលក្ខណៈគ្រប់ជ្រុងជ្រោយ រហូតដល់បញ្ចប់ទៅលើរបាយការណ៍នៃការសិក្សាទិន្នន័យដើមគ្រានេះ។

យើងខ្ញុំសង្ឃឹមជឿជាក់យ៉ាងមុតមាំថា ក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងសាធារណជន នឹងបន្តសហការ គាំទ្រ និងចូលរួមកាន់តែសកម្ម ថែមទៀតក្នុងកិច្ចដំណើរការអនុវត្តមុខងារវិស័យអប់រំ យុវជន និងកីឡា ដែលបានផ្ទេរទៅឱ្យរដ្ឋបាល ថ្នាក់ក្រោមជាតិ ស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ សំដៅជានាដល់ការលើកកម្ពស់ គុណភាពសេវាអប់រំ យុវជន និងកីឡាឱ្យទទួលបានជោគជ័យបន្ថែមទៀត។

*ថ្ងៃ..ចន្ទ.....៩រោច........ ខែ..បុស្ស.. ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩*

*រាជធានីភ្នំពេញ ថ្ងៃទី..១២.. ខែ..មករា..... ឆ្នាំ២០២៦*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.**

**អភិសន្តិបណ្ឌិត ស សុខា**

## សេចក្តីសង្ខេប

ការសិក្សាទិន្នន័យដើមគ្រានេះ ជាមូលដ្ឋានសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃលទ្ធផល និងសមិទ្ធផលរបស់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលនឹងបង្ហាញដល់រាជរដ្ឋាភិបាល និងប្រជាពលរដ្ឋថាការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការពិតជាដើរតួនាទីយ៉ាងសំខាន់ក្នុងការឈានទៅដល់គោលដៅនៃការអភិវឌ្ឍរបស់ប្រទេសកម្ពុជា។ ម្យ៉ាងទៀតការសិក្សាទិន្នន័យដើមគ្រានេះ គឺជាមូលដ្ឋានសំខាន់សម្រាប់ការវាយតម្លៃគុណភាពសេវាអប់រំនាពេលអនាគត និងរួមចំណែកដល់លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងអប់រំ យុវជន និងកីឡាបន្តគាំទ្រអនុវត្តការផ្ទេរមុខងារវិស័យអប់រំនៅតាមក្រុង ស្រុក ខណ្ឌឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

ការសិក្សាទិន្នន័យដើមគ្រាលើគុណភាពសេវាអប់រំនេះ បានរៀបចំដោយយោងលើភាពចាំបាច់ និងឯកភាពស្រុះស្រួលគ្នាជាគោលការណ៍រវាងលេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងអប់រំ យុវជន និងកីឡា ដែលបានណែនាំតម្រង់ទិស និងដាក់ចេញនូវឯកសារទស្សនទានស្តីពីការសិក្សាទិន្នន័យដើមគ្រាលើគុណភាពសេវាអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ លេខាធិការដ្ឋាន គ.ជ.អ.ប. បានសម្របសម្រួល បង្កើត និងដឹកនាំក្រុមការងារបច្ចេកទេសសម្រាប់ចុះសិក្សា និងប្រមូលទិន្នន័យដើមគ្រាដែលមានសមាសភាពមកពីតំណាងក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប. ដើម្បីចុះសិក្សាប្រមូលទិន្នន័យតាមដំណើរការ និងទទួលបានលទ្ធផលដូចមានសង្ខេបខាងក្រោម។

❖ **អំពីគោលបំណង និងកិច្ចដំណើរការនៃការសិក្សាទិន្នន័យដើមគ្រា**

គោលបំណងនៃការសិក្សាទិន្នន័យដើមគ្រាមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ គឺដើម្បីវាយតម្លៃលើវឌ្ឍនភាពគុណភាពសេវាអប់រំនៅមុនពេលដែលក្រុង ស្រុក ខណ្ឌបានចាប់ផ្តើមអនុវត្តមុខងារក្នុងវិស័យអប់រំតាមរយៈអនុក្រឹត្យលេខ២១៣។

សូចនាករដើមគ្រានេះ គឺជាឧបករណ៍សម្រាប់ពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តមុខងាររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌនាពេលអនាគត។ ការរៀបចំសូចនាករដើមគ្រាសម្រាប់វាយតម្លៃគុណភាពសេវាអប់រំកុមារតូច អប់រំបឋមសិក្សា និងអប់រំក្រៅប្រព័ន្ធ មានសមាសធាតុសំខាន់ៗបីដូចខាងក្រោម៖

- ការអភិវឌ្ឍរបស់ប្រព័ន្ធអប់រំទាំងបីអនុវិស័យ ឆ្នាំសិក្សា២០២២-២០២៣ (EMIS)
- ការដឹកនាំ និងការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសាលារៀន (Function and Mechanism) និង
- កំណត់សូចនាករផលសម្រេចសម្រាប់អនុវត្តយន្តការត្រួតពិនិត្យ និងវាយតម្លៃនៃការអនុវត្តផ្ទេរមុខងារដែលបានផ្ទេរ។

ការសិក្សាទិន្នន័យដើមគ្រានេះ គឺបានប្រើវិធីសាស្រ្តចម្រុះក្នុងការប្រមូលទិន្នន័យ ហើយវិធីសាស្រ្តសំខាន់ៗដែលបានអនុវត្តក្នុងកិច្ចដំណើរការសិក្សាទិន្នន័យដើមគ្រានេះ រួមមាន **វិធីសាស្រ្តប្រមូលទិន្នន័យបែបបរិមាណ** (Secondary data) ត្រូវបានប្រមូលទិន្នន័យពីសាលារៀន ជាពិសេសដកស្រង់ចេញពីប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ EMIS (ឆ្នាំសិក្សា២០២២-២០២៣) របស់ក្រសួងអប់រំ យុវជន និងកីឡា នៃអនុវិស័យ

ទាំងបី រួមទាំងបានសិក្សាបន្ថែមទៀតលើស្ថិតិ និងសូចនាករការអប់រំក្រៅប្រព័ន្ធ ឆ្នាំ២០២៣ នៃនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ **និងទិន្នន័យបែបគុណភាព** គឺក្រុមការងារប្រមូលទិន្នន័យដើមគ្រា បានប្រើប្រាស់កម្រងបញ្ជីសំណួរសម្រាប់ប្រមូលទិន្នន័យ ដើម្បីវាស់វែងអំពីស្ថានភាពគុណភាពសេវាអប់រំមុនផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ស្របតាមសូចនាករនីមួយៗដែលបានកំណត់។

ក្រុមការងារប្រមូលទិន្នន័យដើមគ្រាបានចុះនៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌចំនួន៣១ ក្នុងរាជធានីខេត្តគោលដៅចំនួន០៦ គឺក្នុងនោះមានរដ្ឋបាលក្រុង ស្រុកចំនួន០៤ ក្នុងខេត្តកំពត រដ្ឋបាលក្រុង ស្រុកចំនួន០៧ ក្នុងខេត្តបន្ទាយមានជ័យ រដ្ឋបាលក្រុង ស្រុកចំនួន០៦ ក្នុងខេត្តសៀមរាប រដ្ឋបាលក្រុង ស្រុកចំនួន០៤ ក្នុងខេត្តស្វាយរៀង រដ្ឋបាលក្រុង ស្រុកចំនួន០៤ ក្នុងខេត្តមណ្ឌលគិរី និងរដ្ឋបាលខណ្ឌចំនួន០៦ ក្នុងរាជធានីភ្នំពេញ។ ការចុះសិក្សាប្រមូលទិន្នន័យដើមគ្រានេះ ក្រុមការងារប្រមូលទិន្នន័យបានជួបសម្ភាសជាមួយក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អភិបាល ឬអភិបាលរងនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ នាយក/នាយិកាសាលាមត្តេយ្យសិក្សាដាច់ដោយឡែក នាយកសាលាបឋមសិក្សារដ្ឋ លោកគ្រូ អ្នកគ្រូ ប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍ លោកមេឃុំ ចៅសង្កាត់ តំណាងមាតាបិតាសិស្ស ប្រធានគណៈកម្មការគ្រប់គ្រងសាលារៀន និងតំណាងមន្ទីរអប់រំ យុវជន និងកីឡា និងមន្ត្រីទទួលបន្ទុកអនុវិស័យទាំងបី ដែលមានចំនួនសរុប**ប្រមាណជាង ២,៨០៥នាក់**។ ការជួបសម្ភាស និងការពិភាក្សាការងារជាមួយអ្នកពាក់ព័ន្ធខាងលើ ក្រុមការងារបច្ចេកទេសប្រមូលទិន្នន័យបានប្រើប្រាស់បញ្ជីសំណួរចំនួន ១០ទម្រង់ផ្សេងគ្នា (សម្រាប់ ១០ក្រុមគោលដៅ) ដែលបញ្ជីសំណួរនីមួយៗមានទម្រង់សម្រាប់ស្ទង់មតិជាលក្ខណៈបុគ្គល និងបញ្ជីសំណួរសម្រាប់ពិភាក្សាជាក្រុមដោយផ្តោតលើចំណុចសំខាន់ៗ ដូចខាងក្រោម៖

- សិក្សាពីទស្សនៈលើការធ្វើផែនការ និងថវិកា ការអនុវត្ត និងការយកចិត្តទុកដាក់ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ
- សិក្សាពីទស្សនៈលើការអនុវត្ត និងស្ថានភាពធនធានជាក់ស្តែង
- សិក្សាពីទស្សនៈលើខ្សែគណនេយ្យភាព ការទំនាក់ទំនង និងយន្តការគាំទ្រដល់ការអនុវត្តនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- សិក្សាពីសូចនាករ និងស្តង់ដាសាលារៀន
- សិក្សាពីទស្សនៈចំពោះការអនុវត្ត និងការគាំទ្ររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និង
- សិក្សាពីការអនុវត្ត និងការគាំទ្ររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ព័ត៌មាន និងទិន្នន័យនានាដែលប្រមូលបានពីការស្ទង់មតិនៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌគោលដៅនីមួយៗត្រូវបានបូកសរុបជាសេចក្តីព្រាងរបាយការណ៍បឋម និងបានដាក់ឱ្យពិនិត្យ ពិភាក្សាក្នុងកិច្ចប្រជុំពិគ្រោះយោបល់ក្នុងកម្រិតក្រុមការងារបច្ចេកទេសអន្តរក្រសួង ដែលបានរៀបចំឡើងនាថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៥ ក្រោមការដឹកនាំសម្របសម្រួលដោយ **លោកជំទាវ ឃុន រចនា** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា និង**ឯកឧត្តម ជ័យ សម្បត្តិផល្លា** ប្រធានអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយនៃ

លេខាធិការដ្ឋាន គ.ជ.អ.ប.។ ផ្អែកតាមមតិយោបល់ និងធាតុចូលនានាដែលទទួលបានពីកិច្ចប្រជុំពិគ្រោះយោបល់ ក្រុមការងារសិក្សាទិន្នន័យដើមគ្រាបានរៀបចំបញ្ចប់សេចក្តីព្រាងរបាយការណ៍លម្អិតស្តីពីលទ្ធផលនៃការសិក្សាទិន្នន័យដើមគ្រាលើគុណភាពវិស័យអប់រំ យុវជន និងកីឡាដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

❖ **អំពីរបកគំហើញ**

ផ្អែកតាមរបកគំហើញពីការសិក្សាទិន្នន័យដើមគ្រាលើគុណភាពមុខងារវិស័យអប់រំទាំងបីអនុវិស័យមុនផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្រុមការងារបច្ចេកទេសអន្តរក្រសួងសន្និដ្ឋានជារួមបានថា ស្ថានភាពមុនផ្ទេរនៅក្នុងការអនុវត្តមុខងារវិស័យអប់រំទាំងបីអនុវិស័យនៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងការគ្រប់គ្រងការចាត់ចែង និងការអនុវត្តមុខងារអប់រំទាំងនោះពុំសូវមានបញ្ហាណាមួយគួរឱ្យកត់សម្គាល់នោះឡើយ។

លទ្ធផលជារួមបានមើលឃើញថា ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌមានការយល់ដឹងអំពីគោលនយោបាយ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងកម្មវិធីកំណែទម្រង់សាលារៀនត្រឹមកម្រិតមធ្យមនៅឡើយ ប៉ុន្តែក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ បានយកចិត្តទុកយ៉ាងខ្លាំងក្នុងការអភិវឌ្ឍលើវិស័យអប់រំក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបន្ទាប់ពីការផ្ទេរមុខងារវិស័យអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ទន្ទឹមនឹងនេះ ការយល់ដឹងអំពីស្វ័យភាពរបស់សាលារៀននៅមានកម្រិតទាប ហើយក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌយល់ឃើញថាការគាំទ្របច្ចេកទេសក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារនៅមានកម្រិត និងមានបញ្ហាប្រឈមជាច្រើនទៀតផងដែរ។

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវបានមើលឃើញថា មានការយល់ដឹងអំពីគោលនយោបាយ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងកម្មវិធីកំណែទម្រង់សាលារៀនត្រឹមកម្រិតមធ្យមនៅឡើយ ប៉ុន្តែអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ បានយកចិត្តទុកយ៉ាងខ្លាំងក្នុងការអភិវឌ្ឍលើវិស័យអប់រំ យុវជន និងកីឡាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបន្ទាប់ពីការផ្ទេរមុខងារទាំងនោះមកឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ចំពោះទំនាក់ទំនងការងារនានារវាងមន្ទីរអប់រំ យុវជន និងកីឡាជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌក្រោយសមាហរណកម្ម ក្រុមការងារមើលឃើញថា មានកិច្ចសហការល្អគួរឱ្យកត់សម្គាល់ ជាពិសេស ការងាររបាយការណ៍ ដោយឡែកចំពោះការងារពិនិត្យនីត្យានុកូលភាព ការធ្វើសេចក្តីសម្រេចចិត្តនានា ការងារគាំទ្របច្ចេកទេស ការងារអភិវឌ្ឍន៍សមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនៅមានកម្រិតនៅឡើយ ជាក់ស្តែង ៤០% លើកឡើងថាកម្រិតមធ្យម និង ៦០% កម្រិតបង្គួរ។

ទោះជាយ៉ាងនេះក្តី កម្រិតនៃការគ្រប់គ្រង ការចាត់ចែង និងយល់ដឹងពីកិច្ចការមួយចំនួនក្នុងវិស័យអប់រំ យុវជន និងកីឡា មុនសមាហរណកម្មទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបានមើលឃើញថា ជួបបញ្ហាប្រឈមជាគន្លឹះមួយចំនួនពាក់ព័ន្ធនឹងកម្រិតនៃសិទ្ធិអំណាច កិច្ចការរដ្ឋបាល និងការគ្រប់គ្រងធនធានរួមមានទាំងធនធានហិរញ្ញវត្ថុ និងធនធានមនុស្សដែលទាមទារឱ្យមានការពិនិត្យ និងកែសម្រួល រួមជាមួយនឹងការពង្រឹងយន្តការគាំទ្រ ការអភិវឌ្ឍសមត្ថភាព ការតាមដានត្រួតពិនិត្យដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

ក្នុងការដោះស្រាយបញ្ហាប្រឈមនានាឱ្យបានឆាប់រហ័ស ទាន់ពេលវេលា ដើម្បីធានាឱ្យការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌអាចអនុវត្តបានដោយរលូនប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ជាពិសេសធានាបាននូវគុណភាពអប់រំល្អប្រសើរជាលំដាប់។ ចំពោះលទ្ធផលរបកគំហើញជាក់លាក់មានបង្ហាញដូចខាងក្រោម៖

### ❖ អនុវិស័យការអប់រំកុមារតូច

អនុវិស័យការអប់រំកុមារតូចនៅកម្ពុជា សម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្នុងការពង្រីកលទ្ធភាពទទួលបាន និងលើកកម្ពស់គុណភាពនៃការរៀនសូត្រដំបូង។ សមិទ្ធផលសំខាន់ៗរួមមានការកើនឡើងនៃគ្រឹះស្ថានអប់រំកុមារភាព ការធ្វើឱ្យប្រសើរឡើងនូវអត្រាចុះឈ្មោះចូលរៀន កម្មវិធីសិក្សាថ្មីៗ និងកម្មវិធីបណ្តុះបណ្តាលគ្រូឱ្យប្រសើរឡើង។ ក្នុងនោះដែរកម្មវិធីគាំទ្រ និងភាពជាដៃគូក៏បានរួមចំណែកដល់លទ្ធផលវិជ្ជមានទាំងនេះផងដែរ។

- ផ្អែកលើសូចនាករស្នូលនៃអនុវិស័យការអប់រំកុមារតូច (EMIS 2022-2023) ឃើញថាមានការកើនឡើងគួរឱ្យកត់សម្គាល់នៃចំនួនសាលាមត្តេយ្យសិក្សាគ្រប់ប្រភេទ។ ការកើនឡើងនេះមានគោលបំណងផ្តល់លទ្ធភាពកាន់តែទូលំទូលាយសម្រាប់ឱកាសសិក្សាដំបូងសម្រាប់កុមារនៅទូទាំងប្រទេសកម្ពុជា។ កិច្ចខិតខំប្រឹងប្រែងនេះ ត្រូវបានធ្វើឡើងដើម្បីបង្កើនលទ្ធភាពទទួលបានការអប់រំកុមារតូច ដែលបានបង្កើនលទ្ធផលអត្រាចុះឈ្មោះចូលរៀន
- កម្រិតនៃការយល់ដឹងរបស់ក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក ខណ្ឌលើគោលនយោបាយផែនការយុទ្ធសាស្ត្រគ្រប់គ្រងកុមារតូចនៅមានកម្រិតនៅឡើយ ជាក់ស្តែង (៣៣%) យល់ដឹងតិចតួច និង (៤៥%) យល់ដឹងមធ្យម លើគោលនយោបាយ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ យល់ដឹងអំពីគោលនយោបាយកំណែទម្រង់សាលារៀនរបស់ក្រសួងអប់រំ យុវជន និងកីឡា សាលាមត្តេយ្យសិក្សា និងយល់ដឹងតិចតួច (២៥%) អំពីស្វ័យភាពកិច្ចការនានារបស់សាលាមត្តេយ្យសិក្សា
- រដ្ឋបាលក្រុង ស្រុក ខណ្ឌបានផ្តោតការយកចិត្តទុកដាក់ខ្ពស់ក្នុងការអភិវឌ្ឍលើវិស័យអប់រំក្នុងមូលដ្ឋានរបស់ខ្លួន ជាពិសេសផ្តោតលើអនុវិស័យអប់រំទាំងបី ការអប់រំកុមារតូច បឋមសិក្សា និងអប់រំក្រៅប្រព័ន្ធ។ ជាក់ស្តែង (៧៩.៤%) លើកឡើងថា រដ្ឋបាលក្រុង ស្រុក ខណ្ឌ បានដាក់បញ្ចូលផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំឆ្នាំស្តីពីការអប់រំកុមារតូចចូលក្នុងផែនការអភិវឌ្ឍន៍០៥ឆ្នាំ ឬកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ នៅក្នុងឆ្នាំ២០២៣ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌបានអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំឆ្នាំស្តីពីការអប់រំកុមារតូចមានចំនួន ៣៤% បានតិចតួច ៤១% មធ្យម ២១% បានបង្គួរ និង ៣% បានពេញលេញ
- ការដឹកនាំ ចាត់ចែង គ្រប់គ្រង និងការគាំទ្ររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌចំពោះមុខងាររងការអប់រំកុមារតូច៖ រដ្ឋបាលក្រុង ស្រុក ខណ្ឌបានគាំទ្រចន្លោះពី (៧៧ ទៅដល់៨៧%) លើកិច្ចការមួយចំនួនដូចជា ការរៀបចំផែនការសាលារៀន ការពិនិត្យតាមដាន និងវាយតម្លៃ

គ្រប់គ្រងគ្រូមត្តេយ្យសិក្សា គ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ និង (៩០%) បានគាំទ្រលើការងារសន្តិសុខសណ្តាប់ធ្នាប់ និងអនាម័យបរិស្ថាន និង (៥៥%) បានចូលរួមកៀរគរធនធានសម្រាប់អភិវឌ្ឍន៍សាលារៀន

- ការគាំទ្រ និងអន្តរាគមន៍នានារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌលើការងាររបស់សាលារៀនរួមមាន៖ (ការងារគ្រប់គ្រងសិស្ស គ្រប់គ្រងគ្រូបង្រៀន ការងារហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់សាលារៀន និងការងារផ្សេងទៀត) ត្រូវបានមើលឃើញថាបានគាំទ្រច្រើន ចន្លោះពី (៦៥% ទៅដល់ ៩២%)
- គុណភាពនៃការផ្តល់សេវាអនុវិស័យការអប់រំកុមារតូចរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌភាគច្រើនបានបង្ហាញការពេញចិត្តចំពោះការផ្តល់សេវា និងគុណភាពសេវាអប់រំសម្រាប់មុខងាររងការអប់រំកុមារតូច៖ ប៉ុន្តែក្នុងនោះក៏មានមតិមួយចំនួនបានលើកឡើងដែរថា នៅមានកម្រិតនៅឡើយ (៥២%) ពេញចិត្តមធ្យម (៧%) មិនពេញចិត្តសោះ (២៤%) ពេញចិត្តតិចតួច និង(១៧%) ពេញចិត្តខ្លាំង
- យន្តការគាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការងារគ្រប់គ្រង ការចាត់ចែង និងការអនុវត្តកិច្ចការក្នុងវិស័យអប់រំ និងដោះស្រាយបញ្ហានានានៅតាមសាលារៀន។ ក្រុមប្រឹក្សា និងគណៈអភិបាលបានប្រើប្រាស់យន្តការត្រួតពិនិត្យវាយតម្លៃរបស់ខ្លួន (៩២.៦%) តាមរយៈការចុះតាមដានត្រួតពិនិត្យផ្ទាល់ (៨៨.៩%) តាមរយៈកិច្ចប្រជុំរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ (៨២.៥%) តាមរយៈរបាយការណ៍ និង (៥៥.៦%) តាមរយៈយន្តការត្រួតពិនិត្យផ្ទៃក្នុង
- ចំពោះបញ្ហាប្រឈមរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តអនុវិស័យការអប់រំកុមារតូច ត្រូវបានមើលឃើញបញ្ហាក្នុងនោះ គឺ (៣៧%) ការគាំទ្រផ្នែកបច្ចេកទេស (២១%) ធនធាន (២៥%) យន្តការត្រួតពិនិត្យតាមដាន (២៥%) បែងចែកតួនាទី និងការទទួលខុសត្រូវ និង (២៦%) ការងាររដ្ឋបាលខ្សែគណនេយ្យភាព។ បញ្ហាមួយចំនួនទៀតទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធ ឧបសគ្គធនធាន និងការធានាឱ្យមានលទ្ធភាពទទួលបានដោយសមធម៌សម្រាប់កុមារទាំងអស់។ ការដោះស្រាយបញ្ហាប្រឈមទាំងនេះ តម្រូវឱ្យមានការខិតខំប្រឹងប្រែងបន្តទៀត និងវិនិយោគក្នុងការងារការអប់រំកុមារតូច ដោយផ្តោតលើការពង្រឹងសម្ភារបរិក្ខារ ការផ្តល់ធនធានគ្រប់គ្រាន់ និងផ្តល់ការបណ្តុះបណ្តាលដល់គ្រូឱ្យបានទូលំទូលាយថែមទៀត។

❖ ***អនុវិស័យការអប់រំបឋមសិក្សា***

អនុវិស័យការអប់រំបឋមសិក្សាមានការរីកចម្រើនទៅមុខយ៉ាងលឿនក្នុងប៉ុន្មានឆ្នាំកន្លងមកនេះ ជាមួយនឹងសមិទ្ធផលគួរឱ្យកត់សម្គាល់ក្នុងការបង្កើនចំនួនសាលារៀន ការអនុវត្តការគ្រប់គ្រងតាមសាលា

រៀន និងការលើកកម្ពស់កម្មវិធីគាំទ្រសិស្ស។ ការណែនាំអំពីការអប់រំពហុភាសា និងកម្មវិធីសាលាកុមារមេត្រី ក៏បានរួមចំណែកដល់បរិយាកាសសិក្សាដែលរួមបញ្ចូល និងគាំទ្របន្ថែមទៀត។

- ចំនួនសិស្សអាហារូបករណ៍ក៏បានកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ ចន្លោះពី ៦៨,២៣៤នាក់ ក្នុងឆ្នាំសិក្សា២០១៤-២០១៥ ដល់ ១៤៨,៩០១នាក់ ក្នុងឆ្នាំសិក្សា២០២២-២០២៣ ដែលលើសពីគោលដៅចុងក្រោយ និងបង្ហាញពីការខិតខំប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីឆ្ពោះទៅកាន់ការលើកកម្ពស់សមធម៌នៃការអប់រំបឋមសិក្សា (EMIS 2022-2023)
- ផ្អែកតាមលទ្ធផលនៃការស្ទង់មតិបានមើលឃើញថា កម្រិតនៃការយល់ដឹងរបស់ក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក ខណ្ឌ លើគោលនយោបាយផែនការយុទ្ធសាស្ត្រគ្រប់គ្រងការងារអប់រំបឋមសិក្សានៅមានកម្រិតនៅឡើយជាក់ស្តែង ១០.៥២% យល់ដឹងតិចតួច ៤២.១០% យល់ដឹងមធ្យម ៣១.៥៧% យល់ដឹងបង្គួរ និង ៧.៨៨% យល់ដឹងពេញលេញ។ ប៉ុន្តែរដ្ឋបាលក្រុង ស្រុក ខណ្ឌជានិច្ចកាលតែងតែបានផ្តោតការយកចិត្តទុកដាក់ខ្ពស់ក្នុងការអភិវឌ្ឍលើវិស័យអប់រំក្នុងមូលដ្ឋានរបស់ខ្លួន ជាពិសេសផ្តោតលើអនុវិស័យការអប់រំបឋមសិក្សា
- ជាក់ស្តែងរដ្ឋបាលក្រុង ស្រុក ខណ្ឌបានដាក់បញ្ចូលផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំឆ្នាំស្តីពីការអប់រំបឋមសិក្សាចូលក្នុងផែនការអភិវឌ្ឍន៍០៥ឆ្នាំ ឬកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ក្រុង ស្រុក ខណ្ឌនៅក្នុងឆ្នាំ២០២៣ ហើយរដ្ឋបាលក្រុង ស្រុក ខណ្ឌបានអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំឆ្នាំស្តីពីការអប់រំបឋមសិក្សាទាំងនោះមានចំនួន ៤១% បានតិចតួច ៣៩% មធ្យម ១៧% បានបង្គួរ និង ៣% បានពេញលេញ
- ទន្ទឹមនឹងមានការរីកចម្រើនដូចបានរៀបរាប់ខាងលើ ក៏នៅមានបញ្ហាប្រឈមមួយចំនួនដូចជា៖ អត្រាបោះបង់ការសិក្សា និងអត្រាត្រួតថ្នាក់ អត្រាបញ្ចប់ការសិក្សាមិនទាន់សម្រេចបានចំណុចដៅដែលបានគ្រោងទុក និងទាមទារឱ្យមានការខិតខំបន្ថែមទៀត ដើម្បីរកដំណោះស្រាយជាបន្ទាន់។ ផ្អែកលើផែនការយុទ្ធសាស្ត្រវិស័យអប់រំ ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងបន្តកិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ និងបន្តលើកកម្ពស់វឌ្ឍនភាពដែលបានធ្វើនាពេលកន្លងមក ដើម្បីធានាថាកុមារទាំងអស់នៅក្នុងប្រទេសកម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ដើម្បីទទួលបានការអប់រំបឋមសិក្សាមួយប្រកបដោយគុណភាពខ្ពស់ សមធម៌ និងបរិយាបន្ន
- ស្ថានភាពនៃការអនុវត្តមុខងារអនុវិស័យការអប់រំបឋមសិក្សារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានកត់សម្គាល់ឃើញថានៅមានកម្រិតនៅឡើយ ជាក់ស្តែងនៅមានការជួបឧបសគ្គ ឬបញ្ហាភាគច្រើនលើ៖ ៦៦.៦៦% ការងារគាំទ្របច្ចេកទេស ៧៣.៣៣% ការងារបែងចែកតួនាទី និងទំនួលខុសត្រូវ ៦០% ការងាររដ្ឋបាលនិងខ្សែគណនេយ្យភាព និង ៥៦.២៥% ធនធាន។

❖ **អនុវិស័យការអប់រំក្រៅប្រព័ន្ធ និងបរិយាបន្ន**

ផ្អែកតាមស្ថិតិ និងសូចនាករអប់រំក្រៅប្រព័ន្ធ (ឆ្នាំ២០២៣) អនុវិស័យការអប់រំក្រៅប្រព័ន្ធក្នុងប្រទេសកម្ពុជា បានមើលឃើញថា មានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងការពង្រីក និងលើកកម្ពស់ឱកាសសិក្សាសម្រាប់កុមារ យុវជន និងមនុស្សពេញវ័យដែលនៅក្រៅសាលា។ សមិទ្ធិផលសំខាន់ៗរួមមាន ការអភិវឌ្ឍ និងការអនុវត្តកម្មវិធីអក្ខរកម្មវិជ្ជាជីវៈ កម្មវិធីក្រោយអក្ខរកម្ម កម្មវិធីចូលរៀនឡើងវិញ កម្មវិធីសមមូល កម្មវិធីបំពេញវិជ្ជា កម្មវិធីបង្កើនប្រាក់ចំណូល ការកសាងសមត្ថភាពសំខាន់ៗសម្រាប់អ្នកអប់រំ និងការប្រែក្លាយមជ្ឈមណ្ឌលសិក្សាសហគមន៍ទៅជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត។

- ចំនួនសិស្សនៅក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធមានការប្រែប្រួល ដោយមានសិស្សចំនួន ៧០,៧៤១នាក់ ក្នុងឆ្នាំសិក្សា២០១២-២០១៣ និង ៤៧,១៧៣នាក់ ក្នុងឆ្នាំសិក្សា២០២២-២០២៣។ អត្រាបញ្ចប់ការសិក្សាក៏មានការប្រែប្រួលផងដែរ ដោយសិស្សចំនួន ៥៥,៨០៨នាក់ បានបញ្ចប់កម្មវិធីក្នុងឆ្នាំ២០១២-២០១៣ និង ៤៤,៣៧៣នាក់ ក្នុងឆ្នាំ២០២២-២០២៣។ ក្រសួងអប់រំ យុវជន និងកីឡាបានពង្រឹងសមត្ថភាពស្ថាប័ន តាមរយៈវិធានការផ្សេងៗ រួមទាំងការបង្កើនប្រាក់កម្រៃសម្រាប់គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ។ កិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើងដើម្បីធ្វើបច្ចុប្បន្នភាព និងកែលម្អកម្មវិធីសិក្សា សៀវភៅសិក្សា និងលិខិតបទដ្ឋានគតិយុត្ត
- អត្រាអក្ខរកម្មសម្រាប់មនុស្សពេញវ័យ (អាយុចាប់ពី ១៥ឆ្នាំឡើងទៅ) មានភាពប្រសើរឡើង គាំទ្រដោយមានការយកចិត្តទុកដាក់ពីអ្នកសិក្សា ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ជាមួយនិងការបង្កើតមជ្ឈមណ្ឌលសិក្សាសហគមន៍ និងមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត។ ចំនួននៃមជ្ឈមណ្ឌលទាំងនេះបានកើនឡើងយ៉ាងឆាប់រហ័សដោយសារមានកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍
- រដ្ឋបាលក្រុង ស្រុក ខណ្ឌមានកិច្ចសហការល្អប្រសើរជាមួយការិយាល័យអប់រំ យុវជន និងកីឡា និងមន្ត្រីជំនាញពាក់ព័ន្ធក្នុងការកសាងផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងការអនុវត្តផែនការសកម្មភាពវិស័យអប់រំទាំងបីអនុវិស័យ
- ស្ថានភាពនៃការអនុវត្តមុខងារអប់រំអនុវិស័យការអប់រំក្រៅប្រព័ន្ធ និងបរិយាបន្នរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌសម្រាប់ក្រុមប្រឹក្សា កត់សម្គាល់ឃើញថានៅមានកម្រិតនៅឡើយ ជាក់ស្តែង គឺជួបបញ្ហាចម្បងលើ៖ ៥០% ការងារគាំទ្របច្ចេកទេស ៤៦.៦៦% ការងារបែងចែងតួនាទីភារកិច្ច និងទទួលខុសត្រូវ ៣៤.៣៧% ការងាររដ្ឋបាលនិងខ្សែគណនេយ្យភាព និង ៤៦.៦៦% ធនធាន។ ដោយឡែកសម្រាប់គណៈអភិបាលវិញ គឺជួបបញ្ហាចម្បងលើ៖ ៣៣% ការងារគាំទ្របច្ចេកទេស ៣៦% ការងារបែងចែងតួនាទីភារកិច្ចនិងទទួលខុសត្រូវ ៣២% ការងាររដ្ឋបាលនិងខ្សែគណនេយ្យភាព ៤០% ធនធាន និង ២៩% ការងារត្រួតពិនិត្យតាមដាន
- កម្រិតនៃការយល់ដឹងរបស់ក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក ខណ្ឌលើគោលនយោបាយ ផែនការយុទ្ធសាស្ត្រគ្រប់គ្រងការងារអប់រំក្រៅប្រព័ន្ធ និងបរិយាបន្ននៅមានកម្រិតនៅឡើយ ជាក់ស្តែង ការអប់រំក្រៅប្រព័ន្ធ និងបរិយាបន្នមានចំនួន ៣៣.៣៣% យល់ដឹងតិចតួច ៤៦.៦៦%

យល់ដឹងមធ្យម ៣៦.៦៦% យល់ដឹងបង្គួរ និង ០% យល់ដឹងពេញលេញ។ ប៉ុន្តែជានិច្ចកាល រដ្ឋបាលក្រុង ស្រុក ខណ្ឌតែងតែបានផ្តោតការយកចិត្តទុកដាក់ខ្ពស់ក្នុងការអភិវឌ្ឍលើវិស័យ អប់រំក្នុងមូលដ្ឋានរបស់ខ្លួន ជាពិសេសផ្តោតលើអនុវិស័យការអប់រំក្រៅប្រព័ន្ធ និងបរិយាបន្ន។

❖ **សេចក្តីសន្និដ្ឋាន**

ជារួម ស្ថានភាពមុនការផ្ទេរការអនុវត្តមុខងារវិស័យអប់រំ យុវជន និងកីឡានៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំទាំងនោះពុំសូវមានបញ្ហាណាមួយគួរឱ្យកត់សម្គាល់ឡើយ ប៉ុន្តែសង្កេតឃើញថា រដ្ឋបាលក្រុង ស្រុក ខណ្ឌបានយកចិត្តទុកដាក់ខ្ពស់ក្នុងការគ្រប់គ្រង ការចាត់ចែង ការតាមដានត្រួតពិនិត្យ និងការដោះស្រាយបញ្ហាប្រឈមនានាក្នុងការអនុវត្តមុខងារអប់រំ បានយ៉ាងល្អប្រសើរ។ កម្រិតនៃការគ្រប់គ្រង ការចាត់ចែង និងការយល់ដឹងពីកិច្ចការមួយចំនួនក្នុងវិស័យ អប់រំ យុវជន និងកីឡាមុនសមាហរណកម្មនៅមានកម្រិត រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក៏បានជួបបញ្ហាប្រឈម ជាគន្លឹះមួយចំនួនពាក់ព័ន្ធនឹងសិទ្ធិអំណាច កិច្ចសហការ យន្តការគាំទ្រ និងការតាមដាន ត្រួតពិនិត្យលើការផ្តល់សេវាអប់រំក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ផ្អែកលើលទ្ធផលសិក្សាទិន្នន័យដើមគ្រានេះ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវបន្តពង្រឹងការចុះតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងគាំទ្រដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌបន្ថែមទៀត ដើម្បីធានាដល់ការលើកកម្ពស់គុណភាពសេវា អប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព សមធម៌ និង បរិយាបន្ន។

តាមរយៈការផ្ទេរមុខងារក្នុងវិស័យអប់រំនេះ នឹងផ្តល់ការទទួលខុសត្រូវ និងភាពម្ចាស់ការដល់រដ្ឋបាល ក្រុង ស្រុក ខណ្ឌក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរទៅនោះឱ្យកាន់តែមានប្រសិទ្ធភាព ប្រសិទ្ធផល និងចូលរួមចំណែកសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាលក្នុងការ លើកកម្ពស់មូលធនមនុស្សនៅព្រះរាជាណាចក្រកម្ពុជា។

## ១. សេចក្តីផ្តើម

ការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាកិច្ចការដ៏មានសារៈសំខាន់ និងចាំបាច់នៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាការបង្វិតការធ្វើសេចក្តីសម្រេចចិត្តក្នុងការគ្រប់គ្រង ការចាត់ចែង និងការផ្តល់សេវាសាធារណៈឱ្យទៅកៀកជិតនឹងប្រជាពលរដ្ឋ ដើម្បីលើកកម្ពស់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យបានឆាប់រហ័ស ចំទិសដៅ និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៅតាមមូលដ្ឋាននីមួយៗប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម។ ជាគោលការណ៍ ការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវផ្ទេរភ្ជាប់ទៅជាមួយនូវធនធានហិរញ្ញវត្ថុ ធនធានមនុស្ស សិទ្ធិអំណាច និងការទទួលខុសត្រូវលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារដែលបានផ្ទេរទាំងនោះ។ ដើម្បីជានាដល់ការសម្រេចបាននូវគោលការណ៍នៃការផ្ទេរមុខងារទាំងនោះ ចាំបាច់ត្រូវមានការគាំទ្រ និងកិច្ចសហការគ្នាយ៉ាងជិតស្និទ្ធជាមួយកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល ជាពិសេសកំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ បច្ចុប្បន្ននេះ កំណែទម្រង់រដ្ឋបាលសាធារណៈបាននិងកំពុងផ្តោតទៅលើការពង្រឹងប្រសិទ្ធភាពស្ថាប័ន ការលើកកម្ពស់ប្រសិទ្ធភាពនៃគ្រប់គ្រងធនធានមនុស្សទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សំដៅជានាដល់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសង្គមប្រកបដោយសមធម៌ យុត្តិធម៌ និងបរិយាបន្ន ដោយផ្តោតលើការជំរុញនវានុវត្តន៍ ការប្រើប្រាស់បច្ចេកវិទ្យាទូរគមនាគមន៍ និងព័ត៌មានក្នុងរដ្ឋបាលសាធារណៈ ការជំរុញការដាក់ឱ្យអនុវត្តនូវប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម ការរៀបចំយន្តការគណនេយ្យភាពរបស់ស្ថាប័នសាធារណៈ និងការចូលរួមវាយតម្លៃរបស់ប្រជាជនក្នុងដំណើរការនៃការផ្តល់សេវាសាធារណៈ។

វិស័យអប់រំ គឺជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពនានាដែលច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានតម្រូវឱ្យមានការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រោមការសម្របសម្រួល និងការគាំទ្របច្ចេកទេសពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) ចាប់ពីឆ្នាំ២០១៤មក ក្រសួងអប់រំ យុវជន និងកីឡាបានចាប់ផ្តើមរៀបចំផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមគោលការណ៍ និងដំណើរការដែលបានកំណត់ ក្នុងនោះរួមមាន ការរៀបចំបញ្ជីវិភាគមុខងារ ការពិនិត្យឡើងវិញនូវមុខងារ ការកំណត់មុខងារ និងធនធានដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការកំណត់នូវបែបផែននៃការផ្ទេរមុខងារ និងធនធានទាំងនោះ (ការធ្វើប្រតិភូកម្ម ឬការប្រគល់) ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។ នាឆ្នាំ២០១៦ តាមរយៈ គ.ជ.អ.ប. ក្រសួងអប់រំ យុវជន និងកីឡាបានស្នើផ្ទេរមុខងារក្នុងវិស័យអប់រំចំនួន០៣ ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ រួមមាន មុខងារគ្រប់គ្រងការអប់រំកុមារតូច មុខងារគ្រប់គ្រងការអប់រំបឋមសិក្សា និងមុខងារគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ។ ផ្អែកតាមសំណើរបស់ក្រសួងអប់រំ យុវជន និងកីឡា រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវអនុក្រឹត្យលេខ១៩១ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការប្រគល់មុខងារការគ្រប់គ្រងការអប់រំកុមារតូច ការគ្រប់គ្រងការអប់រំបឋមសិក្សា និងការគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធឱ្យទៅរដ្ឋបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបងសម្រាប់ការអនុវត្តដំណាក់កាលដំបូង ។ ការអនុវត្ត

សាកល្បងនេះ បានចងក្រងជាមេរៀន បទសោធន៍សម្រាប់ការប្រគល់មុខងារក្នុងវិស័យអប់រំទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌដទៃទៀតជាជំហានៗ។

នៅចុងឆ្នាំ២០១៩ រាជរដ្ឋាភិបាលបានសម្រេចធ្វើសមាហរណកម្មការិយាល័យជំនាញនានានៅថ្នាក់ក្រុង ស្រុក ខណ្ឌចូលទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស តាមរយៈការដាក់ចេញអនុក្រឹត្យលេខ១៨២ ១៨៣ និង១៨៤ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងនោះក៏មានការិយាល័យអប់រំ យុវជន និងកីឡាផងដែរ។ រហូតមកដល់ឆ្នាំ២០២៣ រដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងអស់បានទទួលខុសត្រូវក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារលើវិស័យអប់រំ យុវជន និងកីឡាក្នុងកម្រិតតែប្រតិភូកម្មប៉ុណ្ណោះ លើកលែងតែរដ្ឋបាលក្រុង ស្រុកនៅខេត្តបាត់ដំបងដែលបានទទួលខុសត្រូវក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាតាមបែបផែននៃការប្រគល់ និងប្រតិភូកម្មជាលក្ខណៈសាកល្បង។

ផ្អែកលើលទ្ធផលនៃការសិក្សាវាយតម្លៃលើការអនុវត្តមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡារបស់រដ្ឋបាលក្រុង ស្រុកនៃខេត្តបាត់ដំបង បានបង្ហាញឱ្យឃើញថា ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារនោះទទួលបានប្រសិទ្ធភាពខ្ពស់ មានការគាំទ្រ និងកោតសរសើរពីគ្រប់មជ្ឈដ្ឋាន និងអ្នកពាក់ព័ន្ធនានា។ ហេតុដូច្នេះ រាជរដ្ឋាភិបាលបានសម្រេចពង្រីកការប្រគល់ និងការធ្វើប្រតិភូកម្មមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេសតែម្តង តាមរយៈអនុក្រឹត្យលេខ២១៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងបានធ្វើការផ្សព្វផ្សាយដាក់ឱ្យអនុវត្តនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣ ក្រោមអធិបតីភាពរបស់**ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប. និង**ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

មុខងារចំនួន០៦ ក្នុងវិស័យអប់រំ យុវជន និងកីឡាដែលត្រូវបានប្រគល់ និងធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ រួមមានដូចខាងក្រោម៖

- **មុខងារដែលបានប្រគល់**
  - ១). ការគ្រប់គ្រងការអប់រំកុមារតូច
  - ២). ការគ្រប់គ្រងការអប់រំបឋមសិក្សា
  - ៣). ការគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ។
- **មុខងារដែលបានធ្វើប្រតិភូកម្ម**
  - ៤). ការងារគាំទ្រផ្នែករដ្ឋបាលដល់គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ
  - ៥). ការងារគាំទ្រផ្នែករដ្ឋបាលដល់ការអភិវឌ្ឍយុវជន
  - ៦). ការងាគាំទ្រផ្នែករដ្ឋបាលដល់ការងារអប់រំកាយ និងកីឡា។

ដើម្បីជានាបានការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព និងសក្តិសិទ្ធិភាព ការសិក្សាទិន្នន័យដើមគ្រានៅមុនការផ្ទេរមុខងារ

គឺជាកិច្ចការចាំបាច់ ដើម្បីកំណត់នូវសូចនាករសំខាន់ៗមួយចំនួនសម្រាប់ប្រៀបធៀបនៅពេលអនាគត បន្ទាប់ពីរដ្ឋបាលក្រុង ស្រុក ខណ្ឌទទួលខុសត្រូវក្នុងការអនុវត្តមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡា។ ការសិក្សាទិន្នន័យដើមគ្រានេះ គឺជាមូលដ្ឋានសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃលទ្ធផល និងសមិទ្ធផល នៃការផ្តល់សេវាអប់រំ និងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីបង្ហាញដល់រាជរដ្ឋាភិបាល និងប្រជាពលរដ្ឋឱ្យឃើញថា ការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ពិតជាដើរតួនាទីយ៉ាងសំខាន់ ក្នុងការចូលរួមចំណែកសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

## ២. គោលបំណង

គោលបំណងនៃការសិក្សាទិន្នន័យដើមគ្រា គឺដើម្បីវាយតម្លៃអំពីស្ថានភាពជាក់ស្តែងបច្ចុប្បន្ន និង ទស្សនៈយល់ឃើញរបស់អ្នកពាក់ព័ន្ធអំពីគុណភាពសេវាអប់រំនៅមុនពេលដែលរដ្ឋបាលក្រុង ស្រុក ខណ្ឌ បានចាប់ផ្តើមអនុវត្តមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡា តាមរយៈអនុក្រឹត្យលេខ២១៣ អនក្រ.បក។ ទិន្នន័យដើមគ្រានឹងត្រូវបានយកមកធ្វើជាមូលដ្ឋានសម្រាប់ប្រៀបធៀបគុណភាពសេវាអប់រំនាពេលអនាគត និងរួមចំណែកដល់លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងអប់រំ យុវជន និងកីឡាបន្តគាំទ្រការអនុវត្តមុខងារ ក្នុងវិស័យអប់រំ យុវជន និងកីឡាដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

យោងតាមគោលបំណងខាងលើ ការរៀបចំសូចនាករវាយតម្លៃគុណភាពសេវាការអប់រំកុមារតូច អប់រំបឋមសិក្សា និងអប់រំក្រៅប្រព័ន្ធ មានសមាសធាតុសំខាន់ចំនួន០៣ ដូចជា៖ (១) ការអភិវឌ្ឍរបស់ប្រព័ន្ធអប់រំទាំងបីអនុវិស័យ (២) ការដឹកនាំ និងការគ្រប់គ្រង និង (៣) យន្តការត្រួតពិនិត្យ និងវាយតម្លៃ។

## ៣. វិសាលភាពគ្របដណ្តប់នៃការសិក្សា

ការសិក្សានេះ ក្រុមការងារអន្តរក្រសួងសម្រេចជ្រើសរើសរាជធានី ខេត្តគោលដៅនៅតាមតំបន់ រាយប៉ាយពេញប្រទេសដូចជា តំបន់ទីក្រុងធំ តំបន់មាត់សមុទ្រ តំបន់ជនបទជាដើម។ ក្រុង ស្រុក ខណ្ឌ គោលដៅចំនួន៣១ នៃរាជធានី ខេត្តចំនួន០៦ មានដូចជា រាជធានីភ្នំពេញ ខេត្តកំពត ខេត្តមណ្ឌលគិរី ខេត្តស្វាយរៀង ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាបត្រូវបានជ្រើសរើស។

ក្រុមគោលដៅដើម្បីជួបសម្ភាសផ្តល់ព័ត៌មានក្នុងការសិក្សានេះ ត្រូវបានកំណត់តាមប្រភេទផ្សេងៗ គ្នាចំនួន ១០ក្រុម ដូចខាងក្រោម៖

- ក្រុមទី១ ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ
- ក្រុមទី២ អភិបាលរងក្រុង ស្រុក ខណ្ឌទទួលបន្ទុកការិយាល័យអប់រំ
- ក្រុមទី៣ ប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ
- ក្រុមទី៤ តំណាងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងមន្ត្រីទទួលបន្ទុកអនុវិស័យទាំងបី
- ក្រុមទី៥ នាយក/នាយិកាសាលាមត្តេយ្យសិក្សារដ្ឋ
- ក្រុមទី៦ នាយក/នាយិកាសាលាបឋមសិក្សារដ្ឋ
- ក្រុមទី៧ ប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍

- ក្រុមទី៨  គ្រូបង្រៀន
- ក្រុមទី៩  មេឃុំ ឬចៅសង្កាត់
- ក្រុមទី១០ ប្រធានគណៈកម្មការគ្រប់គ្រងសាលារៀន។

## ៤. យន្តការដឹកនាំសម្របសម្រួលការសិក្សាទិន្នន័យដើមគ្រា

ការសិក្សាទិន្នន័យដើមគ្រាលើគុណភាពសេវាអប់រំនេះ បានរៀបចំដោយយោងលើភាពចាំបាច់ និងឯកភាពស្រុះស្រួលគ្នាជាគោលការណ៍រវាងលេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងអប់រំ យុវជន និងកីឡា ដែលបានណែនាំតម្រង់ទិស និងដាក់ចេញនូវឯកសារទស្សនទានស្តីពីការសិក្សាទិន្នន័យដើមគ្រាលើគុណភាពសេវាអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ លេខាធិការដ្ឋាន គ.ជ.អ.ប. បានសម្របសម្រួល និងដឹកនាំក្រុមការងារបច្ចេកទេសអន្តរក្រសួងសម្រាប់ការសិក្សាទិន្នន័យដើមគ្រានេះ។

ក្រុមការងារបច្ចេកទេសអន្តរក្រសួងចុះសិក្សាទិន្នន័យដើមគ្រានេះ គឺជាយន្តការដឹកនាំសម្របសម្រួលកិច្ចដំណើរការសិក្សាទិន្នន័យដើមគ្រាលើគុណភាពសេវាអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដោយមានសមាជិកសរុបចំនួន **២៤រូប** ដែលមានសមាសភាពមកពីលេខាធិការដ្ឋាន គ.ជ.អ.ប. ចំនួន ០៦រូប ក្រសួងអប់រំ យុវជន និងកីឡា ចំនួន ១២រូប និងក្រសួងមហាផ្ទៃចំនួន ០៦រូប។ ការសិក្សាទិន្នន័យដើមគ្រានេះក៏មានការចូលរួមគាំទ្របច្ចេកទេសពីកម្មវិធី "ធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាជូនប្រជាពលរដ្ឋនៅកម្ពុជា" គាំទ្រហិរញ្ញប្បទានពីរដ្ឋាភិបាលអាល្លឺម៉ង់ និងរដ្ឋាភិបាលស្វីស ដែលហៅកាត់ជាភាសាអង់គ្លេសថា ( ISD/GIZ )។

## ៥. វិធីសាស្ត្រនៃការវិភាគទិន្នន័យដើមគ្រា

ការសិក្សាទិន្នន័យដើមគ្រានេះ គឺបានប្រើវិធីសាស្ត្រចម្រុះក្នុងការប្រមូលទិន្នន័យ ហើយវិធីសាស្ត្រសំខាន់ៗដែលបានអនុវត្តក្នុងកិច្ចដំណើរការសិក្សាទិន្នន័យដើមគ្រានេះ រួមមានដូចខាងក្រោម៖

### ៥.១. ការសិក្សាលើបទដ្ឋានគតិយុត្ត

ក្រុមការងារបច្ចេកទេសអន្តរក្រសួងបានសិក្សាលើលិខិតបទដ្ឋានគតិយុត្តសំខាន់ៗពាក់ព័ន្ធនឹងការផ្ទេរមុខងារក្នុងវិស័យអប់រំទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីកំណត់ទិដ្ឋភាព និងលក្ខខណ្ឌចាំបាច់នានាសម្រាប់ជាមូលដ្ឋានក្នុងការពិនិត្យ ការវាស់វែង ការវាយតម្លៃ និងការវិភាគស្ថានភាពលើការអនុវត្តជាក់ស្តែង និងគុណភាពនៃសេវាអប់រំមុនពេលមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាបានចាប់ផ្តើមអនុវត្តដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមរយៈអនុក្រឹត្យលេខ២១៣ អនក្រ.បក។ លិខិតបទដ្ឋានគតិយុត្តសំខាន់ៗដែលក្រុមការងារអន្តរក្រសួងបានសិក្សារួមមាន៖

– អនុក្រឹត្យលេខ២១៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ស្តីពីការផ្ទេរមុខងារអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ

- អនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
- អនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ
- អនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុក
- អនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសអន្តរក្រសួងលេខ៥២១ សហវ ប្រ.ក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ស្តីពីលក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុសម្រាប់ផ្ទេរធនធានមានភ្ជាប់លក្ខណ្ឌទៅឱ្យរដ្ឋបាលក្រុង ស្រុកទាំង១៤ ក្នុងខេត្តបាត់ដំបងសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ
- សារាចរណែនាំលេខ០០១ សហវ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីនីតិវិធីអនុវត្តថវិកាបញ្ជិកាគណនេយ្យ និងចលនាឥណទានថវិកានៃការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុង ស្រុកទាំង១៤ ក្នុងខេត្តបាត់ដំបងសម្រាប់អនុវត្តមុខងារគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ
- សេចក្តីសម្រេចរបស់ គ.ជ.អ.ប. ស្តីពីការផ្ទេរសមាហរណកម្មបុគ្គលិក និងការរៀបចំមុខតំណែងគ្រប់គ្រងនៅក្នុងរចនាសម្ព័ន្ធនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ
- សៀវភៅណែនាំស្តីពីគោលការណ៍ បែបបទ និងនីតិវិធីសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡា
- ទិន្នន័យការអភិវឌ្ឍរបស់ប្រព័ន្ធអប់រំនៃអនុវិស័យទាំងបី រួមមាន អប់រំកុមាតូច អប់រំបឋមសិក្សា និងអប់រំក្រៅប្រព័ន្ធ ឆ្នាំ២០២២-២០២៣ (EMIS)។

### ៥.២. ការសិក្សាលើទិន្នន័យ

សូចនាករសម្រាប់វាស់វែងអំពីស្ថានភាពដឹកនាំ គ្រប់គ្រង ចាត់ចែងមុខងារលើគុណភាពសេវាអប់រំនៃអនុវិស័យចំនួន០៣ មុនប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវបែងចែកជាពីរប្រភេទដូចខាងក្រោម៖

#### ក). ការប្រមូលទិន្នន័យបែបបរិមាណ

ការប្រមូលទិន្នន័យបែបបរិមាណ ត្រូវបានផ្តោតជាចម្បងលើការប្រមូលទិន្នន័យដែលមានស្រាប់អំពីសូចនាករអប់រំស្នូលដែលជ្រើសរើសពីប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ (EMIS ឆ្នាំ២០២២-២០២៣) របស់ក្រសួងអប់រំ យុវជន និងកីឡាចំពោះការអប់រំកម្រិតមត្តេយ្យសិក្សា និងបឋមសិក្សា ដូចបានបង្ហាញក្នុងឧបសម្ព័ន្ធទី១ និងទី២នៃរបាយការណ៍នេះ។ ដោយឡែក សូចនាករអប់រំក្រៅប្រព័ន្ធ ផ្អែកលើប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ (NFE-MIS ឆ្នាំ២០២៣) របស់នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ បានបង្ហាញក្នុងឧបសម្ព័ន្ធ

ទី៣នៃរបាយការណ៍នេះ។

**ខ). ការប្រមូលទិន្នន័យបែបគុណភាព**

ក្រុមការងារអន្តរក្រសួងបានផ្តោតសំខាន់លើការប្រមូលទិន្នន័យបែបគុណភាព ដែលចង់ដឹងអំពីទស្សនៈ និងការយល់ឃើញរបស់អ្នកពាក់ព័ន្ធនៃក្រុមគោលដៅនីមួយៗអំពីការអភិវឌ្ឍប្រព័ន្ធអប់រំ ការដឹកនាំ ការគ្រប់គ្រង និងយន្តការត្រួតពិនិត្យ និងវាយតម្លៃ តាមរយៈជួបដោយផ្ទាល់ ដើម្បីស្ទង់មតិ និងការយល់ឃើញផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗអំពីការអភិវឌ្ឍ ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តការងារក្នុងវិស័យអប់រំ យុវជន និងកីឡា និងភាពពេញចិត្តអំពីគុណភាពសេវាការអប់រំកុមារតូច បឋមសិក្សា និងអប់រំក្រៅប្រព័ន្ធ។ ក្រុមការងារបានរៀបចំបញ្ជីសំណួរ ១០ប្រភេទផ្សេងគ្នានៅលើថ្នាល Google Form ដើម្បីឱ្យបុគ្គលម្នាក់ៗបំពេញចម្លើយអំពីទស្សនៈ និងការយល់ឃើញរបស់ពួកគេដោយស្មោះត្រង់។ បញ្ជីសំណួរទាំង ១០ក្រុម ត្រូវបានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី៤ នៃរបាយការណ៍នេះ។

**៥.៣. ក្រុមគោលដៅ**

ការជ្រើសរើសសំណាកត្រូវបានជ្រើសរើសដោយចៃដន្យ ផ្តោតសំខាន់លើចំនួនក្រុង ស្រុក ខណ្ឌ និងចំនួនសាលារៀនជាគោល។ ផ្អែកលើកត្តានេះ ក្រុង ស្រុក ខណ្ឌចំនួន៣១ នៃ២០៨ ក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេស ឬស្មើនឹង ១៥% និងចំនួនសាលារៀនទាំងមត្តេយ្យសិក្សា និងបឋមសិក្សាមានចំនួន ៦៩៨ នៃចំនួនសាលាសរុបប្រមាណ ៧,០០០សាលា ឬប្រហែល ១០% ត្រូវបានជ្រើសរើសធ្វើជាសំណាកដើម្បីចូលរួមផ្តល់ចម្លើយក្នុងការប្រមូលទិន្នន័យបែបគុណភាព ដែលមានចំនួនអ្នកចូលរួមក្នុងការស្ទង់មតិនេះមានចំនួន **៣,៩៩៤នាក់** ដែលជ្រើសរើសដោយចៃដន្យមកពីក្រុមគោលដៅទាំង១០ ដូចមានបង្ហាញក្នុងតារាងខាងក្រោម៖

| ទម្រង់ | ក្រុមអ្នកផ្តល់ចម្លើយ | ចំនួនគ្រោង | ចំនួនអ្នកបានឆ្លើយ | ចម្លើយទទួលយកបាន | ភាគរយ |
|---|---|---|---|---|---|
| ២.១ | ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | ៣១ | ៣៩ | ៣៧ | ១១៩.៤ |
| ២.២ | អភិបាល អភិបាលរងទទួលបន្ទុកអប់រំ | ៣១ | ៣២ | ២៩ | ៩៣.៥ |
| ២.៣ | ប្រធានការិយាល័យអប់រំ យុវជន និងកីឡា | ៣១ | ៥១ | ៥៨ | ១៥៤.៨ |
| ២.៤ | ប្រធានមន្ទីរអប់រំ យុវជន និងកីឡា និងប្រធានការិយាល័យអនុវិស័យទាំងបី | ២៤ | ៥ | ៥ | ២០.៨ |
| ២.៥ | នាយកសាលាមត្តេយ្យសិក្សារដ្ឋ | ២៩៧ | ៨៤ | ៨២ | ២៧.៦ |
| ២.៦ | នាយក/នាយិកាសាលាបឋមសិក្សា | ៤០១ | ៦៥១ | ៦៣៩ | ១៥៩.៤ |

| | | | | | |
|---|---|---|---|---|---|
| ២.៧ | ប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍ | ៦២ | ៦៣ | ៦២ | ១០០ |
| ២.៨ | គ្រូបង្រៀន | ១,៣៩៥ | ១,៤៣៤ | ១,៣៩៧ | ១០០.១ |
| ២.៩ | មេឃុំ ចៅសង្កាត់ | ១២៤ | ៩៦ | ៩៦ | ៧៧.៤ |
| ២.១០ | ប្រធានគណៈកម្មការគ្រប់គ្រងសាលា និងតំណាងអាណាព្យាបាលសិស្ស | ៦៩៨ | ៣៥០ | ៣៣៣ | ៤៧.៧ |
| | **សរុប** | **៣,០៩៤** | **២,៨០៥** | **២,៧២៨** | **៨៨.២%** |

## ៦. របកគំហើញនៃការសិក្សាទិន្នន័យដើមគ្រា

### ៦.១. ស្ថិតិ និងសូចនាករស្នូល ( EMIS ២០២២-២០២៣ )

ការសិក្សាទិន្នន័យ និងសូចនាករស្នូលនៃអនុវិស័យអប់រំទាំងបី ស្តីពីការអនុវត្តមុខងារការគ្រប់គ្រងការអប់រំកុមារតូច ការគ្រប់គ្រងការអប់រំបឋមសិក្សា និងការគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ ត្រូវបានដកស្រង់ចេញពីសូចនាករស្នូលក្នុងសៀវភៅស្ថិតិ និងសូចនាករអប់រំ ឆ្នាំសិក្សា២០២២-២០២៣ ដែលបានផ្តល់ព័ត៌មានជាមូលដ្ឋានអំពីស្ថានភាពសាលារៀនសាធារណៈ រួមមាន សាលាមត្តេយ្យសិក្សា និងសាលាបឋមសិក្សា។ ដោយឡែក សម្រាប់ការសិក្សាទិន្នន័យ និងសូចនាករអនុវិស័យអប់រំក្រៅប្រព័ន្ធ បានស្រង់ចេញពីទិន្នន័យសូចនាករការអប់រំក្រៅប្រព័ន្ធឆ្នាំសិក្សា២០២៣ ដែលផ្តល់ព័ត៌មានជាមូលដ្ឋានអំពីកម្មវិធីអក្ខរកម្ម ក្រោយអក្ខរកម្ម ចូលរៀនឡើងវិញ សមមូលបឋមសិក្សា បំពេញវិជ្ជា បង្កើនប្រាក់ចំណូល និងការងារមជ្ឈមណ្ឌលសិក្សាសហគមន៍របស់មន្ទីរអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍន៍។ សូចនាករស្នូលទាំងអស់នេះបានឆ្លុះបញ្ចាំងពីស្ថានភាពគុណភាពសេវាអប់រំ ដោយប្រៀបធៀបទៅនឹងស្ថានភាពមុនពេលផ្ទេរមុខងារអនុវិស័យអប់រំទាំងបីនោះ ពីមន្ទីរអប់រំ យុវជន និងកីឡា មកស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

#### ៦.១.១. ស្ថិតិ និងសូចនាករស្នូលសម្រាប់អនុវិស័យការអប់រំកុមារតូច

**តារាង ៦.១ ស្ថិតិ និងសូចនាករសម្រេចបានសម្រាប់អនុវិស័យការអប់រំកុមារតូច**

| លេខ | ស្ថិតិ និងសូចនាករ | ទិន្នន័យ ( EMIS ២០២២-២០២៣ ) | |
|---|---|---|---|
| | | គ្រោង | សម្រេច |
| សូចនាករ | | | |
| ១ | ភាគរយអត្រាចូលរៀនកុមារអាយុ៥ឆ្នាំ | ៦៣.១ | ៦៤.៨ |
| ២ | ភាគរយអត្រាចូលរៀនកុមារអាយុ៤ឆ្នាំ | ៣៦.៣ | ៣៤.២ |
| ៣ | អត្រាចូលរៀនកុមារអាយុ៣ឆ្នាំ | ១៤.១ | ១៤.២ |

| | | | |
|---|---|---|---|
| ៤ | អត្រារួមនៃការសិក្សា | ៣៧.៤ | ៣៧.១ |
| ៥ | ផលធៀបសិស្ស-គ្រូ | ៣៨.៥ | ៤៦.៣ |
| ៦ | ផលធៀបសិស្ស-ថ្នាក់រៀន | | ៣៥.៤ |
| ៧ | ផលធៀបសិស្ស-បន្ទប់ | | ៤៤.១ |
| **ស្ថិតិអប់រំ** | | | |
| ៨ | សាលារៀន | | ៤៦៣៤ |
| ៩ | បន្ទប់រៀន | | ៧៣៩៣ |
| ១០ | សិស្ស | សរុប | ២៥,៦៦៥៧ |
| | | ស្រី | ១២,៨៤៥៩ |
| ១១ | %សាលាមត្តេយ្យសិក្សាមានអគ្គិសនី (មត្តេយ្យសិក្សារដ្ឋ) | ៨១.៥ | ៨២.៣ |
| ១២ | % សាលាមត្តេយ្យសិក្សាមានកន្លែងលាងដៃ (មត្តេយ្យសិក្សារដ្ឋ) | ៩០.៤ | ៨២.៩ |
| ១៣ | %សាលាមត្តេយ្យសិក្សាមានទឹកស្អាត(មត្តេយ្យសិក្សារដ្ឋ) | ៨៣.៦ | ៧៨.៧ |
| ១៤ | % សាលាមត្តេយ្យសិក្សាមានបង្គន់អនាម័យ (មត្តេយ្យសិក្សារដ្ឋ) | ៨៩.៨ | ៩៩.៧ |
| ១៥ | % សាលាមត្តេយ្យសិក្សាមានប្រអប់សង្គ្រោះបឋម (មត្តេយ្យសិក្សារដ្ឋ) | ២១.៦ | ៣៨.៤ |
| ១៦ | % កុមារមានស្ថានភាពអាហារូបត្ថម្ភស្របតាមប័ណ្ណសុខភាពកុមារ | | ៥៥.២ |
| ១៧ | % គណៈគ្រប់គ្រងសាលារៀនមានគុណវុឌ្ឍិសមស្រប | | ៧៨.៨ |
| ១៨ | % គ្រូបង្រៀនមត្តេយ្យសិក្សាមានគុណវុឌ្ឍិសមស្រប (១២+២) | | ៧៣.៥ |
| ១៩ | ចំនួនគ្រូបង្រៀនពហុភាសា | ១២៥ | ១៣៣ |
| ២០ | ចំនួនគ្រូកិច្ចសន្យា | | ៨៨២ |

ផ្អែកតាមតារាង ៦.១ ស្ថិតិ និងសូចនាករសម្រេចបានខាងលើបានបង្ហាញឱ្យឃើញថា សេវាការអប់រំកុមារតូចត្រូវបានកែលម្អឥតឈប់ឈរ និងត្រូវបានលើកកម្ពស់គុណភាពជាបណ្តើរៗគួរឱ្យកត់សម្គាល់។

### ៦.១.២. ស្ថិតិ និងសូចនាករសាលាមត្តេយ្យដែលបានជាប់ក្នុងកម្មវិធីប្រឡងប្រណាំងសាលាមត្តេយ្យសិក្សាស្តង់ដាគំរូ (ឆ្នាំ២០២៣)

**តារាង ៦.២. សាលាមត្តេយ្យសិក្សាជាប់ក្នុងកម្មវិធី (មត្តេយ្យសិក្សាស្តង់ដាគំរូឆ្នាំ២០២៣)**

| រាជធានីខេត្ត | ក្រុង ស្រុក ខណ្ឌ | កម្មវិធីបសាលាមត្តយ្យស្តង់ដាគំរូ (សម្រាប់ឆ្នាំ២០២៣) |
|---|---|---|
| បន្ទាយមានជ័យ | ស្វាយចេក | សាលាមត្តេយ្យសិក្សាធនធានកកោះ |
| សៀមរាប | សៀមរាប | សាលាមត្តេយ្យសិក្សាធនធាន អង្គរ |
| | សូទ្រនិគម | សាលាមត្តេយ្យសិក្សាធនធានស្រុកសូទ្រនិគម |
| ស្វាយរៀង | ស្វាយរៀង | សាលាមត្តេយ្យសិក្សាធនធានកុមារថ្មី |
| បាត់ដំបង | ស្វាយប៉ោ | សាលាមត្តេយ្យសិក្សាធនធានក្រុងបាត់ដំបង |
| ព្រះវិហារ | ព្រះវិហារ | សាលាមត្តេយ្យសិក្សាធនធានក្រុងព្រះវិហារ |
| ក្រចះ | ក្រចេះ | សាលាមត្តេយ្យសិក្សាធនធាន ក្រចេះក្រុង |
| ព្រះសីហនុ | ព្រះសីហនុ | សាលាមត្តេយ្យសិក្សាធនធានក្រុង |
| ព្រៃវែង | ពារាំង | សាលាមត្តេយ្យសិក្សាធនធាន បណ្ឌិតតិថី លីណា ស្នាយពុល |
| កណ្ដាល | តាខ្មៅ | សាលាមត្តេយ្យសិក្សាធនធានក្រុងតាខ្មៅ |

ផ្អែកតាមតារាង ៦.២. ស្ថិតិ និងសូចនាករសម្រេចបានខាងលើបានបង្ហាញឱ្យឃើញថា **សាលាមត្តេយ្យ** សិក្សាដែលបានជាប់ក្នុងកម្មវិធីប្រឡងប្រណាំងផ្សេងៗ ប៉ុន្តែក្នុងនោះមានតែក្នុងកម្មវិធីសាលាមត្តេយ្យស្តង់ដាសិក្សាគំរូប៉ុណ្ណោះដែលបានជាប់សម្រាប់ឆ្នាំសិក្សា២០២៣។ សាលាសរុបចំនួន១០ ក្នុងនោះសាលាមត្តេយ្យសិក្សាមានស្តង់ដាពេញលេញ ០១សាលា មានស្តង់ដា ០៤សាលា និងស្តង់ដាអប្បបរមា ០៥សាលា។

### ៦.១.៣. ស្ថិតិ និងសូចនាករស្នូលសម្រាប់អនុវិស័យការអប់រំបឋមសិក្សា

**តារាង ៦.៣. ស្ថិតិ និងសូចនាករសម្រេចបានសម្រាប់អនុវិស័យអប់រំបឋមសិក្សា**

| លេខ | សូចនាករ | ទិន្នន័យ EMIS ឆ្នាំសិក្សា២០២២-២០២៣ | |
|---|---|---|---|
| | | ចំណុចដៅ | ជាក់ស្តែង |
| **សូចនាករអប់រំ** | | | |
| ១ | អត្រាពិតចូលរៀនថ្មី | ៨៩.៤០ | ៨៩.៨០ |
| ២ | អត្រាពិតនៃការសិក្សា | ៩៣.០ | ៩៥.៨០ |

| | | | |
|---|---|---|---|
| ៣ | អត្រាបោះបង់ការសិក្សា | ៦.២ | ៧.៥ |
| ៤ | អត្រាត្រួតថ្នាក់ | ៥.០ | ៥.៩ |
| ៥ | ចំនួនស្រុកដែលសម្រេចបានអត្រាត្រួតថ្នាក់នៅបឋមសិក្សាតិចជាងឬស្មើ ១០ភាគរយ | ១៧៦ | ១៦៨ |
| ៦ | អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា | ៨៨.៧ | ៨៦.៨ |
| ៧ | អត្រាគង់វង្សនៅបឋមសិក្សា | ៨១.៦ | ៨៩.៤ |
| ៨ | អត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិ | ៨៥.២ | ៨៣.៧ |
| **ស្ថិតិអប់រំ** | | | |
| ៩ | សាលារៀន | | ៧,៣៣៨ |
| ១០ | បន្ទប់រៀន | | ៤៧,០៣១ |
| ១១ | សិស្ស | ២,០៥៧,៦១២ | |
| ១២ | ភាគរយសិស្សថ្មីថ្នាក់ទី១ដែលបានឆ្លងកាត់មត្តេយ្យសិក្សា | ៧៧.៣ | ៦៩.៩ |
| ១៣ | ភាគរយសាលាកុមារមេត្រីកម្រិតមធ្យម និងកម្រិតអភិវឌ្ឍ | ៨២.២ | ៧៨.៣ |
| ១៤ | ភាគរយសាលាបឋមសិក្សាមានអគ្គិសនីប្រើប្រាស់ | ៨៧.៥ | ៨៣.៧ |
| ១៥ | ភាគរយសាលាបឋមសិក្សាអនុវត្តស្តង់ដាទឹកស្អាត និងអនាម័យ | | |
| | *កម្រិត១* | ៣៤.៥ | ១៥.៧ |
| | *កម្រិត២* | ៤០.១ | ២៩.៧ |
| | *កម្រិត៣* | ៤.៣ | ៤៧.៧ |
| ១៦ | ភាគរយសាលាបឋមសិក្សាមាន | | |
| | *បង្គន់អនាម័យ* | ១០០ | ៩៩.៩ |
| | *ទឹកស្អាតសម្រាប់ទទួលទាន* | | |
| | *កន្លែងលាងដៃ* | ៨១.៧ | ៨៥.៩ |
| | *ប្រអប់សង្គ្រោះបឋម* | ៥៨.៣ | ៥៧.៤ |
| ១៧ | ចំនួនសិស្សបឋមសិក្សាបានទទួលអាហារនៅតាមសាលារៀន | ១០១,៤០០ | ២៦៩,៨៣៨ |
| ១៨ | ចំនួនសិស្សទទួលអាហារូបករណ៍នៅបឋមសិក្សា | ១៤៩,៩៧០ | ១៤៨,៣៦២ |
| ១៩ | ចំនួនគ្រូបង្រៀនពហុភាសា | ២៤២ | ២៣៥ |
| ២០ | ចំនួនគ្រូបង្រៀនទទួលបានការបណ្តុះបណ្តាលកម្រិតឌីប្លូម៉ាស្តីពីការអប់រំពិសេសនៅវិទ្យាស្ថានអប់រំពិសេស | ២០ | ២៣ |
| ២១ | ផលធៀបសិស្ស-គ្រូ | ៣៩,៩ | ៤៤,៨ |

| | | | |
|---|---|---|---|
| ២២ | ភាគរយគ្រូបង្រៀនបឋមសិក្សាមានសញ្ញាបត្រតាមស្តង់ដា (សញ្ញាបត្រមធ្យម.ទុតិយភូមិ+២) | ៧៦,៥ | ៧៧,៨ |
| ២៣ | ចំនួនគ្រូបង្រៀនបឋមសិក្សាទទួលការបំប៉នសមត្ថភាពបន្ថែម | | |
| | *កញ្ចប់សម្ភារអំណានថ្នាក់ដំបូង* | ៣,៥០០ | ៣,៨៥៤ |
| | *កញ្ចប់សម្ភារគណិតវិទ្យាថ្នាក់ដំបូង* | ៣,៥០០ | ៣,១០០ |
| | *ការបំប៉នសមត្ថភាពផ្សេងទៀត* | ៣,០០០ | ៧,០០០ |
| ២៤ | ចំនួនគ្រូបង្រៀនបឋមសិក្សាដែលបានបញ្ចប់បរិញ្ញាបត្រនៅវិទ្យាស្ថានគរុកោសល្យ (១២+៤) | ២៩៧ | ២៩៧ |
| ២៥ | ភាគរយសិស្សបឋមសិក្សាទទួលបានសៀវភៅសិក្សាគោល ១ សម្រាប់ក្នុងម្នាក់ | ៩៩.១ | ១០០ |
| ២៦ | ចំនួនសាលាបឋមសិក្សាមានបន្ទប់កុំព្យូទ័រសម្រាប់សិស្ស | ២៥០ | ១៥៣ |
| ២៧ | ចំនួនសាលាបឋមសិក្សាមានបណ្ណាល័យតាមស្តង់ដា | ១,៨២៧ | ១,៥២៩ |
| ២៨ | ចំនួនសាលាបឋមសិក្សាអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនមានផ្ទះបាយ និងកន្លែងទទួលទានអាហារតាមស្តង់ដា | ១២ | ៨ |
| ២៩ | ចំនួននាយកបឋមសិក្សាបានទទួលការបំប៉នស្តីពីការគ្រប់គ្រងតាមសាលារៀន | ៥០០ | ២,៥២០ |
| ៣០ | ចំនួនសាលាបឋមសិក្សាអនុវត្តកម្មវិធីការគ្រប់គ្រងតាមសាលារៀន | ៥០០ | ១៧០០ |

ផ្អែកតាមតារាង ៦.៣ ស្ថិតិ និងសូចនាករសម្រេចបានខាងលើបានបង្ហាញឱ្យឃើញថា សេវាអប់រំបឋមសិក្សាត្រូវបានកែលម្អឥតឈប់ឈរ និងត្រូវបានលើកកម្ពស់គុណភាពជាបណ្តើរៗគួរឱ្យកត់សម្គាល់។

### ៦.១.៤. ស្ថិតិ និងសូចនាករសាលាបឋមសិក្សាដែលបានជាប់ក្នុងកម្មវិធីប្រឡងប្រណាំងផ្សេងៗ (ឆ្នាំ២០២៣)

**តារាង ៦.៤. សាលាបឋមសិក្សាដែលបានជាប់ក្នុងកម្មវិធីប្រឡងប្រណាំងផ្សេងៗ (ឆ្នាំ២០២២-២០២៣)**

| រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | សាលាបឋមសិក្សាដែលបានជាប់ក្នុងកម្មវិធីប្រឡងប្រណាំងផ្សេងៗ (ឆ្នាំ២០២២-២០២៣) | | | | | | |
|---|---|---|---|---|---|---|---|---|
| | | អង្គភាពផ្តល់សេវាគំរូ | សាលាកុមារមេត្រី | សាលារៀនស្អាត | សាលាមេត្រីបរិស្ថាន | សាលារៀនគំរូ | នាយកសាលាល្អ | គ្រូបង្រៀនល្អ |
| ភ្នំពេញ | ច្បារអំពៅ | ០ | ០ | ០ | ០ | ១ | ០ | ០ |
| | ដង្កោ | ០ | ០ | ០ | ០ | ០ | ០ | ០ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ដូនពេញ | ០ | ០ | ០ | ០ | ២ | ០ | ០ |
| សៀមរាប | ស្រីស្នំ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| | សៀមរាប | ១ | ០ | ០ | ០ | ៤ | ០ | ៣ |
| | អង្គរធំ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| | ស្វាយលើ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| | បន្ទាយស្រី | ០ | ០ | ០ | ០ | ០ | ០ | ០ |
| | សូទ្រនិគម | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ស្វាយរៀង | បាវិត | ០ | ០ | ០ | ០ | ០ | ០ | ០ |
| | រំដួល | ០ | ០ | ០ | ០ | ០ | ០ | ០ |
| | ស្វាយជ្រុំ | ១ | ០ | ០ | ០ | ១ | ០ | ០ |
| | ស្វាយរៀង | ០ | ០ | ១ | ០ | ០ | ០ | ០ |

ផ្អែកតាមតារាង ៦.៤ ស្ថិតិ និងសូចនាករសម្រេចបានខាងលើបានបង្ហាញឱ្យឃើញថា **សាលាបឋមសិក្សា**ដែលបានជាប់ក្នុងកម្មវិធីប្រឡងប្រណាំងផ្សេងៗក្នុងនោះមានរាជធានីខេត្តគោលដៅ និង ក្រុងស្រុកខណ្ឌាមួយចំនួនប៉ុណ្ណោះដែលបានជាប់ក្នុងកម្មវិធីប្រឡងប្រណាំងផ្សេងៗក្នុងនោះមានកម្មវិធីសាលារៀនគំរូ គ្រូបង្រៀនល្អ អង្គភាពផ្តល់សេវាគំរូ និងសាលារៀនស្អាត (សម្រាប់ឆ្នាំសិក្សា២០២២-២០២៣)។

### ៦.១.៥. ស្ថិតិ និងសូចនាករស្នូលសម្រាប់ការអប់រំក្រៅប្រព័ន្ធ

កម្មវិធីចំនួន០៧ ត្រូវបានអនុវត្តនៅក្នុងអនុវិស័យអប់រំក្រៅប្រព័ន្ធ រួមមានអក្ខរកម្មវិជ្ជាជីវៈ ក្រោយអក្ខរកម្ម ចូលរៀនឡើងវិញ បង្កើនប្រាក់ចំណូល សមមូលបឋមសិក្សា សមមូលមធ្យមសិក្សា និងកម្មវិធីបំពេញវិជ្ជា។

**តារាង ៦.៥. ចំនួនរាជធានី ខេត្តដែលបានអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធ ឆ្នាំសិក្សា២០២២-២០២៣**

| **សូចនាករអប់រំកម្មវិធីក្រៅប្រព័ន្ធ** | **ចំនួនរាជធានី ខេត្តដែលបានអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធ ឆ្នាំសិក្សា២០២២-២០២៣** | |
|---|---|---|
| | **ឆ្នាំសិក្សា២០២២** | **ឆ្នាំសិក្សា២០២៣** |
| អក្ខរកម្មវិជ្ជាជីវៈ | ២៥ | ២៥ |
| ក្រោយអក្ខរកម្ម | ១៥ | ១៥ |
| ចូលរៀនឡើងវិញ | ២១ | ១១ |
| បង្កើនប្រាក់ចំណូល | ២៥ | ២៥ |
| សមមូលបឋមសិក្សា | ២៤ | ២៥ |

| | | |
|---|---|---|
| សមមូលមធ្យមសិក្សាបឋមភូមិ | ៣ | ៦ |
| បំពេញវិជ្ជា | ១៨ | ១៩ |

*ប្រភព៖ សៀវភៅស្ថិតិនិងសូចនាករការអប់រំក្រៅប្រព័ន្ធ ឆ្នាំសិក្សា២០២២-២០២៣*

**តារាង ៦.៥.២. សូចនាករសំខាន់ដែលបានអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធ ឆ្នាំសិក្សា២០២២-២០២៣**

| ល.រ | សូចនាករ | ទិន្នន័យ (អប់រំក្រៅប្រព័ន្ធ ឆ្នាំ២០២២-២០២៣) | |
|---|---|---|---|
| | | គ្រោង | សម្រេច |
| ១ | ចំនួនប្រជាជនមិនចេះអក្សរបានបញ្ចប់ថ្នាក់អក្ខរកម្ម | ១៥,៧០០ | ១៥,៦០០ (ស្រី ៩,៨៩៧) |
| ២ | ចំនួនសិស្សចូលរៀនក្នុងកម្មវិធីសមមូល | ៧,៣៨៧ | ៨,៣១០ (ស្រី ៣៣,៣១) |
| ៣ | ចំនួនមជ្ឈមណ្ឌលសិក្សាសហគមន៍ដែលប្រែក្លាយជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត | ១៦ | ៣៣ |
| ៤ | ចំនួនកុមារបានបញ្ចប់កម្មវិធីចូលរៀនឡើងវិញ និងបានបញ្ជូនទៅក្នុងប្រព័ន្ធ | ៣,២៤៤ | ៤,៨១៦ (ស្រី ២,០៥២) |
| ៥ | ចំនួនអ្នកបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញមុខរបរងាយៗ | ៨,៦៩០ | ១០,២៣៩ (ស្រី ៧,២២៥) |
| ៦ | ចំនួនមន្ត្រីអប់រំក្រៅប្រព័ន្ធទទួលការបណ្តុះបណ្តាលលើការធ្វើផែនការ និងការគ្រប់គ្រងសេវាអប់រំក្រៅប្រព័ន្ធ | ១៣០ | ២០៣ (ស្រី ៣០) |

*ប្រភព៖ សៀវភៅស្ថិតិ និងសូចនាករការអប់រំក្រៅប្រព័ន្ធ ឆ្នាំសិក្សា២០២២-២០២៣*

## ៦.២. ទិន្នន័យដើមគ្រានៃការរកឃើញតាមរយៈការស្ទង់មតិ

ទិន្នន័យដែលទទួលបានពីការឆ្លើយតបរបស់ក្រុមគោលដៅទាំង១០ក្រុម នឹងត្រូវធ្វើការបកស្រាយ និងបង្ហាញដោយក្រាហ្វិចតាមចម្លើយនីមួយៗ ដូចខាងក្រោម៖

### ៦.២.១. ក្រុមគោលដៅទី១៖ ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ

#### ១. ការយល់ដឹងរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌអំពីគោលនយោបាយ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ

ផ្អែកតាមក្រាហ្វិក*៦.២.១.១.* បានបង្ហាញថា កម្រិតនៃការយល់ដឹងរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ចំនួន **៣៧នាក់** អំពីគោលនយោបាយ ផែនការយុទ្ធសាស្ត្រអនុវិស័យការអប់រំកុមារតូចមានចំនួន ២០% យល់ដឹងតិចតួច ៤៥.៧១% យល់ដឹងមធ្យម ២៨.៥៧% យល់ដឹងបង្គួរ និង ២.៨៥% យល់ដឹងពេញលេញ។ ចំពោះអនុវិស័យការអប់រំបឋមសិក្សាមានចំនួន ១០.៥២% យល់ដឹងតិចតួច ៤២.១០% យល់ដឹងមធ្យម

៣១.៥៧% យល់ដឹងបង្គួរ និង ៧.៨៨% យល់ដឹងពេញលេញ។ ដោយឡែក អនុវិស័យអប់រំក្រៅប្រព័ន្ធ មានចំនួន ១៣.៨៨% យល់ដឹងតិចតួច ៤៧.២២% យល់ដឹងមធ្យម ២២.២២% យល់ដឹងបង្គួរ និង ២.៧៧% យល់ដឹងពេញលេញ។

ជារួម យើងអាចធ្វើការកត់សម្គាល់ឃើញថា ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានការយល់ដឹងលើគោលនយោបាយ ផែនការយុទ្ធសាស្ត្រវិស័យអប់រំនៅមានកម្រិតនៅឡើយ។

ក្រាហ្វិក ៦.២.១.១. កម្រិតយល់ដឹងរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌលើគោលនយោបាយ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ




## ២. ការយល់ដឹងរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌអំពីគោលនយោបាយកំណែទម្រង់សាលារៀន នៃក្រសួងអប់រំ យុវជន និងកីឡា

ផ្អែកតាមក្រាហ្វិក *៦.២.១.២.* បានបង្ហាញថា កម្រិតនៃការយល់ដឹងរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ចំនួន **៣៣នាក់** ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងគោលនយោបាយកំណែទម្រង់សាលារៀនមត្តេយ្យសិក្សា មាន ចំនួន ៣០.៣០% យល់ដឹងតិចតួច ៣៣.៣៣% យល់ដឹងមធ្យម ២៧.២៧% យល់ដឹងបង្គួរ និង ៦.០៦% យល់ដឹងពេញលេញ។ ចំពោះកំណែទម្រង់សាលាបឋមសិក្សាមានចំនួន ២១.២១% យល់ដឹងតិចតួច ៤២.៤២% យល់ដឹងមធ្យម ២៤.២៤% យល់ដឹងបង្គួរ និង ៩.០៩% យល់ដឹងពេញលេញ។

ក្រាហ្វិក ៦.២.១.២. កម្រិតយល់ដឹងរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌលើគោលនយោបាយកំណែទម្រង់ សាលារៀនរបស់ក្រសួងអប់រំ យុវជន និងកីឡា



## ៣. ការយល់ដឹងរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌស្តីពីស្វ័យភាពលើកិច្ចការនានារបស់សាលារៀនមត្តេយ្យសិក្សា និងសាលាបឋមសិក្សា

ផ្អែកលើការឆ្លើយតបរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន **២៩នាក់** បានបង្ហាញថា កម្រិតនៃការយល់ដឹងរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌស្តីពីស្វ័យភាពលើកិច្ចការនានារបស់សាលារៀនមត្តេយ្យសិក្សា និងសាលាបឋមសិក្សាមានតែ ២៥% ប៉ុណ្ណោះ ដែលមានការយល់ដឹងតិចតួចអំពីស្វ័យភាពលើការគ្រប់គ្រងបុគ្គលិក ហិរញ្ញវត្ថុ និងការរៀបចំផែនការ ការគ្រប់គ្រងកុមារ ការរៀបចំតុបតែងក្នុងបរិវេណសាលា ការកែលម្អហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងអង្គភាពនានា និងការដឹកនាំ ចាត់ចែង ការរៀបចំបច្ចេកទេសបង្រៀន។ អ្វីដែលគួរកត់សម្គាល់នោះ គឺ ៧៥% បានលើកឡើងថាមិនបានដឹងអំពីស្វ័យភាពការងារនានារបស់សាលារៀនមត្តេយ្យសិក្សា និងសាលាបឋមសិក្សាឡើយ។

## ៤. រដ្ឋបាលក្រុង ស្រុក ខណ្ឌបានដាក់បញ្ចូលផែនការយុទ្ធសាស្ត្រវិស័យអប់រំ យុវជន និងកីឡាទៅក្នុងផែនការអភិវឌ្ឍន៍០៥ឆ្នាំ និង/ឬកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌនៅក្នុងឆ្នាំ២០២៣

ផ្អែកតាមការឆ្លើយតបរបស់ប្រធានក្រុមប្រឹក្សាចំនួន **៣០នាក់** បានបង្ហាញថា រដ្ឋបាលក្រុង ស្រុក ខណ្ឌបានដាក់បញ្ចូលផែនការយុទ្ធសាស្ត្រវិស័យអប់រំ យុវជន និងកីឡាទៅក្នុងផែនការអភិវឌ្ឍន៍០៥ឆ្នាំ និង/ឬកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌនៅឆ្នាំ២០២៣ ដែលមានលទ្ធផលដូចខាងក្រោម៖

- ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំឆ្នាំស្តីពីការអប់រំកុមារតូច មានចំនួន ៧៩.៤%
- ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំឆ្នាំស្តីពីការអប់រំបឋមសិក្សា មានចំនួន ៨២.៤%
- ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំឆ្នាំស្តីពីការងារអប់រំក្រៅប្រព័ន្ធ មានចំនួន ៦១.៨%
- ផែនការអភិវឌ្ឍន៍សាលារៀនសម្រាប់មត្តេយ្យសិក្សារដ្ឋ មានចំនួន ៦៤.៧%
- ផែនការអភិវឌ្ឍន៍សាលារៀនសម្រាប់បឋមសិក្សារដ្ឋ មានចំនួន ៦៤.៧%
- ផែនការអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀន មានចំនួន ៦១.៨%
- ផែនការតម្រូវការគ្រូបង្រៀនជាប់កិច្ចសន្យាក្នុងការងារអប់រំក្រៅប្រព័ន្ធ មានចំនួន ៥៥.៩%
- ផែនការអភិវឌ្ឍន៍មជ្ឈមណ្ឌលសិក្សាសហគមន៍/មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត មានចំនួន ២៦.៥%
- ផ្សេងទៀត មានចំនួន ៥.៩%។

ដូច្នេះ អាចធ្វើការសន្និដ្ឋានបានថា រដ្ឋបាលក្រុង ស្រុក ខណ្ឌបានផ្តោតការយកចិត្តទុកដាក់ខ្ពស់ក្នុងការអភិវឌ្ឍលើវិស័យអប់រំក្នុងមូលដ្ឋានរបស់ខ្លួន ជាពិសេសផ្តោតលើអនុវិស័យទាំងបី គឺការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ។

## ៥. រដ្ឋបាលក្រុង ស្រុក ខណ្ឌបានអនុវត្តផែនការដាក់ស្តែងនៅក្នុងឆ្នាំ២០២៣

ផ្អែកតាមក្រាហ្វិក*៦.២.១.៣.* ប្រធានក្រុមប្រឹក្សាចំនួន **៣៤នាក់** បានឆ្លើយថា រដ្ឋបាលក្រុង ស្រុក ខណ្ឌបានអនុវត្តផែនការនានាសម្រាប់អនុវិស័យទាំងបី ដែលមានលទ្ធផលដូចខាងក្រោម៖

- ការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំឆ្នាំស្តីពីការអប់រំកុមារតូចមានចំនួន ៣២.៥០% យល់ដឹងតិចតួច ៤២.៥០% យល់ដឹងមធ្យម ១៩.៤៣% យល់ដឹងបង្គួរ និង ៥.៥៧% យល់ដឹងពេញលេញ
- ការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំឆ្នាំស្តីពីការអប់រំបឋមសិក្សាមានចំនួន ៣៥% យល់ដឹងតិចតួច ៣៧.១៨% យល់ដឹងមធ្យម ២៥% យល់ដឹងបង្គួរ និង ២.៨២% យល់ដឹងពេញលេញ
- ការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំឆ្នាំស្តីពីការអប់រំក្រៅប្រព័ន្ធមានចំនួន ៣៨.៥៧% យល់ដឹងតិចតួច ៤៦.៦២% យល់ដឹងមធ្យម ៨.៨៩% យល់ដឹងបង្គួរ និង ៥.៩២% យល់ដឹងពេញលេញ
- ការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀនសម្រាប់មត្តេយ្យសិក្សារដ្ឋមានចំនួន ៣៩.៥៩% យល់ដឹងតិចតួច ៣២.១៣% យល់ដឹងមធ្យម ២៥.៥៧% យល់ដឹងបង្គួរ និង ៥.៧១% យល់ដឹងពេញលេញ
- ការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀនបឋមសិក្សារដ្ឋមានចំនួន ៣៧.១៦% យល់ដឹងតិចតួច ៣៤.២៨% យល់ដឹងមធ្យម ១៧.១៤% យល់ដឹងបង្គួរ និង ១១.៤២% យល់ដឹងពេញលេញ
- ការអនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀនមានចំនួន ៣១.៨៧% យល់ដឹងតិចតួច ៣៧.១៤% យល់ដឹងមធ្យម ២២.២៨% យល់ដឹងបង្គួរ និង ៨.៧១% យល់ដឹងពេញលេញ
- ការអនុវត្តផែនការតម្រូវការគ្រូបង្រៀនជាប់កិច្ចសន្យាក្នុងការងារអប់រំក្រៅប្រព័ន្ធមានចំនួន ៣៧.២៧% យល់ដឹងតិចតួច ៣៧.០៣% យល់ដឹងមធ្យម ១៤.២៨% យល់ដឹងបង្គួរ និង ១១.៤២% យល់ដឹងពេញលេញ
- ការអនុវត្តផែនការអភិវឌ្ឍន៍មជ្ឈមណ្ឌលសិក្សាសហគមន៍/មជ្ឈមណ្ឌលសិក្សាពេញមួយជីវិតមានចំនួន ៤១.២៥% យល់ដឹងតិចតួច ៣៨.៨៩% យល់ដឹងមធ្យម ១៥.៧២% យល់ដឹងបង្គួរ និង ៣.៨៤% យល់ដឹងពេញលេញ។

ក្រាហ្វិក ៦.២.១.៣. ក្រុង ស្រុក ខណ្ឌបានអនុវត្តផែនការជាក់ស្តែងក្នុងឆ្នាំ២០២៣



## ៦. ការយល់ដឹងរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌលើការដឹកនាំ គ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌអំពីមុខងារការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ

ផ្អែកតាមក្រាហ្វិក*៦.២.១.៤.* បានបង្ហាញថា ប្រធានក្រុមប្រឹក្សាចំនួន **៣២នាក់** មានភាពពេញចិត្តទៅនឹងការដឹកនាំ គ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌលើមុខងារការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ដែលមានដូចខាងក្រោម៖

(១) **ការអប់រំកុមារតូច៖** មានចំនួន ៣.៦២% មិនពេញចិត្តសោះ ៩.៣៧% ពេញចិត្តតិចតួច ៩.៣៧% ពេញចិត្តមធ្យម ៥៦.២៥% ពេញចិត្តបង្គួរ និង ១៥.១៥% ពេញចិត្តខ្លាំង

(២) **មុខងារអប់រំបឋមសិក្សា៖** មានចំនួន ៣.១៥% មិនពេញចិត្តសោះ ៦.២៥% ពេញចិត្តតិចតួច ៩.៣៧% ពេញចិត្តមធ្យម ៦២.៥០% ពេញចិត្តបង្គួរ និង ១៨.៧៥% ពេញចិត្តខ្លាំង

(៣) **មុខងារអប់រំក្រៅប្រព័ន្ធ៖** មានចំនួន ៣.១៥% មិនពេញចិត្តសោះ ១៥.៦២% ពេញចិត្តតិចតួច ១៨.៧៥% ពេញចិត្តមធ្យម ៥៣.១២% ពេញចិត្តបង្គួរ និង ១៥.៦២% ពេញចិត្តខ្លាំង

ជារួម អាចសន្និដ្ឋានបានថា ក្រុមប្រឹក្សាមានភាពពេញចិត្តជាបង្គួរលើការដឹកនាំ គ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌលើមុខងារអប់រំនៃអនុវិស័យទាំងបី។

ក្រាហ្វិក ៦.២.១.៤. កម្រិតយល់ឃើញក្នុងការគ្រប់គ្រង ចាត់ចែងរបស់ក្រុង ស្រុក ខណ្ឌលើមុខងារអប់រំទាំងបីអនុវិស័យ




## ៧. កត្តាដែលជាឧបសគ្គ ឬបញ្ហាប្រឈមដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តការងារលើមុខងារការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ

ផ្អែកតាមក្រាហ្វិក*៦.២.១.៥.* បានបង្ហាញថា ប្រធានក្រុមប្រឹក្សាចំនួន **៣២នាក់** បានលើកឡើងថា កត្តាដែលជាឧបសគ្គ ឬបញ្ហាប្រឈមរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តមុខងារការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ មានដូចខាងក្រោម៖

| កត្តាជាឧបសគ្គ ឬបញ្ហាប្រឈម | ការអប់រំកុមារតូច | ការអប់រំបឋមសិក្សា | អប់រំក្រៅប្រព័ន្ធ |
|---|---|---|---|
| ការគាំទ្របច្ចេកទេស | ៨៨.៣៣% | ៦៦.៦៦% | ៥០% |
| ការបែងចែកតួនាទី និងទំនួលខុសត្រូវ | ៥០% | ៧៣.៣៣% | ៤៦.៦៦% |

| | | | |
|---|---|---|---|
| ការងាររដ្ឋបាល និងខ្សែគណនេយ្យភាព | ៥០% | ៦០% | ៣៤.៣៧% |
| ធនធាន | ៤៣.៧៥% | ៥៦.២៥% | ៤៦.៦៦% |
| ការពិនិត្យតាមដាន | ៥៦.៦៦% | ៦០% | ៦០% |
| បញ្ហាផ្សេងៗ | | | |

ក្រាហ្វិក ៦.២.១.៥. កត្តាដែលជាឧបសគ្គ ឬបញ្ហាប្រឈមនានារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌលើមុខងារអប់រំទាំងបីអនុវិស័យ




## ៨. ការអន្តរាគមន៍របស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមក្នុងការអនុវត្តមុខងារនៃអនុវិស័យទាំងបី នាពេលកន្លងមក

ផ្អែកតាមការឆ្លើយតបរបស់ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន **៣១នាក់** បានបង្ហាញថា ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌបានខិតខំធ្វើអន្តរាគមន៍ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនានាក្នុងការអនុវត្តមុខងារក្នុងវិស័យអប់រំកន្លងមក តាមរយៈកិច្ចប្រជុំក្រុមប្រឹក្សា ប្រចាំខែ ដោយបានណែនាំដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌឱ្យបំពេញការងារ ដូចខាងក្រោម៖

- ត្រូវខិតខំផ្តល់ការណែនាំជាប្រចាំ និងផ្តល់ការបណ្តុះបណ្តាលបន្ថែមអំពីខ្លឹមសារអនុក្រឹត្យ សេចក្តីណែនាំ គោលការណ៍ និងនីតិវិធីនៃការអនុវត្ត និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដល់មន្ត្រីការិយាល័យអប់រំ យុវជន និងកីឡា នាយកសាលា គ្រូបង្រៀន និងអ្នកពាក់ព័ន្ធ
- ត្រូវពង្រឹងកិច្ចសហការរវាងគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងប្រធានការិយាល័យអប់រំ យុវជន និងកីឡា ក្នុងការស្វែងរកដំណោះស្រាយលើបញ្ហាប្រឈមនានាក្នុងការអនុវត្តមុខងារអប់រំ និងការគ្រប់គ្រងសាលារៀន
- ជំរុញឱ្យគ្រូបង្រៀនធ្វើការទំនាក់ទំនងជាមួយមាតាបិតាសិស្សរៀនយឺត សិស្សដែលមិនចូលរៀន សិស្សដែលមានបញ្ហានានា ដើម្បីស្វែងរកដំណោះស្រាយ និងជួយដល់សិស្សទាំងនោះឱ្យបានចូលរៀនឡើងវិញ
- ណែនាំដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌឱ្យចុះត្រួតពិនិត្យតាមដានជាប្រចាំនៅតាមសាលារៀន និងធ្វើការរាយការណ៍អំពីលទ្ធផលនៃការចុះត្រួតពិនិត្យតាមដាន នៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា
- ជំរុញការចូលរួមរបស់សហគមន៍មូលដ្ឋានក្នុងការគាំទ្រផ្នែកបច្ចេកទេស និងធនធាន ដើម្បីដោះស្រាយបញ្ហាជាតម្រូវការរបស់សាលារៀន។

ជារួមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌបានប្រើប្រាស់យន្តការកិច្ចប្រជុំរបស់ខ្លួនក្នុងការផ្តល់យោបល់ និងកំណត់ដាក់ចេញជាអនុសាសន៍ល្អៗ ដើម្បីបង្កើនការរីកចម្រើននៅក្នុងការអនុវត្តមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡា។

## ៩. យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌលើការអនុវត្តមុខងារការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ

ផ្អែកតាមក្រាហ្វិក *៦.២.១.៦.* បានបង្ហាញថា ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន **៤៣នាក់** បានលើកឡើងថា យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តមុខងារការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ មានចំនួន ៣០% តាមរយៈរបាយការណ៍ ៩០.៩៨% តាមរយៈកិច្ចប្រជុំក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ២២% តាមរយៈការចុះតាមដាន ត្រួតពិនិត្យ វាយតម្លៃ និង ១៦% តាមរយៈយន្តការត្រួតពិនិត្យផ្ទៃក្នុង។

ក្រាហ្វិក ៦.២.១.៦. យន្តការណ៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃរបស់ក្រុមប្រឹក្សា




ដូច្នេះអាចសន្និដ្ឋានបានថា យន្តការកិច្ចប្រជុំរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌដើរតួនាទីសំខាន់ណាស់ក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តមុខងារ ព្រមទាំងបានចូលរួមចំណែកដោះស្រាយបញ្ហាប្រឈមនានារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌលើការអនុវត្តមុខងារអប់រំទាំងបី នាពេលបច្ចុប្បន្ននេះ។

## ១០.ការគិតគូរ និងយកចិត្តទុកដាក់របស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌទៅលើកុមារ និងប្រជាជនដែលជាជនជាតិដើមភាគតិច ជនមានពិការភាព និងជនងាយរងគ្រោះនៅក្នុងដំណើរការកសាងផែនការ និងការអនុវត្តមុខងារការអប់រំនៃអនុវិស័យទាំងបី នាពេលកន្លងមក

ផ្អែកតាមក្រាហ្វិក*៦.២.១.៧.* បានបង្ហាញថា ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន **៣២នាក់** បានលើកឡើងថា មានការគិតគូរខ្ពស់ទៅលើកុមារ និងប្រជាជនដែលជាជនជាតិដើមភាគតិច ជនមានពិការភាព ជនងាយរងគ្រោះនៅក្នុងដំណើរការកសាងផែនការ និងអនុវត្តមុខងារអប់រំនៃអនុវិស័យទាំងបី មានមតិលើកឡើងថា៖ ចំនួន ៨៤.៤០% បានគិតគូរ និងចំនួន ១៥.៦០% មិនបានគិតគូរ។

ក្រាហ្វិក ៦.២.១.៧. កម្រិតយកចិត្តទុកដាក់របស់ក្រុមប្រឹក្សាទៅលើជនងាយរងគ្រោះ ក្នុងដំណើរការអនុម័តផែនការ និងអនុវត្តមុខងារអប់រំទាំងបីអនុវិស័យ



### ៦.២.២. ក្រុមអ្នកផ្តល់ព័ត៌មានជាអភិបាល ឬអភិបាលរងទទួលបន្ទុកការងារអប់រំក្រុង ស្រុក ខណ្ឌ

**១. ការយល់ដឹងអំពីគោលនយោបាយ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ**

ផ្អែកតាមក្រាហ្វិក *៦.២.២.១.* បានបង្ហាញថា កម្រិតនៃការយល់ដឹងរបស់គណៈអភិបាលក្រុង ស្រុក ខណ្ឌចំនួន **៣១នាក់** អំពីគោលនយោបាយ ផែនការយុទ្ធសាស្ត្រគ្រប់គ្រងកុមារតូចមានចំនួន ១៦.៦៦% យល់ដឹងតិចតួច ៥៦.៦៦% យល់ដឹងមធ្យម ២០% យល់ដឹងបង្គួរ និង ០% យល់ដឹងពេញលេញ។ ចំពោះការងារគ្រប់គ្រងការអប់រំបឋមសិក្សាមានចំនួន ១៣.៣៣% យល់ដឹងតិចតួច ៥៦.៦៦% យល់ដឹងមធ្យម ៣៣.៣៣% យល់ដឹងបង្គួរ និង ០% យល់ដឹងពេញលេញ។ ដោយឡែក ការអប់រំក្រៅប្រព័ន្ធមានចំនួន ៣៣.៣៣% យល់ដឹងតិចតួច ៤៦.៦៦% យល់ដឹងមធ្យម ៣៦.៦៦% យល់ដឹងបង្គួរ និង ០% យល់ដឹងពេញលេញ។

ជារួម យើងអាចធ្វើការកត់សម្គាល់ឃើញថា គណៈអភិបាលក្រុង ស្រុក ខណ្ឌមានការយល់ដឹងលើគោលនយោបាយ ផែនការយុទ្ធសាស្ត្រវិស័យអប់រំនៅមានកម្រិតនៅឡើយ។

ក្រាហ្វិក ៦.២.២.១. កម្រិតយល់ដឹងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌស្តីពីគោលនយោបាយផែនការយុទ្ធសាស្ត្រ




**២. ការយល់ដឹងរបស់គណៈអភិបាលក្រុង ស្រុក ខណ្ឌស្តីពីគោលនយោបាយកំណែទម្រង់សាលារៀនរបស់ក្រសួងអប់រំ យុវជន និងកីឡា**

ផ្អែកតាមក្រាហ្វិក *៦.២.២.២.* បានបង្ហាញថា កម្រិតនៃការយល់ដឹងរបស់គណៈអភិបាលក្រុង ស្រុក ខណ្ឌចំនួន **៣១នាក់** ចំពោះគោលនយោបាយកំណែទម្រង់សាលារៀនមត្តេយ្យសិក្សា (ស្តង់ដាសាលារៀនគំរូ) មានចំនួន ១០.៣៤% យល់ដឹងតិចតួច ៤១.៣៧% យល់ដឹងមធ្យម ៣៨% យល់ដឹងបង្គួរ និង ៧% យល់ដឹងពេញលេញ។ ចំពោះគោលនយោបាយកំណែទម្រង់សាលាបឋមសិក្សា (សាលារៀនជំនាន់ថ្មី) មានចំនួន ២៥.៩២% យល់ដឹងតិចតួច ៥១.៨៥% យល់ដឹងមធ្យម ១៨.៥១% យល់ដឹងបង្គួរ និង ៥% យល់ដឹងពេញលេញ។ ចំណែកគោលនយោបាយកំណែទម្រង់សាលាបឋមសិក្សា (ស្តង់ដាសាលាបឋមសិក្សាគំរូ) មានចំនួន ១៧.២៤% យល់ដឹងតិចតួច ៣១.០៣% យល់ដឹងមធ្យម ៤១.៣៧% យល់ដឹងបង្គួរ និង ៧% យល់ដឹងពេញលេញ។

ក្រាហ្វិក ៦.២.២.២. កម្រិតយល់ដឹងពីគោលនយោបាយកំណែទម្រង់សាលារៀន




### ៣. ការយល់ដឹងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌអំពីស្វ័យភាពការងាររបស់សាលាមត្តេយ្យសិក្សា និងសាលារៀនបឋមសិក្សា

ផ្អែកលើការឆ្លើយតបរបស់គណៈអភិបាលក្រុង ស្រុក ខណ្ឌចំនួន **២២នាក់** បានបង្ហាញថា កម្រិតនៃការយល់ដឹងរបស់គណៈអភិបាលក្រុង ស្រុក ខណ្ឌស្តីពីស្វ័យភាពលើកិច្ចការនានារបស់សាលារៀនមត្តេយ្យសិក្សា និងសាលាបឋមសិក្សា មានមតិលើកឡើងថា ៣៦.៣៦% មិនបានដឹង និង ៦៣.៦៤% បានដឹងអំពីស្វ័យភាពលើកិច្ចការនានារបស់សាលាមេត្តយ្យសិក្សា និងបឋមសិក្សាដែលរួមមាន ៖ ការគ្រប់គ្រងបុគ្គលិក ហិរញ្ញវត្ថុ និងការរៀបចំផែនការ ការគ្រប់គ្រងកុមារ ការរៀបចំតុបតែងក្នុងបរិវេណសាលារៀន ការកែលម្អហេដ្ឋាសម្ព័ន្ធសាលារៀន និងអង្គភាពនានា និងការដឹកនាំចាត់ចែង ការរៀបចំបច្ចេកទេសបង្រៀន។

### ៤. រដ្ឋបាលក្រុង ស្រុក ខណ្ឌបានដាក់បញ្ចូលផែនការយុទ្ធសាស្ត្រវិស័យអប់រំទៅក្នុងផែនការអភិវឌ្ឍន៍០៥ឆ្នាំ និង/ឬកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌនៅក្នុងឆ្នាំ២០២៣

ផ្អែកតាមការឆ្លើយតបរបស់គណៈអភិបាលក្រុង ស្រុក ខណ្ឌចំនួន **២៤នាក់** បានបង្ហាញថា រដ្ឋបាលក្រុង ស្រុក ខណ្ឌបានដាក់បញ្ចូលផែនការយុទ្ធសាស្ត្រវិស័យអប់រំ យុវជន និងកីឡាទៅក្នុងផែនការអភិវឌ្ឍន៍ ០៥ឆ្នាំ ឬកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌនៅឆ្នាំ២០២៣ ដែលមានលទ្ធផលដូចខាងក្រោម៖

- ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំឆ្នាំស្តីពីការអប់រំកុមារតូចមានចំនួន ៨១.៨០%
- ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំឆ្នាំស្តីពីការអប់រំបឋមសិក្សាមានចំនួន ៨១.៨០%
- ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំឆ្នាំស្តីពីការងារអប់រំក្រៅប្រព័ន្ធមានចំនួន ៦៣.៦០%
- ផែនការអភិវឌ្ឍន៍សាលាមត្តេយ្យសិក្សារដ្ឋមានចំនួន ៦៣.៦០%
- ផែនការអភិវឌ្ឍន៍សាលារៀនសម្រាប់សាលាបឋមសិក្សារដ្ឋមានចំនួន ៦៨.២០%
- ផែនការអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀនមានចំនួន ៥៤.៥០%
- ផែនការតម្រូវការគ្រូបង្រៀនជាប់កិច្ចសន្យាក្នុងការងារអប់រំក្រៅប្រព័ន្ធមានចំនួន ៥០%

- ផែនការអភិវឌ្ឍន៍មជ្ឈមណ្ឌលសិក្សាសហគមន៍/មជ្ឈមណ្ឌលសិក្សាពេញមួយជីវិតមានចំនួន ៩០.៩០%។

## ៥. ការអន្តរាគមន៍នានារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌលើការងារគ្រប់គ្រងបុគ្គលិកអប់រំ

ផ្អែកតាមតារាង *៦.២.២.១* គណៈអភិបាលក្រុង ស្រុក ខណ្ឌចំនួន **៣១នាក់** បានលើកឡើងថា រដ្ឋបាលក្រុង ស្រុក ខណ្ឌបានអន្តរាគមន៍នានាលើការគ្រប់គ្រងបុគ្គលិកអប់រំ ដូចក្នុងតារាងខាងក្រោម៖

**តារាង *៦.២.២.១* ការអន្តរាគមន៍លើការងារគ្រប់គ្រងបុគ្គលិកអប់រំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ**

| ល.រ | ការងារគ្រប់គ្រងបុគ្គលិកអប់រំ | មិនបាន (ភាគរយ) | បាន (ភាគរយ) |
|---|---|---|---|
| ១ | ការរៀបចំផែនការជ្រើសរើសបុគ្គលិកក្របខ័ណ្ឌ និងបុគ្គលិកកិច្ចសន្យា | ៧២.៧២ | ២៨.២៨ |
| ២ | ការជ្រើសរើសបុគ្គលិកកិច្ចសន្យា | ២៨.២៨ | ៧២.៧២ |
| ៣ | ការបំពេញសាលាកបត្រព័ត៌មានមន្ត្រីរាជការស៊ីវិល និងការធ្វើកម្មសិក្សា | ៣៦.៣៧ | ៦៣.៦៣ |
| ៤ | ការតាំងស៊ប់ក្នុងក្របខ័ណ្ឌ | ៥០ | ៥០ |
| ៥ | ការដំឡើងថ្នាក់ និង/ឬឋានន្តរស័ក្តិ | ៨១.៨១ | ១៩.១៩ |
| ៦ | ការតែងតាំង និងការបញ្ចប់មុខតំណែង | ៩.១០ | ៩០.៩០ |
| ៧ | ការបញ្ចប់មុខតំណែង | ៥៦.៨២ | ៤៣.១៨ |
| ៨ | ការផ្ទេរ និងការផ្លាស់ប្តូរកន្លែងធ្វើការ | ៩០.៩០ | ៩.១០ |
| ៩ | ការដាក់ឱ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម ឬដាក់ឱ្យនៅក្រៅតំណែង | ៩០.៩ | ៩.១០ |
| ១០ | ការដាក់ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស | ៧២.៧២ | ២៧.២៨ |
| ១១ | ការផ្អាកការងារដោយផ្អាកបៀវត្ស | ៧០ | ៣០ |
| ១២ | ការឈប់សម្រាកពីការងារ បំពេញការសិក្សា វគ្គបណ្តុះបណ្តាល បេសកកម្មក្នុង និងក្រៅប្រទេស | ៨៦.៣៦ | ២៣.៦៤ |
| ១៣ | ការដាក់ឱ្យចូលនិវត្តន៍ និងការដាក់ឱ្យបាត់បង់សម្បទាវិជ្ជាជីវៈ | ៩០.៩០ | ៩.១០ |
| ១៤ | ការស្នើសុំលាឈប់ពីការងាររាជការ | ៦៨.១០ | ៣១.៩៩ |
| ១៥ | ការលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌមុខងារសាធារណៈ | ៩៥.៤៥ | ៤.៥៥ |
| ១៦ | ការអនុញ្ញាត និងការទទួលបុគ្គលិកឱ្យចូលបម្រើការងារក្នុងអង្គភាពដើមវិញ | ៩៥.០៩ | ៩.៩១ |
| ១៧ | មន្ត្រីរាជការដែលស្ថិតក្នុងនីតិវិធីចោទប្រកាន់តាមផ្លូវតុលាការ | ៩៥.៤៥ | ៤.៥៥ |
| ១៨ | ការដាក់វិន័យ | ៩០.០៩ | ៩.៩១ |

## ៦. ការគាំទ្រ និងអន្តរាគមន៍របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌលើការងាររបស់សាលារៀន

មតិរបស់គណៈអភិបាលក្រុង ស្រុក ខណ្ឌចំនួន **៣១នាក់** បានលើកឡើងថា រដ្ឋបាលក្រុង ស្រុក ខណ្ឌបានអន្តរាគមន៍លើការងាររបស់សាលារៀន ដូចខាងក្រោម៖

### ក. ការគ្រប់គ្រងសិស្ស

ផ្អែកតាមក្រាហ្វិក *៦.២.២.៣.* បានបង្ហាញថា៖

- ការគ្រប់គ្រងទិន្នន័យកុមារដល់វ័យសិក្សា មានមតិចំនួន ២៤% លើកឡើងថាមិនបានគាំទ្រ និង ៧៦% លើកឡើងថាបានគាំទ្រ
- យុទ្ធនាការប្រមូលកុមារចូលរៀន មានមតិចំនួន ២៨% លើកឡើងថាមិនបានគាំទ្រ និង ៧២% លើកឡើងថាបានគាំទ្រ
- ការជួយកុមារ សិស្សជួបការលំបាក ឬបោះបង់ការសិក្សា មានមតិចំនួន ២៨% លើកឡើងថាមិនបានគាំទ្រ និង ៧២% លើកឡើងថាបានគាំទ្រ។

ក្រាហ្វិក ៦.២.២.៣. ការគ្រប់គ្រងសិស្ស




### ខ. ការងារគ្រប់គ្រងគ្រូបង្រៀន

ផ្អែកតាមក្រាហ្វិក *៦.២.២.៤.* បានបង្ហាញថា៖

- ការបំពេញការងាររបស់គ្រូបង្រៀន (វត្តមាន) មានមតិចំនួន ៣៦% លើកឡើងថា មិនបានគាំទ្រ និង ៦៤% លើកឡើងថាបានគាំទ្រ
- ការគ្រប់គ្រងទិន្នន័យគ្រូបង្រៀន (លើសឬខ្វះ) មានមតិចំនួន ៤១% លើកឡើងថាមិនបានគាំទ្រ និង ៥៩% លើកឡើងថាបានគាំទ្រ
- ការជួយគ្រូបង្រៀន (សម្រាប់គ្រូបង្រៀនចេញថ្មី និងគ្រូបង្រៀនជួបការលំបាក) មានមតិចំនួន ៥៩% លើកឡើងថាមិនបានគាំទ្រ និង ៤១% លើកឡើងថាបានគាំទ្រ។

ក្រាហ្វិក ៦.២.២.៤. ការងារគ្រប់គ្រងគ្រូបង្រៀន




**គ. ការងារផែនការហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់សាលារៀន**

ផ្អែកតាមក្រាហ្វិក *៦.២.២.៥.* បានបង្ហាញថា៖

- ការចូលរួមធ្វើផែនការផ្សេងៗនៅតាមសាលារៀន មានមតិចំនួន ៥៧% លើកឡើងថាមិនបានគាំទ្រ និង ៤៣% លើកឡើងថាបានគាំទ្រ
- ការពិនិត្យតាមដានការប្រើប្រាស់ថវិកាមូលនិធិដំណើរការសាលារៀន មានមតិចំនួន ៤៦% លើកឡើងថា មិនបានគាំទ្រ និង ៥៤% លើកឡើងថា បានគាំទ្រ
- ការពិនិត្យតាមដានការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិរបស់សាលារៀន មានមតិចំនួន ៤១% លើកឡើងថា មិនបានគាំទ្រ និង ៥៩% លើកឡើងថា បានគាំទ្រ
- ការធ្វើរបាយការណ៍ជូនអ្នកពាក់ព័ន្ធ មានមតិចំនួន ៤៣% លើកឡើងថា មិនបានគាំទ្រ និង ៥៧% លើកឡើងថា បានគាំទ្រ
- ការអនុវត្តស្តង់ដាសាលារៀនគំរូ មានមតិចំនួន ៣៨% លើកឡើងថា មិនបានគាំទ្រ និង ៦២% លើកឡើងថា បានគាំទ្រ។

ក្រាហ្វិក ៦.២.២.៥ ការងារផែនការហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់សាលារៀន



### ឃ. ការងារផ្សេងទៀត

ផ្អែកលើការឆ្លើយតបក្នុងក្រាហ្វិក *៦.២.២.៦* បានបង្ហាញថា ៖

- ការកៀគរធនធានសម្រាប់អភិវឌ្ឍសាលារៀន មានមតិចំនួន ៤% លើកឡើងថា មិនបានគាំទ្រ និង ៩៦% លើកឡើងថា បានគាំទ្រ
- ការងារបរិស្ថាន មានមតិចំនួន ១០០% លើកឡើងថា បានគាំទ្រ
- ហេដ្ឋារចនាសម្ព័ន្ធនានារបស់សាលារៀន មានមតិចំនួន ១៩% លើកឡើងថា មិនបានគាំទ្រ និង ៨១% លើកឡើងថា បានគាំទ្រ
- ការងារអប់រំកាយ និងកីឡា មានមតិចំនួន ១៩% លើកឡើងថា មិនបានគាំទ្រ និង ៨១% លើកឡើងថា បានគាំទ្រ
- ការងារក្រុមប្រឹក្សាកុមារ មានមតិចំនួន ៥៦% លើកឡើងថា មិនបានគាំទ្រ និង ៤៤% លើកឡើងថា បានគាំទ្រ
- ការចូលរួមជាគណៈកម្មការនានារបស់សាលារៀន មានមតិចំនួន ៣០% លើកឡើងថា មិនបានគាំទ្រ និង៧០% លើកឡើងថាបានគាំទ្រ
- ការទប់ស្កាត់បាតុភាពអសកម្មនានារបស់សាលារៀន (សន្តិសុខ គ្រឿងញៀន សុខភាពអនាម័យ ល្បែងស៊ីសង) មានមតិចំនួន ៤% លើកឡើងថា មិនបានគាំទ្រ និង ៩៦% លើកឡើងថា បានគាំទ្រ
- ការរៀបចំគណៈកម្មការគ្រប់គ្រងសាលារៀន មានមតិចំនួន ២៩% លើកឡើងថា មិនបាន គាំទ្រ និង ៧១% លើកឡើងថាបានគាំទ្រ។

ក្រាហ្វិក ៦.២.២.៦ ការងារផ្សេងទៀត



## ៧. ការរៀបចំរបាយការណ៍សមិទ្ធិកម្មការងារអប់រំកម្រិតក្រុង ស្រុក ខណ្ឌ និងបានដាក់បញ្ចូលក្នុងរបាយការណ៍សន្និបាតអប់រំនៅថ្នាក់រាជធានីខេត្ត

ផ្អែកតាមក្រាហ្វិក *៦.២.២.៧.* បានបង្ហាញថា គណៈអភិបាលក្រុង ស្រុក ខណ្ឌចំនួន **៣១នាក់** បានលើកឡើងថា របាយការណ៍សមិទ្ធកម្មការងារអប់រំកម្រិតក្រុង ស្រុក ខណ្ឌត្រូវបានរៀបចំ និងបានដាក់បញ្ចូលក្នុងរបាយការណ៍សន្និបាតអប់រំនៅថ្នាក់រាជធានី ខេត្ត មានចំនួន ៥៥.៦% បានដាក់បញ្ចូល និង ៤៤.៤% មិនបានដាក់បញ្ចូល។

*ក្រាហ្វិក ៦.២.២.៧*




## ៨. ការអនុវត្តផែនការដាក់ស្តែងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌនៅក្នុងឆ្នាំ២០២៣

ផ្អែកតាម**ក្រាហ្វិក***៦.២.២.៨* បានបង្ហាញថា គណៈអភិបាលក្រុង ស្រុក ខណ្ឌចំនួន **២៧នាក់** បានលើកឡើងថា រដ្ឋបាលក្រុង ស្រុក ខណ្ឌ បានអនុវត្តផែនការដាក់ស្តែងក្នុងឆ្នាំ២០២៣ ដែលមានលទ្ធផលដូចខាងក្រោម៖

- ការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំឆ្នាំស្តីពីការអប់រំកុមារតូច មានចំនួន ៣៤% បានតិចតួច ៤១% មធ្យម ២២% បានបង្គួរ និង ៣% បានពេញលេញ
- ការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំឆ្នាំស្តីពីការអប់រំបឋមសិក្សា មានចំនួន ៤១% បានតិចតួច ៣៩% មធ្យម ១៧% បានបង្គួរ និង ៣% បានពេញលេញ
- ការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំឆ្នាំស្តីពីការអប់រំក្រៅប្រព័ន្ធ មានចំនួន ៥៥% បានតិចតួច ២៥% មធ្យម ១៧% បានបង្គួរ និង ៣% បានពេញលេញ
- ការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀនសម្រាប់សាលាបឋមសិក្សារដ្ឋ មានចំនួន ៤៥% បានតិចតួច ៣៥% មធ្យម ១៧% បានបង្គួរ និង៣% បានពេញលេញ
- ការអនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀន មានចំនួន ៣៦% បានតិចតួច ៤៣% មធ្យម ១៨% បានបង្គួរ និង ៤% បានពេញលេញ
- ការអនុវត្តផែនការតម្រូវការគ្រូបង្រៀនជាប់កិច្ចសន្យាក្នុងការងារអប់រំក្រៅប្រព័ន្ធ មានចំនួន ៥៧% បានតិចតួច ២៥% មធ្យម ១៤% បានបង្គួរ និង ៤% បានពេញលេញ
- ការអនុវត្តផែនការអភិវឌ្ឍន៍មជ្ឈមណ្ឌលសិក្សាសហគមន៍/មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត មានចំនួន ៥២% បានតិចតួច ២៧% មធ្យម ១៤% បានបង្គួរ និង ៧% បានពេញលេញ។

ក្រាហ្វិក ៦.២.២.៨ ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំទាំងបីអនុវិស័យ




## ៩. រដ្ឋបាលក្រុង ស្រុក ខណ្ឌបានគាំទ្រ និងអន្តរាគមន៍លើកម្មវិធីនៃការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ

ផ្អែកតាមតារាង *៦.២.២.២* អ្នកផ្តល់ព័ត៌មានជាអភិបាលក្រុង ស្រុក ខណ្ឌចំនួន **៣៣នាក់** បានលើកឡើងថា បានខិតខំអន្តរាគមន៍ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនានាក្នុងការអនុវត្តមុខងារអប់រំនាពេលកន្លងមក ដូចមាននៅក្នុងតារាង *៦.២.២.២* ខាងក្រោម៖

**តារាង *៦.២.២.២* ការអន្តរាគមន៍របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីដោះស្រាយបញ្ហានានាក្នុងការអនុវត្តមុខងារអប់រំកន្លងមក**

| ល.រ. | មុខងាររង/សកម្មភាព | មិនបាន (ភាគរយ) | បានតិចតួច (ភាគរយ) | បានមធ្យម (ភាគរយ) | បានបង្គួរ (ភាគរយ) | បានច្រើន (ភាគរយ) |
|---|---|---|---|---|---|---|
| **ការគ្រប់គ្រងការអប់រំកុមារតូច** | | | | | | |
| ១ | ការគ្រប់គ្រងកម្មវិធីមត្តេយ្យសិក្សារដ្ឋ | ២៨ | ៣០ | ២០ | ១១ | ១១ |
| ២ | កម្មវិធីអប់រំបរិយាបន្ន និងកម្មវិធីពហុភាសា | ៦៨ | ២៤ | ២ | ២ | ៤ |
| ៣ | កម្មវិធីអាហារូបត្ថម្ភ | ៣៧ | ៣០ | ១០ | ២០ | ៣ |
| ៤ | កម្មវិធីជួយកុមារក្រីក្រតាមសាលា | ២៧ | ២៧ | ២២ | ២ | ២២ |
| ៥ | កម្មវិធីអប់រំមាតាបិតា ផ្សារភ្ជាប់នឹងកម្មវិធីមត្តេយ្យសិក្សារដ្ឋ | ២៥ | ៤៨ | ៩ | ៩ | ៩ |

| | | | | | | |
|---|---|---|---|---|---|---|
| **ការអប់រំបឋមសិក្សា** | | | | | | |
| ១ | កម្មវិធីអប់រំពហុភាសា | ៦២ | ២៥ | ៨ | ០ | ៥ |
| ២ | កម្មវិធីពន្លឿនការសិក្សា | ៤៨ | ២៦ | ២០ | ១ | ៣ |
| ៣ | កម្មវិធីផ្តល់អាហារតាមសាលារៀន | ៥២ | ២៦ | ៥ | ៥ | ២ |
| ៤ | កម្មវិធីអប់រំពិសេស | ៦២ | ២៥ | ៦ | ៦ | ២.៥០ |
| ៥ | កម្មវិធីអាហារូបករណ៍សិស្សក្រីក្រ | ៣០ | ៣៦ | ២០ | ១០ | ៤ |
| ៦ | កម្មវិធីអប់រំសុខភាព និងអនាម័យ | ១២ | ៣២ | ២០ | ៨ | ២៨ |
| ៧ | ការងារក្រុមប្រឹក្សាកុមារ | ៤៨ | ៤០ | ៨ | ០ | ១២ |
| ៨ | ការអប់រំកាយ និងកីឡា | ១៦ | ៤០ | ២០ | ៤ | ២០ |
| **ការអប់រំក្រៅប្រព័ន្ធ និងបរិយាបន្ន** | | | | | | |
| ៩ | ការប្រមូល ការគ្រប់គ្រងសិស្ស អ្នកសិក្សា និងអ្នកចូលរួម | ៤០ | ៤៨ | ៨ | ០ | ៤ |
| ១០ | កម្មវិធីអក្ខរកម្មវិជ្ជាជីវៈ | ៤៨ | ២៨ | ១២ | ៤ | ៨ |
| ១១ | កម្មវិធីក្រោយអក្ខរកម្ម | ៤៨ | ២៤ | ១២ | ៨ | ៨ |
| ១២ | កម្មវិធីសមមូលបឋមសិក្សា | ៦០ | ២០ | ១២ | ៤ | ៤ |
| ១៣ | កម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិ | ៦៤ | ២០ | ៨ | ០ | ៨ |
| ១៤ | កម្មវិធីបំពេញវិជ្ជា | ៥២ | ២០ | ១២ | ៤ | ១២ |
| ១៥ | កម្មវិធីបង្កើនប្រាក់ចំណូល | ៣៦ | ២៨ | ២៤ | ៤ | ៨ |
| ១៦ | កម្មវិធីចូលរៀនឡើងវិញ | ៤៨ | ២៨ | ១២ | ៤ | ៨ |

## ១០. ការពេញចិត្តរបស់គណៈអភិបាលលើគុណភាពសេវាអប់រំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

ផ្អែកតាមក្រាហ្វិក *៦.២.២.៩* បានបង្ហាញថា គណៈអភិបាលក្រុង ស្រុក ខណ្ឌចំនួន **២៧នាក់** បានលើកឡើងថា គុណភាពនៃការផ្តល់សេវាអប់រំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ មានដូចខាងក្រោម៖

- **ការអប់រំកុមារតូច៖** មានចំនួន ៧% មិនពេញចិត្តសោះ ២៤% ពេញចិត្តតិចតួច ៥២% ពេញចិត្តធម្មតា និង ១៧% ពេញចិត្តខ្លាំង
- **ការអប់រំបឋមសិក្សា៖** មានចំនួន ៣% មិនពេញចិត្តសោះ ៣១% ពេញតិចតួច ៤៨% ពេញចិត្តមធ្យម និង ១៧% ពេញចិត្តខ្លាំង
- **ការអប់រំក្រៅប្រព័ន្ធ៖** មានចំនួន ១០% មិនពេញចិត្តសោះ ២៨% ពេញចិត្តតិចតួច ៤៥% ពេញចិត្តមធ្យម និង ១៧% ពេញចិត្តខ្លាំង។

ក្រាហ្វិក ៦.២.២.៩ កម្រិតពេញចិត្តលើគុណភាពសេវាអប់រំទាំងបីអនុវិស័យ




## ១១. កត្តាឧបសគ្គ ឬបញ្ហាប្រឈមនានារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តមុខងារអប់រំនៃអនុវិស័យទាំងបី នាពេលបច្ចុប្បន្ន

ផ្អែកតាមក្រាហ្វិក *៦.២.២.១០* បានបង្ហាញថា គណៈអភិបាលក្រុង ស្រុក ខណ្ឌចំនួន **២៧នាក់** បានលើកឡើងថា កត្តាដែលជាឧបសគ្គ ឬបញ្ហាប្រឈមរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តមុខងារការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ មានដូចខាងក្រោម៖

| **កត្តាជាឧបសគ្គ ឬបញ្ហាប្រឈម** | **ការអប់រំកុមារតូច** | **អប់រំបឋមសិក្សា** | **អប់រំក្រៅប្រព័ន្ធ និងបរិយាបន្ន** |
|---|---|---|---|
| ការគាំទ្របច្ចេកទេស | ៣៦% | ៣១% | ៣៣% |
| ការបែងចែកតួនាទី និងទំនួលខុសត្រូវ | ២១% | ៤៣% | ៣៦% |
| ការងាររដ្ឋបាល និងខ្សែគណនេយ្យភាព | ២៥% | ៤៣% | ៣២% |
| ធនធាន | ២៥% | ៣៥% | ៤០% |
| ការពិនិត្យតាមដាន | ២៦% | ៤៤% | ៣០% |

ក្រាហ្វិក ៦.២.២.១០ ឧបសគ្គ ឬបញ្ហាប្រឈមនានារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តមុខងារអប់រំទាំងបីអនុវិស័យ



### ១២.ការយល់ឃើញរបស់គណៈអភិបាលក្រុង ស្រុក ខណ្ឌអំពីគុណភាពនៃសេវាអប់រំសំដៅលើការអភិវឌ្ឍរបស់ប្រព័ន្ធអប់រំសម្រាប់អនុវិស័យនីមួយៗ ការដឹកនាំ និងការគ្រប់គ្រង និងយន្តការត្រួតពិនិត្យ និងវាយតម្លៃ

ផ្អែកតាមក្រាហ្វិក*៦.២.២.១១* បានបង្ហាញថា គណៈអភិបាលក្រុង ស្រុក ខណ្ឌចំនួន **២៧នាក់** បានលើកឡើងថា គុណភាពនៃសេវាអប់រំសំដៅលើការអភិវឌ្ឍរបស់ប្រព័ន្ធអប់រំសម្រាប់អនុវិស័យនីមួយៗ ការដឹកនាំ និងការគ្រប់គ្រង និងយន្តការត្រួតពិនិត្យ និងវាយតម្លៃ រួមមានដូចខាងក្រោម៖

- **ការអប់រំកុមារតូច៖** មានចំនួន ០% មិនពេញចិត្តសោះ ៣% ពេញចិត្តតិចតួច ៣១% ពេញចិត្តមធ្យម ៥៩% ពេញចិត្ត និង ៧% ពេញចិត្តខ្លាំង
- **ការអប់រំបឋមសិក្សា៖** មានចំនួន ០% មិនពេញចិត្តសោះ ៣% ពេញចិត្តតិចតួច ៤១% ពេញចិត្តមធ្យម ៤% ពេញចិត្ត និង ៧% ពេញចិត្តខ្លាំង
- **ការអប់រំក្រៅប្រព័ន្ធ៖** មានចំនួន ០% មិនពេញចិត្តសោះ ១៤% ពេញចិត្តតិចតួច ៤៥% ពេញចិត្តមធ្យម ៣៤% ពេញចិត្ត និង ៧% ពេញចិត្តខ្លាំង។

ក្រាហ្វិក ៦.២.២.១១. កម្រិតយល់ឃើញលើគុណភាពនៃសេវាអប់រំសំដៅលើការអភិវឌ្ឍរបស់ប្រព័ន្ធអប់រំទាំងបីអនុវិស័យ




### ១៣. រដ្ឋបាលក្រុង ស្រុក ខណ្ឌបានធ្វើប្រតិភូកម្មការងារអប់រំទៅឱ្យរដ្ឋបាលឃុំ សង្កាត់

ផ្អែកតាមក្រាហ្វិក*៦.២.២.១២* បានបង្ហាញថា គណៈអភិបាលក្រុង ស្រុក ខណ្ឌចំនួន **២៧នាក់** មានមតិ ៥៥.៦០% បានលើកឡើងថា រដ្ឋបាលក្រុង ស្រុក ខណ្ឌមិនបានធ្វើប្រតិភូកម្មការងារអប់រំទៅឱ្យរដ្ឋបាលឃុំ សង្កាត់ និងមានមតិ ៤៤.៤០% បានធ្វើប្រតិភូកម្មការងារអប់រំទៅឱ្យរដ្ឋបាលឃុំ សង្កាត់។

*ក្រាហ្វិក ៦.២.២.១២*



## ១៤. ការកៀរគរធនធានពីប្រភពនានាដើម្បីគាំទ្រដល់ការអនុវត្តមុខងារអប់រំនៃអនុវិស័យទាំងបីនាពេលកន្លងមក

ផ្អែកលើការឆ្លើយតបរបស់គណៈអភិបាលក្រុង ស្រុក ខណ្ឌចំនួន **២៧នាក់** បានបង្ហាញថា រដ្ឋបាលក្រុង ស្រុក ខណ្ឌបានចូលរួមចំណែកក្នុងការកៀរគរធនធានពីប្រភពនានាដូចខាងក្រោម៖

- អង្គការដៃគូ សប្បុរសជន វិស័យឯកជន
- ប្រើប្រាស់មូលនិធិឃុំ សង្កាត់ សប្បុរសជន និងអង្គការដៃគូ ក្នុងការចូលរួមចំណែកសាងសង់ និងអភិវឌ្ឍសាលារៀន
- ប្រើប្រាស់មូលនិធិក្រុង ស្រុក ខណ្ឌក្នុងការចូលរួមចំណែកសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងអភិវឌ្ឍសាលារៀន
- ការឧបត្ថម្ភពីសាធារណជន សប្បុរសជន និងមាតាបិតា អាណាព្យាបាលសិស្ស។

## ១៥.យន្តការត្រួតពិនិត្យ និងវាយតម្លៃរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌលើការអនុវត្តមុខងារអប់រំនៃអនុវិស័យទាំងបី

ផ្អែកតាមក្រាហ្វិក*៦.២.២.១៣* បានបង្ហាញថា គណៈអភិបាលក្រុង ស្រុក ខណ្ឌចំនួន **២៧នាក់** បានលើកឡើងថា រដ្ឋបាលក្រុង ស្រុក ខណ្ឌបានប្រើប្រាស់យន្តការត្រួតពិនិត្យវាយតម្លៃរបស់ខ្លួន មានចំនួន ៨១.៥០% តាមរយៈរបាយការណ៍ ៨៨.៩០% តាមរយៈកិច្ចប្រជុំរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ៩២.៦០% តាមរយៈការចុះតាមដានត្រួតពិនិត្យ និង ៥៥.៦០% តាមរយៈយន្តការត្រួតពិនិត្យផ្ទៃក្នុង។

*ក្រាហ្វិក ៦.២.២.១៣.*



### ៦.២.៣. ក្រុមអ្នកផ្តល់ព័ត៌មានជាប្រធាន និងមន្ត្រីទទួលបន្ទុកផ្នែកពាក់ព័ន្ធ នៃការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ

#### ១. ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំនៅថ្នាក់ក្រុង ស្រុក ខណ្ឌ (សូចនាករស្នូល និង ចំណុចដៅ) បានទាន់ពេលវេលា

ផ្អែកតាមក្រាហ្វិក*៦.២.៣.១* បានបង្ហាញថា ក្រុមអ្នកផ្តល់ព័ត៌មានជាប្រធាន និងមន្ត្រីការិយាល័យ អប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌចំនួន **៤៨នាក់** បានលើកឡើងថា ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យ អប់រំនៃអនុវិស័យទាំងបី មានចំនួន ៦៨.៨០% បាន រៀបចំទាន់ពេលវេលា និង ៣១.៣០% រៀបចំមិនទាន់ ពេលវេលា។



*ក្រាហ្វិក ៦.២.៣.១.*

#### ២. ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំកម្រិតក្រុង ស្រុក ខណ្ឌ បើធៀបទៅនឹងទិសដៅដែល បានកំណត់បានសម្រេចកម្រិតណា

ផ្អែកលើក្រាហ្វិក*៦.២.៣.២* បានបង្ហាញថា ក្រុមអ្នកផ្តល់ព័ត៌មានជាប្រធាន និងមន្ត្រីការិយាល័យ អប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌចំនួន **៤៨នាក់** បានលើកឡើងថា ការអនុវត្តផែនការយុទ្ធសាស្ត្រ វិស័យអប់រំនៅថ្នាក់ក្រុង ស្រុក ខណ្ឌ បើធៀបទៅនឹងទិសដៅដែលបានកំណត់ បានសម្រេចលទ្ធផល ដូចខាងក្រោម៖

- **អនុវិស័យការអប់រំកុមារតូច៖** មានចំនួន ១៧% សម្រេចបានតិចតួច ៤១% សម្រេចបាន មធ្យម ៣៥% សម្រេចបានបង្គួរ និង ៧% សម្រេចបានពេញលេញ។
- **អនុវិស័យការអប់រំបឋមសិក្សា៖** មានចំនួន ៧% សម្រេចបានតិចតួច ២៦% សម្រេចបាន មធ្យម ៥៩% សម្រេចបានបង្គួរ និង ៩% សម្រេចបានពេញលេញ។
- **អនុវិស័យការអប់រំក្រៅប្រព័ន្ធ៖** មានចំនួន ១៩% សម្រេចបានតិចតួច ៤៩% សម្រេចបាន មធ្យម ៣០% សម្រេចបានបង្គួរ និង២% សម្រេចបានពេញលេញ។

ក្រាហ្វិក ៦.២.៣.២ ភាគរយសម្រេចបាននៃការអនុវត្តផែនការយុទ្ធសាស្ត្រធៀបនឹងទិសដៅគ្រោង


## ៣. កត្តាជាឧបសគ្គ ឬបញ្ហាប្រឈមដែលធ្វើឱ្យការអនុវត្តផែនការយុទ្ធសាស្ត្រនេះ មិនបានសម្រេចតាមទិសដៅកំណត់

ផ្អែកលើក្រាហ្វិក *៦.២.៣.៣* បានបង្ហាញថា ក្រុមអ្នកផ្តល់ព័ត៌មានជាប្រធាន និងមន្ត្រីការិយាល័យអប់រំ យុវជន និងកីឡា ចំនួន **៤០នាក់** បានលើកឡើងថា កត្តាជាឧបសគ្គ ឬបញ្ហាប្រឈមដែលធ្វើឱ្យការអនុវត្តផែនការយុទ្ធសាស្ត្រនេះមិនបានសម្រេចតាមទិសដៅកំណត់ រួមមានដូចខាងក្រោម៖

| **បរិយាយ** | **ការអប់រំកុមារតូច** | **អប់រំបឋមសិក្សា** | **អប់រំក្រៅប្រព័ន្ធ និងបរិយាបន្ន** |
|---|---|---|---|
| សមត្ថភាព | ៣៦ | ២៨ | ៣៦ |
| ហិរញ្ញវត្ថុ | ៣៨ | ៣៤ | ២៨ |
| បុគ្គលិក | ៣៩ | ៣៥ | ២៦ |
| មធ្យោបាយ | ៣៦ | ៣០ | ៣៤ |
| ការចូលរួម | ៤៤ | ៣២ | ២៤ |
| ផ្សេងៗ | ០ | ០ | ០ |




## ៤. ការផ្សព្វផ្សាយអំពីផែនការយុទ្ធសាស្ត្រ ក្របខ័ណ្ឌគតិយុត្ត និងគោលការណ៍ណែនាំនានាដល់សាលារៀនបានទាន់ពេលវេលា និងទូលំទូលាយ

ផ្អែកតាមក្រាហ្វិក *៦.២.៣.៤* បានបង្ហាញថា ក្រុមអ្នកផ្តល់ព័ត៌មានជាប្រធាន និងមន្ត្រីការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌចំនួន **៤៨នាក់** បានលើកឡើងថា ការផ្សព្វផ្សាយអំពីផែនការ យុទ្ធសាស្ត្រ ក្របខ័ណ្ឌគតិយុត្ត និងគោលការណ៍ណែនាំនានាដល់សាលារៀនមានចំនួន ៨៣.៣០% បានទាន់ពេលវេលា និង ១៦.៧០% ផ្សព្វផ្សាយមិនបានទាន់ពេលវេលា។



### ៥. ការអនុវត្តការងារគ្រប់គ្រងបុគ្គលិកអប់រំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

ផ្អែកតាមតារាងលេខ *៦.២.៣.១* បានបង្ហាញថាក្រុមអ្នកផ្តល់ព័ត៌មានជាប្រធាន និងមន្ត្រីនៃការិយាល័យអប់រំ យុវជន និងកីឡាបានបង្ហាញពីការពេញចិត្តចំពោះការអនុវត្តការងារគ្រប់គ្រងបុគ្គលិកអប់រំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានដូចខាងក្រោម៖

**តារាងលេខ ៦.២.៣.១. ការពេញចិត្តរបស់ប្រធាន និងមន្ត្រីការិយាល័យអប់រំ យុវជន និងកីឡាលើការអនុវត្តការងារគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ**

| ការគ្រប់គ្រងបុគ្គលិក | មិនពេញចិត្តសោះ (ភាគរយ) | ពេញចិត្តតិចតួច (ភាគរយ) | មធ្យម (ភាគរយ) | ពេញចិត្ត (ភាគរយ) | ពេញចិត្តខ្លាំង (ភាគរយ) |
|---|---|---|---|---|---|
| ការរៀបចំផែនការជ្រើសរើសបុគ្គលិកក្របខ័ណ្ឌ និងបុគ្គលិកកិច្ចសន្យា (គ្រូជាគ្រូបង្រៀនជាប់កិច្ចសន្យា) | ៤.៦៨ | ១២.៥០ | ៥៩.៣៧ | ៧០.៣១ | ៤.៦៨ |
| ការជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យា | ៤.៦៨ | ១៥.៦២ | ៤៦.៨៧ | ៧៨.១២ | ៤.៦៨ |
| ការបំពេញសាលាកបត្រព័ត៌មានមន្ត្រីរាជការស៊ីវិល | ០.០០ | ៧.១៣ | ៥៣.១៣ | ៧៨.១២ | ៤.៦៨ |
| ការធ្វើកម្មសិក្សា | ៤.៦៨ | ៤.៤៨ | ២៥.០០ | ៩៦.៨៧ | ៧.៨១ |
| ការតាំងស៊ប់ក្នុងក្របខ័ណ្ឌ | ៦.០០ | ១២.៥០ | ២៨.១២ | ៨៧.៥ | ១២.៥០ |
| ការដំឡើងថ្នាក់ និង/ឬឋានន្តរស័ក្តិ | ៩.៣៧ | ១៨.៧៥ | ៤៦.៨៧ | ៤៦.៨៧ | ៧.៨១ |
| ការតែងតាំង និងការបញ្ចប់មុខតំណែង | ១៥.៦២ | ១២.៥០ | ៦២.៥០ | ៣៧.៥០ | ៤.៦៨ |
| ការបញ្ចប់មុខតំណែង | ៤.៦៨ | ១២.៥០ | ៦៨.៧៥ | ៥៦.២៥ | ០.០០ |
| ការផ្ទេរ និងការផ្លាស់ប្តូរកន្លែងធ្វើការ | ៥.១១ | ១២.៥០ | ៧០.៣១ | ៥០.០០ | ០.០០ |
| ការដាក់ឱ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម ឬដាក់ឱ្យនៅក្រៅតំណែង | ៦.២៥ | ៧.៨១ | ៧៨.១២ | ៣១.២៥ | ៧.៨១ |
| ការដាក់ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស | ៦.២៥ | ១៥.៦២ | ៦៤.០៦ | ៤០.៦២ | ៦.២៥ |

| | | | | | |
|---|---|---|---|---|---|
| ការផ្អាកការងារដោយផ្អាកបៀវត្ស | ៣.១៣ | ៦៧.១៩ | ៤៣.០០ | ៧៥.០០ | ៣.១៣ |
| ការឈប់សម្រាកពីការងារបំពេញការសិក្សា វគ្គបណ្តុះបណ្តាល បេសកកម្មក្នុងនិងក្រៅប្រទេស | ៦.២៥ | ៦.២៥ | ៧១.៨៧ | ៤០.៦៣ | ៩.៣៧ |
| ការដាក់ឱ្យចូលនិវត្តន៍ និងការដាក់ឱ្យបាត់បង់សម្បទាវិជ្ជាជីវៈ | ៦.២៥ | ១២.៥០ | ៧៥.០០ | ៤៦.៨៧ | ៣.១២ |
| ការស្នើសុំលាឈប់ពីការងាររាជការ | ១២.៥០ | ៣.១២ | ៦៤.០៦ | ៤៦.៨៧ | ៣.១២ |
| ការលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌមុខងារសាធារណៈ | ៦.២៥ | ៦.២៥ | ៥៩.៣៧ | ៥៦.២៥ | ៣.១២ |
| ការអនុញ្ញាត និងការទទួលបុគ្គលិកឱ្យចូលបម្រើការងារក្នុងអង្គភាពដើមវិញ | ១២.៥០ | ១២.៥០ | ៦៨.៧៥ | ៤៣.៧៥ | ៣.១២ |
| មន្ត្រីរាជការដែលស្ថិតក្នុងនីតិវិធីចោទប្រកាន់តាមផ្លូវតុលាការ | ៣.១២ | ១៨.៧៥ | ៦៤.០៦ | ៥៤.៦៨ | ៣.១២ |
| ការដាក់វិន័យ | ០.០០ | ០.០០ | ០.០០ | ០.០០ | ០.០០ |

### ៦. ស្ថានភាពនៃការគ្រប់គ្រង ចាត់ចែងថវិកាដំណើរការសាលារៀននៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ

ផ្អែកតាមក្រាហ្វិក **៦.២.៣.៥.** បានបង្ហាញថា ក្រុមអ្នកផ្តល់ព័ត៌មានជាប្រធាននិងមន្ត្រីការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌចំនួន **៤៨នាក់** មានមតិលើកឡើងអំពីការគ្រប់គ្រង និងការប្រើប្រាស់មូលនិធិដំណើរការសាលារៀន រួមមានដូចខាងក្រោម៖

- ការបូកសរុបតាមផែនការ៖ មានចំនួន ២២% មិនទាន់ពេល និង ៧៨% បានទាន់ពេល
- ការទម្លាក់ថវិកាទៅសាលារៀន៖ មានចំនួន ១២% មិនទាន់ពេល និង ៨៨% បានទាន់ពេល
- ការទូទាត់និងរៀបចំរបាយការណ៍សមិទ្ធកម្ម៖ មានចំនួន ២៣% មិនទាន់ពេល និង ៧៧% បានទាន់ពេល
- ការដោះស្រាយបញ្ហាប្រឈមនានា៖ មានចំនួន ២៤% មិនទាន់ពេល និង ៧៦% បានទាន់ពេល។

ក្រាហ្វិក ៦.២.៣.៥ ស្ថានភាពនៃកម្រិតគ្រប់គ្រង ចាត់ចែងថវិកាក្នុងដំណើរការគាំទ្រសាលារៀន




## ៧. ការអនុវត្តកម្មវិធីនានាគាំទ្រមុខងារទាំងបី ការគ្រប់គ្រងសិស្ស ការងារគ្រប់គ្រងគ្រូបង្រៀន និង ការងារផែនការហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់សាលារៀននៅក្នុងឆ្នាំ២០២៣

ផ្អែកតាមតារាង **៦.២.៣.២.** បានបង្ហាញថា ក្រុមអ្នកផ្តល់ព័ត៌ជាប្រធាន និងមន្ត្រីការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌចំនួន **៣២នាក់** បានមានមតិលើកឡើងថា ការអនុវត្តកម្មវិធីនានាគាំទ្រ មុខងារទាំងបី ការគ្រប់គ្រងសិស្ស ការងារគ្រប់គ្រងគ្រូបង្រៀន ការងារផែនការ ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ សាលារៀននៅក្នុងឆ្នាំ២០២៣ ដូចខាងក្រោម៖

**តារាង ៦.២.៣.២. ការអនុវត្តកម្មវិធីគាំទ្រមុខងារអប់រំទាំង៣អនុវិស័យក្នុងឆ្នាំ២០២៣**

| ល.រ | ការគ្រប់គ្រងតាមសាលារៀន | បានតិចតួច (ភាគរយ) | មធ្យម (ភាគរយ) | បានបង្គួរ (ភាគរយ) | បានពេញលេញ (ភាគរយ) |
|---|---|---|---|---|---|
| ក. | **ការគ្រប់គ្រងសិស្ស** | | | | |
| ១ | ការគ្រប់គ្រងទិន្នន័យកុមារដល់វ័យសិក្សា | 0.00 | ១៨.៧៥ | ៨១.២៥ | ៤៣.៧៥ |
| ២ | យុទ្ធនាការប្រមូលកុមារចូលរៀន | 0.00 | ៦.២៥ | ៥៩.៣៧ | ៣៨.១២ |
| ៣ | ការជួយកុមារ សិស្សជួបការលំបាក ឬបោះបង់ការសិក្សា | ៧.៨១ | ២៥.00 | ៨១.២៥ | ២១.៨៧ |
| ខ. | **ការងារគ្រប់គ្រងគ្រូបង្រៀន** | | | | |
| ៤ | ការបំពេញការងាររបស់គ្រូបង្រៀន (វត្តមាន) | 0.00 | ៦.២៥ | ៥៣.១២ | ៨៤.៣៧ |
| ៦ | ការគ្រប់គ្រងទិន្នន័យគ្រូបង្រៀន (លើស ឬខ្វះ) | 0.00 | ៣.១២ | ៥0.00 | ៩៣.៧៥ |

| | | | | | |
|---|---|---|---|---|---|
| ៧ | ការជួយគ្រូបង្រៀន ៖ ការស្នាក់នៅ (សម្រាប់គ្រូបង្រៀនចេញថ្មីជួបការលំបាក) | ៤០.៦២ | ១៨.៧៥ | ៥៣.១២ | ២១.៨៧ |
| គ. | **ការងារផែនការ ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់សាលារៀន** | | | | |
| ១ | ការចូលរួមធ្វើផែនការផ្សេងៗរបស់សាលារៀន | ៦.២៥ | ១៥.៦២ | ៧១.៨៧ | ៥០.០០ |
| ២ | ការពិនិត្យតាមដានការប្រើប្រាស់មូលនិធិដំណើរការសាលារៀន | ០.០០ | ៩.៣៧ | ៨១.២៥ | ៥៣.១២ |
| ៣ | ការពិនិត្យតាមដានការប្រើប្រាស់ទ្រព្យសម្បត្តិរបស់សាលារៀន | ០.០០ | ១៨.៧៥ | ៨៤.៣៧ | ៣៧.៥០ |
| ៤ | ការធ្វើរបាយការណ៍ជូនអ្នកពាក់ព័ន្ធ | ០.០០ | ១៥.៥០ | ៦៥.៦២ | ៦៨.៧៥ |
| ៥ | ការអនុវត្តស្តង់ដាសាលារៀនគំរូ | ២១.៨៧ | ២៨.១២ | ៨៧.៥ | ៥៣.១២ |
| ឃ. | **ផ្សេងៗ** | | | | |
| ១ | ការកៀរគរធនធានសម្រាប់អភិវឌ្ឍសាលារៀន | ១៨.៧៥ | ៥៣.១២ | ៧១.៨៧ | ៣.១២ |
| ២ | ការងារបរិស្ថាន | ៦.២៥ | ២១.៨៧ | ៩៦.៨៧ | ១៥.៦២ |
| ៣ | ហេដ្ឋារចនាសម្ព័ន្ធនានារបស់សាលារៀន ៖ អគារ បន្ទប់ទឹក | ០.០០ | ២៥.០០ | ៩៦.៨៧ | ១៥.៦២ |
| ៤ | ការងារអប់រំកាយ និងកីឡា | ៣.១២ | ២៨.១២ | ៧៨.១២ | ១៥.៦២ |
| ៥ | ការងារក្រុមប្រឹក្សាកុមារ | ៦.២៥ | ៥០.០០ | ៥០.០០ | ៣១.២៥ |
| ៦ | ការចូលរួមជាគណៈកម្មការនានារបស់សាលារៀន | ៩.៣៧ | ២៨.១២ | ៩៣.៧៥ | ១២.៥០ |
| ៧ | ការទប់ស្កាត់បាតុភាពអសកម្មនានារបស់សាលារៀន៖ សន្តិសុខ គ្រឿងញៀន សុខភាពអនាម័យ ល្បែងស៊ីសង | ០.០០ | ២១.៣៧ | ៧៨.១២ | ៤០.៦២ |
| ៨ | ការរៀបចំគណៈកម្មការគ្រប់គ្រងសាលារៀន | ០.០០ | ៩.៣៧ | ៦៨.៧៥ | ៦២.៥០ |

### ៨. ការអនុវត្តផែនការចុះជួយគាំទ្រដំណើរការបង្រៀន និងរៀននៅតាមសាលារៀនធៀបទៅនឹងផែនការ

ផ្អែកតាមក្រាហ្វិក ៦.២.៣.៦. បានបង្ហាញថា ក្រុមអ្នកផ្តល់ព័ត៌មានជាប្រធាន និងមន្ត្រីការិយាល័យ អប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌចំនួន **៤៦នាក់** មានមតិលើកឡើងថា ផែនការចុះជួយគាំទ្រដំណើរការបង្រៀន និងរៀននៅតាមសាលារៀន បើធៀបនឹងផែនការសម្រេចបានលទ្ធផលចំនួន ២.២០% បានតិចតួច ១៣% បានជាមធ្យម ៦០.៩០% បានជាបង្គួរ និង ២៣.៩០% បានពេញលេញ។




### ៩. កត្តាជាឧបសគ្គ ឬបញ្ហាប្រឈមដែលធ្វើឱ្យការអនុវត្តផែនការចុះជួយគាំទ្រដំណើរការបង្រៀន និងរៀនមិនបានសម្រេច

ផ្អែកតាមក្រាហ្វិក **៦.២.៣.៧.** បានបង្ហាញថា ក្រុមអ្នកផ្តល់ព័ត៌មានជាប្រធាន និងមន្ត្រីការិយាល័យ អប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌចំនួន **៤៦នាក់** មានមតិលើកឡើងថា កត្តាជាឧបសគ្គ ឬបញ្ហាប្រឈមដែលធ្វើឱ្យការអនុវត្តផែនការចុះជួយគាំទ្រដំណើរការបង្រៀន និងរៀនមិនបានសម្រេច រួមមានដូចខាងក្រោម៖

| កត្តាជាឧបសគ្គ ឬបញ្ហាប្រឈម | ភាគរយ |
|---|---|
| ថវិកា | ៧៨.៣០% |
| មធ្យោបាយ | ១០.៩០% |
| នីតិវិធីរដ្ឋបាល | ២៦.១០% |
| ពេលវេលា | ៥៨.៧០% |
| បុគ្គលិក | ៦០.៩០% |
| គ្មាន | ៤.៣០% |




### ១០. លទ្ធផលក្នុងរបាយការណ៍សមិទ្ធកម្មកម្រិតក្រុង ស្រុក ខណ្ឌដែលសម្រេចបាននាពេលកន្លងមក (២០២៣) ស្តីពីគោលនយោបាយ និងផែនការយុទ្ធសាស្ត្រនៃអនុវិស័យការអប់រំកុមារតូច ការបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ និងបរិយាបន្ន

ផ្អែកតាមក្រាហ្វិក **៦.២.៣.៨.** បានបង្ហាញថា ក្រុមអ្នកផ្តល់ព័ត៌មានជាប្រធាន និងមន្ត្រីការិយាល័យ អប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌចំនួន **៤៦នាក់** បានលើកឡើងថា លទ្ធផលក្នុងរបាយការណ៍សមិទ្ធកម្មកម្រិតក្រុង ស្រុក ខណ្ឌដែលអនុវត្តនាពេលកន្លង មានដូចខាងក្រោម៖

- **ការគ្រប់គ្រងការអប់រំកុមារតូច៖** មានចំនួន ២% បានតិចតួច ៥០% បានមធ្យម ៣៥% បានបង្គួរ និង ១៣% បានពេញលេញ
- **ការគ្រប់គ្រងការអប់រំបឋមសិក្សា៖** មានចំនួន ២% បានតិចតួច ២២% បានមធ្យម ៦៣% បានបង្គួរ និង ១៣% បានពេញលេញ
- **ការគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ៖** មានចំនួន ៤% បានតិចតួច ៥០% បានមធ្យម ៣៧% បានបង្គួរ និង ៩% បានពេញលេញ។

ក្រាហ្វិក ៦.២.៣.៨. លទ្ធផលរបាយការណ៍សមិទ្ធកម្មនៅក្រុងស្រុកខណ្ឌានអនុវត្តកន្លងមក




## ១១. ទំនាក់ទំនងការងារ (របាយការណ៍ លិខិតរដ្ឋបាល) កន្លងមករវាងការិយាល័យអប់រំយុវជន និងកីឡា និងអ្នកពាក់ព័ន្ធនានា

ផ្អែកតាមក្រាហ្វិក **៦.២.៣.៩.** បានបង្ហាញថា ក្រុមអ្នកផ្តល់ព័ត៌មានជាប្រធាន និងមន្ត្រីការិយាល័យអប់រំ យុវជន និងកីឡាចំនួន **៤៨នាក់** បានមានមតិលើកឡើងថា ទំនាក់ទំនងការងារ (របាយការណ៍ លិខិតរដ្ឋបាល) កន្លងមក រវាងការិយាល័យអប់រំ យុវជន និងកីឡា និងអ្នកពាក់ព័ន្ធនានា រួមមានដូចខាងក្រោម៖

| ល.រ | អ្នកពាក់ព័ន្ធ | មិនពេញចិត្តសោះ | ពេញចិត្តតិចតួច | ធម្មតា | ពេញចិត្ត | ពេញចិត្តខ្លាំង |
|---|---|---|---|---|---|---|
| ១ | មន្ទីរអប់រំ យុវជន និងកីឡា | ២% | ២៦% | ២៦% | ៦៨% | ៤% |
| ២ | រដ្ឋបាលក្រុង ស្រុក ខណ្ឌ | ២% | ៣៩% | ៣៩% | ៤៨% | ០% |
| ៣ | រដ្ឋបាលឃុំ សង្កាត់ | ២% | ៤៦% | ៤៦% | ៣៩% | ០% |
| ៤ | សាលារៀន | ០% | ២០% | ២០% | ៧៦% | ២% |
| ៥ | ការិយាល័យជំនាញនានា | ២% | ៤៥% | ៤៥% | ៤៧% | ០% |

ក្រាហ្វិក ៦.២.៣.៩. ទស្សនៈយល់ឃើញអំពីទំនាក់ទំនងការងារ (របាយការណ៍ លិខិតស្នាមរដ្ឋបាល) រវាងកា.រិអប់រំ និងអ្នកពាក់ព័ន្ធនានា



### ៦.២.៤. ក្រុមអ្នកផ្តល់ព័ត៌មានជាថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងប្រធានការិយាល័យពាក់ព័ន្ធ

#### ១. ការធ្វើសមាហរណកម្មការិយាល័យអប់រំ យុវជន និងកីឡាទៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

ផ្អែកតាមក្រាហ្វិក ៦.២.៤.១. បានបង្ហាញថា អ្នកផ្តល់ព័ត៌មានជាប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចំនួន **០៥នាក់** មានមតិបានលើកឡើងថា ការធ្វើសមាហរកម្មការិយាល័យអប់រំ យុវជន និងកីឡាទៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ មានចំនួន ៨០% ត្រឹមត្រូវ និង ២០% លើកឡើងថាមិនត្រឹមត្រូវ។




*ក្រាហ្វិក ៦.២.៤.១.*

#### ២. ការគ្រប់គ្រងដឹកនាំ និងចាត់ចែងការងារនានាក្នុងវិស័យអប់រំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ នាពេលកន្លងមក (ឆ្នាំ២០២៣)

ផ្អែកតាមក្រាហ្វិក ៦.២.៤.២. បានបង្ហាញថា អ្នកផ្តល់ព័ត៌មានជាប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចំនួន៥នាក់ យល់ឃើញថា ការគ្រប់គ្រងការដឹកនាំ និងការចាត់ចែងការងារនានាក្នុងវិស័យអប់រំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌនាពេលកន្លងមក មានចំនួន ៦០% ពេញចិត្តតិចតួច ២០% ពេញចិត្តមធ្យម និង ២០% ពេញចិត្ត។




*ក្រាហ្វិក ៦.២.៤.២.*

#### ៣. ការទំនាក់ទំនងការងារនានារវាងមន្ទីរអប់រំ យុវជន និងកីឡាជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្រោយសមាហរណកម្ម

ផ្អែកតាមក្រាហ្វិក **៦.២.៤.៣.** បានបង្ហាញថា អ្នកផ្តល់ព័ត៌មានជាប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចំនួន **០៥នាក់** យល់ឃើញថា ការទំនាក់ទំនងការងារនានារវាងមន្ទីរអប់រំ យុវជន និងកីឡាជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្រោយសមាហរណកម្ម រួមមានដូចខាងក្រោម៖

១) **ការងារពិនិត្យនីត្យានុកូលភាព សេចក្តីសម្រេចនានា** ៖ មាន ៦០% កម្រិតមធ្យម និង ៤០% កម្រិតបង្គួរ

២) **ការងារគាំទ្របច្ចេកទេស ការអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ** ៖ មាន ៨០% កម្រិតបង្គួរ និង ២០% កម្រិតមធ្យម

៣) **ការងារពិនិត្យតាមដាន វាយតម្លៃ អធិការកិច្ច និងធ្វើសវនកម្ម** ៖ មាន ៥០% កម្រិតមធ្យម និង ៥០% កម្រិតបង្គួរ

៤) **ការងារបោយការណ៍** ៖ ១០០% កម្រិតល្អបង្គួរ។

ក្រាហ្វិក ៦.២.៤.៣. ទស្សនៈយល់ឃើញអំពីទំនាក់ទំនងការងារនានារវាងមន្ទីរអប់រំជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌក្រោយសមាហរកម្ម




## ៤. ស្ថានភាពនៃការដឹកនាំ និងការគ្រប់គ្រងអនុវត្តមុខងារអប់រំយុវជន និងកីឡារបស់ការិយាល័យអប់រំ យុវជន និងកីឡា

ផ្អែកតាមក្រាហ្វិក **៦.២.៤.៤.** បានបង្ហាញថា អ្នកផ្តល់ព័ត៌មានជាប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចំនួន **០៥នាក់** បានយល់ឃើញអំពីស្ថានភាពនៃការដឹកនាំ និងការគ្រប់គ្រងរបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ រួមមានលទ្ធផលខាងក្រោម៖

១) **ការដឹកនាំគ្រប់គ្រងបុគ្គលិក (តែងតាំង ផ្លាស់ប្តូរ ដំឡើងថ្នាក់ ឋានន្តរស័ក្តិជាដើម)៖** ២៥% បង្គួរ និង ៧៥% ល្អ

២) **ការគ្រប់គ្រងចាត់ចែង និងប្រើប្រាស់ថវិកានិងទ្រព្យសម្បត្តិរដ្ឋរបស់ការិយាល័យអប់រំ យុវជន និងកីឡា** ៖ ៥០% បង្គួរ និង ៥០% ល្អ

៣) **មុខងារការគ្រប់គ្រងការអប់រំកុមារតូច** ៖ ១០០% បង្គួរ

៤) **ការគ្រប់គ្រងការអប់រំបឋមសិក្សា** ៖ ១០០% បង្គួរ

៥) **មុខងារការគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ** ៖ ៨០% បង្គួរ និង ២០% ល្អ

៦) **មុខងារមធ្យមសិក្សាចំណេះទូទៅ** ៖ ៧៥% បង្គួរ និង ២៥% ល្អ

៧) **ការងារអប់រំកាយ និងកីឡា** ៖ ៧៥% បង្គួរ និង ២៥% ល្អ

៨) **ការងារយុវជន** ៖ ៧៥% បង្គួរ និង ២៥ % ល្អ។

ក្រាហ្វិក ៦.២.៤.៤. ការដឹកនាំការអនុវត្តមុខងារអប់រំ យុវជន និងកីឡាការិយាល័យអប់រំ យុវជន និងកីឡា




## ៥. ទស្សនៈយល់ឃើញទូទៅចំពោះការពិនិត្យតាមដានគាំទ្រសាលាមត្តេយ្យសិក្សា បឋមសិក្សា និងមជ្ឈមណ្ឌលសិក្សាសហគមន៍របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌនាពេលកន្លងមក (២០២៣)

ផ្អែកតាមក្រាហ្វិក **៦.២.៤.៥.** បានបង្ហាញថា អ្នកផ្តល់ព័ត៌មានជាប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ចំនួន **០៥នាក់** យល់ឃើញថា ជាទូទៅ រដ្ឋបាលក្រុង ស្រុក ខណ្ឌ បានចុះពិនិត្យតាមដានគាំទ្រសាលាមត្តេយ្យសិក្សា សាលាបឋមសិក្សា និងមជ្ឈមណ្ឌលសហគមន៍ បានក្នុងកម្រិត ២០% មធ្យម ៤០% ល្អបង្គួរ និង ៤០% ល្អ។




*ក្រាហ្វិក ៦.២.៤.៥.*

## ៦. កត្តាជាឧបសគ្គ ឬបញ្ហាប្រឈមនានារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការគ្រប់គ្រង ដឹកនាំ និងចាត់ចែងការងារនានាក្នុងវិស័យអប់រំក្រោយសមាហរណកម្ម

ផ្អែកតាមការឆ្លើយតប របស់អ្នកផ្តល់ព័ត៌មានជាប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចំនួន **០៥នាក់** បានលើកឡើងថា ក្រោយសមាហរណកម្មការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ មកក្រោមរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ គឺមានបញ្ហាប្រឈមលើការដំឡើងឋានន្តរស័ក្តិ ថ្នាក់ និងការតែងតាំងមុខដំណែងមានភាពស្មុគស្មាញ តម្រូវការឯកសារភ្ជាប់ច្រើន និងមានការយឺតយ៉ាវក្នុងការចេញដីកា។

## ៦.២.៥. ក្រុមអ្នកផ្តល់ព័ត៌មានជា (នាយក/នាយិកាសាលាមត្តេយ្យសិក្សា)

### ១. ការដឹកនាំ និងគ្រប់គ្រងសាលាមត្តេយ្យសិក្សានាពេលកន្លងមក

ផ្អែកតាមក្រាហ្វិក **៦.២.៥.១.** បានបង្ហាញថា អ្នកផ្តល់ព័ត៌មានជានាយក/នាយិកាសាលាមត្តេយ្យសិក្សាចំនួន **៨២នាក់** បានលើកឡើងថា ការដឹកនាំ និងគ្រប់គ្រងសាលាមត្តេយ្យសិក្សាចំនួន ១.២០% ពេញចិត្តតិចតួច ១៣.៤០% ពេញចិត្តធម្មតា ៦៩.៥០% ពេញចិត្ត និង ១៥.៩០% ពេញចិត្តខ្លាំង។

ក្រាហ្វិក ៦.២.៥.១.




### ២. ការយល់ឃើញអំពីសារៈសំខាន់នៃការអនុវត្តកម្មវិធីនានាគាំទ្រដល់ការងារការអប់រំកុមារតូច

ផ្អែកតាមក្រាហ្វិក **៦.២.៥.២.** បានបង្ហាញថា អ្នកផ្តល់ព័ត៌មានជានាយក/នាយិកាសាលាមត្តេយ្យសិក្សាចំនួន **៨២នាក់** បានយល់ឃើញអំពីសារៈសំខាន់នៃការអនុវត្តកម្មវិធីនានាគាំទ្រដល់ការងារការអប់រំកុមារតូច រួមមានដូចខាងក្រោម៖

១) **ការគ្រប់គ្រងកម្មវិធីមត្តេយ្យសិក្សារដ្ឋ និងឯកជន** ៖ មានចំនួន ១% សំខាន់តិចតួច ២% ធម្មតា ៦២% សំខាន់ និង ៣៥% សំខាន់ណាស់

២) **កម្មវិធីអប់រំបរិយាបន្ន និងកម្មវិធីពហុភាសា** ៖ មានចំនួន ១% មិនសំខាន់ ៨% ធម្មតា ៦៤% សំខាន់ និង ២៧% សំខាន់ណាស់

៣) **កម្មវិធីអាហារូបត្ថម្ភ** ៖ មានចំនួន ៦% ធម្មតា ៤៥% សំខាន់ និង ៤៩% សំខាន់ណាស់

៤) **កម្មវិធីជួយកុមារក្រីក្រតាមសាលា** ៖ មានចំនួន ៣% សំខាន់តិចតួច ៥% ធម្មតា ៥០% សំខាន់ និង ៤២% សំខាន់ណាស់

៥) **កម្មវិធីអប់រំមាតាបិតាផ្សារភ្ជាប់នឹងកម្មវិធីមត្តេយ្យសិក្សារដ្ឋ** ៖ មានចំនួន ១% សំខាន់តិចតួច ៦% ធម្មតា ៤៧% សំខាន់ និង ៤៦% សំខាន់ណាស់។

ក្រាហ្វិក ៦.២.៥.២. ទស្សនៈយល់ឃើញពីសារៈសំខាន់នៃការអនុវត្តកម្មវិធីនានាគាំទ្រដល់មុខងារអប់រំកុមារតូច



### ៣. ការងារគ្រប់គ្រងគ្រូមត្តេយ្យសិក្សានាពេលកន្លងមក (២០២៣)

ផ្អែកតាមក្រាហ្វិក **៦.២.៥.៣.** បានបង្ហាញថា អ្នកផ្ដល់ព័ត៌មានជានាយក/នាយិកាសាលាមត្តេយ្យសិក្សាចំនួន **៨២នាក់** បានលើកឡើងការយល់ឃើញ អំពីការងារគ្រប់គ្រងគ្រូមត្តេយ្យសិក្សា មានដូចខាងក្រោម៖

១) **ការសុំច្បាប់ឈប់សម្រាក** ៖ មានចំនួន ៣% មិនពេញចិត្តសោះ ៩% មិនពេញចិត្ត ៣៥% ធម្មតា ៣៨% ពេញចិត្ត និង ១៥% ពេញចិត្តខ្លាំង

២) **ការដំឡើងកាំ** ៖ មានចំនួន ១% មិនពេញចិត្ត ៩% ធម្មតា ៥៨% ពេញចិត្ត និង ៣២% ពេញចិត្តខ្លាំង

៣) **ការតែងតាំងឋានន្តរស័ក្តិ** ៖ មានចំនួន ១% មិនពេញចិត្ត ១០% ធម្មតា ៦៥% ពេញចិត្ត និង ២៣% ពេញចិត្តខ្លាំង

៤) **ការសម្រាកលំហែមាតុភាព** ៖ មានចំនួន ១% មិនពេញចិត្ត ២២% ធម្មតា ៤៩% ពេញចិត្ត និង ២៨% ពេញចិត្តខ្លាំង

៥) **ការផ្លាស់ប្ដូរ** ៖ មានចំនួន ១៨% មិនពេញចិត្ត ៣៤% ធម្មតា ៣៧% ពេញចិត្ត និង ១១% ពេញចិត្តខ្លាំង

៦) **ការដាក់វិន័យ** ៖ មានចំនួន ៨% មិនពេញចិត្តសោះ ៣៦% មិនពេញចិត្ត ៤១% ធម្មតា ១១% ពេញចិត្ត និង ៥% ពេញចិត្តខ្លាំង។

ក្រាហ្វិក ៦.២.៥.៣. ទស្សនៈយល់ឃើញចំពោះការគ្រប់គ្រងគ្រូមត្តេយ្យ




### ៤. កញ្ចប់ថវិកាដែលទទួលបានសម្រាប់គាំទ្រដំណើរការសាលាមត្តេយ្យសិក្សាជារៀងរាល់ឆ្នាំ ឆ្លើយតបទៅនឹងផែនការ និងតម្រូវការជាក់ស្ដែងរបស់សាលារៀន

ផ្អែកតាមក្រាហ្វិក **៦.២.៥.៤.** អ្នកផ្ដល់ព័ត៌មានជានាយក/នាយិកាសាលារៀនមត្តេយ្យសិក្សាចំនួន **៨២នាក់** បានលើកឡើងថា កញ្ចប់ថវិកាសម្រាប់ដំណើរការសាលារៀនឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែង រួមមាន ៦% បានតិចតួច ១៥% បានមធ្យម ៣៦% បានបង្គួរ និង ៤៣% បានពេញលេញ។

ក្រាហ្វិក ៦.២.៥.៤. កញ្ចប់ថវិកាគាំទ្រដំណើរការសាលារៀនមត្តេយ្យសិក្សា ឆ្លើយតបទៅនឹងផែនការ និង តម្រូវការជាក់ស្តែង




## ៥. ការរួមចំណែករបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ក្នុងការប្រើប្រាស់ថវិកាពីមូលនិធិរបស់ខ្លួនដើម្បីជួយគាំទ្រសាលារៀន

ផ្អែកតាមក្រាហ្វិក **៦.២.៥.៥.** បានបង្ហាញថា អ្នកផ្តល់ព័ត៌មានជានាយក/នាយិកាសាលារៀនមត្តេយ្យសិក្សាចំនួន **៨២នាក់** បានលើកឡើងអំពីការប្រើប្រាស់ថវិកាពីមូលនិធិរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ដើម្បីជួយគាំទ្រដល់សាលារៀន ដែលក្នុងនោះរួមមាន៖ ៥.៤០% បានប្រើប្រាស់ថវិកាពេញលេញ ៤.៥០% បានប្រើប្រាស់ថវិកាបង្គួរ ១១.៣០% បានប្រើប្រាស់ថវិកាជាមធ្យម ២៥.៩០% បានប្រើប្រាស់ថវិកាតិចតួច និង ៥៣.៨០% មិនបានប្រើប្រាស់ថវិកា។

*ក្រាហ្វិក ៦.២.៥.៥.*




## ៦. ការដាក់បញ្ចូលផែនការសកម្មភាពជាអាទិភាពនានារបស់វិស័យអប់រំទៅក្នុងផែនការអភិវឌ្ឍន៍ ០៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ក្រុង ស្រុក ខណ្ឌ នៅក្នុងឆ្នាំ២០២៣

ផ្អែកតាមក្រាហ្វិក **៦.២.៥.៦.** បានបង្ហាញថា អ្នកផ្តល់ព័ត៌មានជានាយក/នាយិកាសាលារៀនមត្តេយ្យសិក្សាចំនួន **៨២នាក់** បានលើកឡើងថា ផែនការសកម្មភាពនានារបស់វិស័យអប់រំ យុវជន និងកីឡាបានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍០៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរដ្ឋបាលក្រុង ស្រុក ខណ្ឌ រួមមាន៖

- ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំឆ្នាំស្តីពីការអប់រំកុមារតូចមានចំនួន ៧៤.៤០% បានដាក់បញ្ចូល និង ២៥.៦០% មិនបានដាក់បញ្ចូល
- ផែនការអភិវឌ្ឍន៍សាលារៀនសម្រាប់មត្តេយ្យសិក្សារដ្ឋមានចំនួន ៦៧.១០% បានដាក់បញ្ចូល និង ៣២.៩០% មិនបានដាក់បញ្ចូល
- ផែនការអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀនមានចំនួន ២៦.៨០% បានដាក់បញ្ចូល និង ៧៣.២០%
- មិនបានដាក់បញ្ចូល។

*ក្រាហ្វិក ៦.២.៥.៦.*




## ៧. ការអនុវត្តផែនការជាក់ស្ដែង នៅក្នុងឆ្នាំ២០២៣

ផ្អែកតាមក្រាហ្វិក **៦.២.៥.៧.** បានបង្ហាញថា អ្នកផ្ដល់ព័ត៌មានជានាយក/នាយិកាសាលារៀនមត្តេយ្យសិក្សាចំនួន **៨២នាក់** បានលើកឡើងថា កម្រិតនៃការអនុវត្តជាក់ស្ដែងនៃផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំឆ្នាំស្ដីពីការអប់រំកុមារតូច ផែនការអភិវឌ្ឍន៍សាលាមត្តេយ្យសិក្សារដ្ឋ និងផែនការអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀន រួមមានដូចខាងក្រោម៖

- ការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំឆ្នាំស្ដីពីការអប់រំកុមារតូចមានចំនួន ៧% បានតិចតួច ២៧% បានមធ្យម ៥៥% បានបង្គួរ និង ១១% បានពេញលេញ
- ការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀនសម្រាប់មត្តេយ្យសិក្សារដ្ឋមានចំនួន ១២.៥០% បានតិចតួច ២៦,៥០% បានមធ្យម ៥១% បានបង្គួរ និង ១០% បានពេញលេញ
- ការអនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀនមានចំនួន ១៨% បានតិចតួច ១៩% បានមធ្យម ៤៨% បានបង្គួរ និង ១៥% បានពេញលេញ។




## ៨. ការទំនាក់ទំនងការងាររវាងសាលាមត្តេយ្យសិក្សា និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់

ផ្អែកតាមក្រាហ្វិក **៦.២.៥.៨.** អ្នកផ្ដល់ព័ត៌មានជានាយក/នាយិកាសាលាមត្តេយ្យសិក្សាចំនួន **៨២នាក់** បានបង្ហាញថា ទំនាក់ទំនងការងាររវាងសាលាមត្តេយ្យសិក្សា និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ រួមមានលទ្ធផលដូចខាងក្រោម៖

- **ទំនាក់ទំនងការងាររវាងសាលាមត្តេយ្យសិក្សា និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ៖** មាន ២% មិនពេញចិត្ត ៤២% ធម្មតា ៤៧% ពេញចិត្ត និង ៩% ពេញចិត្តខ្លាំង
- **ទំនាក់ទំនងការងាររវាងសាលារៀនមត្តេយ្យសិក្សា និងរដ្ឋបាលឃុំ សង្កាត់៖** មាន ៣% មិនពេញចិត្ត ៤៣% ធម្មតា ៣៩% ពេញចិត្ត និង ១៥% ពេញចិត្តខ្លាំង។

ក្រាហ្វិក ៦.២.៥.៨. ការយល់ឃើញអំពីទំនាក់ទំនងការងាររវាងសាលាមត្តេយ្យ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់




## ៩. បញ្ហាប្រឈមនានាក្នុងការប្រាស្រ័យទាក់ទងការងាររវាងសាលាមត្តេយ្យសិក្សា និងរដ្ឋបាល ក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់

ផ្អែកតាមការផ្តល់ព័ត៌មានពីនាយក/នាយិកាសាលារៀនមត្តេយ្យសិក្សាចំនួន **៨២នាក់** បានបង្ហាញថា មានបញ្ហាប្រឈមមួយចំនួនក្នុងការប្រាស្រ័យទាក់ទងការងាររវាងរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ និងសាលារៀន រួមមានដូចជា៖ ការលំបាកក្នុងការបញ្ជូនឯកសារមករដ្ឋបាលក្រុង ស្រុក ខណ្ឌ (ដោយសារសាលានៅឆ្ងាយ) ការចូលរួម និងកិច្ចសហការនានានៅមានកម្រិតនៅឡើយ ការយកចិត្តទុកដាក់របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ចំពោះការអប់រំកុមារតូចនៅមានកម្រិតនៅឡើយ រដ្ឋបាលឃុំ សង្កាត់មួយចំនួនមិនដែលបានអញ្ជើញលោកគ្រូ អ្នកគ្រូមត្តេយ្យសិក្សាចូលរួមក្នុងកិច្ចប្រជុំនានានៅសាលាឃុំ ដូចនាយក/នាយិកាបឋមសិក្សា ការចូលរួមក្នុងការអភិវឌ្ឍសាលារៀននៅមិនទាន់បានល្អ ពិបាកក្នុងការចេញលិខិតឧទ្ទេសនាមនិងមានការយឺតយ៉ាវ ការទំនាក់ទំនងនៅមិនទាន់មានភាពស៊ីសង្វាក់គ្នានៅឡើយ រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់មិនសូវបានគាំទ្រដល់សាលារៀន ជាពិសេសការចូលរួមអភិវឌ្ឍសាលារៀនក្នុងការកែលម្អ និងថែរក្សា ដោយគាត់គិតថាកិច្ចការនេះ ជាកិច្ចការរបស់គ្រូបង្រៀនជាអ្នកទទួលបន្ទុកទាំងស្រុង។

## ១០. ការគ្រប់គ្រង និងការគាំទ្ររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌចំពោះមុខងារការអប់រំកុមារតូច នាពេលកន្លងមក ឆ្នាំ២០២៣

ផ្អែកតាមក្រាហ្វិក **៦.២.៥.៩.** អ្នកផ្តល់ព័ត៌មានជានាយក/នាយិកាសាលាមត្តេយ្យសិក្សាចំនួន **៨២នាក់** បានបង្ហាញអំពីការយល់ឃើញចំពោះការគ្រប់គ្រង និងការគាំទ្ររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌដល់ការអនុវត្តមុខងារអនុវិស័យការអប់រំកុមារតូចនាពេលកន្លងមក រួមមានលទ្ធផលដូចខាងក្រោម៖

- **ការរៀបចំផែនការ៖** មាន ១.២៥% មិនបានគាំទ្រ ១៥% គាំទ្រតិចតួច ៣៧.៥០% មធ្យម ៣៨.៧៥% គាំទ្រច្រើន និង ៧.៥០% គាំទ្រច្រើនណាស់
- **ការពិនិត្យតាមដាន និងវាយតម្លៃ** ៖ ២.៤៤% មិនបានគាំទ្រ ១៣.៤១% គាំទ្រតិចតួច ៤២.៦៨% មធ្យម ៣៤.១៥% គាំទ្រច្រើន និង ៧.៣២% គាំទ្រច្រើណាស់
- **ការគ្រប់គ្រងគ្រូបង្រៀនមត្តេយ្យសិក្សា៖** ២.៤% មិនបានគាំទ្រ ១១.១១% គាំទ្រតិចតួច ៤១.៩៨% មធ្យម ៣៧.០៤% គាំទ្រច្រើន និង ៧.៤១% គាំទ្រច្រើនណាស់
- **ការគ្រប់គ្រងហិរញ្ញវត្ថុ** ៖ ៣.៧០% មិនបានគាំទ្រ ១៣.៥៨% គាំទ្រតិចតួច ៣៩.៥១% មធ្យម ៣៧.០៤% គាំទ្រច្រើន និង ៦.១៧% គាំទ្រច្រើនណាស់
- **ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ** ៖ ៣.៦៦% មិនបានគាំទ្រ ១០.៩៨% គាំទ្រតិចតួច ៣៥.៣៧% មធ្យម ៤១.៤៦% គាំទ្រច្រើន និង ៨.៥៤% គាំទ្រច្រើនណាស់
- **សុវត្ថិភាព អនាម័យ និងបរិស្ថាននៅតាមសាលារៀន** ៖ ៦.២៥% មិនបានគាំទ្រ ១០% គាំទ្រតិចតួច ២៨.៧៥% មធ្យម ៤៥% គាំទ្រច្រើន និង ១០% គាំទ្រច្រើនណាស់
- **ការកៀរគរធនធានសម្រាប់ការអភិវឌ្ឍសាលារៀន** ៖ ៨.៥៤% មិនបានគាំទ្រ ១៨.២៩% គាំទ្រតិចតួច ៣៤.១៥% មធ្យម ២៨.០៥% គាំទ្រច្រើន និង ១០.៩៨% គាំទ្រច្រើនណាស់។

**ក្រាហ្វិក ៦.២.៥.៩. ការគាំទ្ររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌទៅលើការងារអប់រំកុមារតូច (២០២៣)**




| | ការរៀបចំផែនការ | ការពិនិត្យតាមដាន និងវាយតម្លៃ | ការគ្រប់គ្រងគ្រូបង្រៀនមត្តេយ្យ | ការគ្រប់គ្រងហិរញ្ញវត្ថុ | ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ | សន្តិសុខសណ្ដាប់ធ្នាប់អាណាម័យ | ការកៀរគរធនធានសម្រាប់អភិវឌ្ឍសាលារៀន |
|---|---|---|---|---|---|---|---|
| មិនបានគាំទ្រសោះ | 1.25 | 2.44 | 2.47 | 3.70 | 3.66 | 6.25 | 8.54 |
| គាំទ្រតិចតួច | 15.00 | 13.41 | 11.11 | 13.58 | 10.98 | 10.00 | 18.29 |
| គាំទ្រមធ្យម | 37.50 | 42.68 | 41.98 | 39.51 | 35.37 | 28.75 | 34.15 |
| គាំទ្រច្រើន | 38.75 | 34.15 | 37.04 | 37.04 | 41.46 | 45.00 | 28.05 |
| គាំទ្រច្រើនណាស់ | 7.50 | 7.32 | 7.41 | 6.17 | 8.54 | 10.00 | 10.98 |

■មិនបានគាំទ្រសោះ ■គាំទ្រតិចតួច ■គាំទ្រមធ្យម ■គាំទ្រច្រើន ■គាំទ្រច្រើនណាស់

### ៦.២.៦. ក្រុមអ្នកផ្តល់ព័ត៌មានជានាយក/នាយិកាសាលាបឋមសិក្សា

**១. ទស្សនៈយល់ឃើញចំពោះស្ថានភាពការដឹកនាំ គ្រប់គ្រងនិងចាត់ចែងសាលាបឋមសិក្សាមុនផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ**

ផ្អែកតាមក្រាហ្វិក **៦.២.៦.១.** អ្នកផ្តល់ព័ត៌មានជានាយក/នាយិកាសាលាបឋមសិក្សា ចំនួន **៦៣៥នាក់** បានបង្ហាញមតិយល់ឃើញថា ៣.៧% តិចតួច ១០% មធ្យម ៦៩.៩០% ពេញចិត្ត និង ១៦.៤០% ពេញចិត្តខ្លាំង។

*ក្រាហ្វិក ៦.២.៦.១.*




**២. ទស្សនៈយល់ឃើញអំពីស្ថានភាពនៃការអនុវត្តកម្មវិធីគាំទ្រការអប់រំបឋមសិក្សា**

ផ្អែកតាមក្រាហ្វិក **៦.២.៦.២.** អ្នកផ្តល់ព័ត៌មានជានាយក/នាយិកាសាលាបឋមសិក្សាចំនួន **៦៣៥នាក់** បានបង្ហាញមតិយល់ឃើញថាស្ថានភាពនៃការអនុវត្តកម្មវិធីគាំទ្រការអប់រំបឋមសិក្សា រួមមានដូចជា៖

- **កម្មវិធីអប់រំពហុភាសា៖** មាន ៥% មិនសំខាន់ ១២% សំខាន់តិចតួច ៣៣% មធ្យម ៣៨% សំខាន់ និង ១២% សំខាន់ណាស់
- **កម្មវិធីពន្លឿនការសិក្សា៖** មាន ២.៨០% មិនសំខាន់ ១៣% សំខាន់តិចតួច ៣២.៧០% មធ្យម ៤១.៤០% សំខាន់ និង ១០.១០% សំខាន់ណាស់
- **កម្មវិធីផ្តល់អាហារតាមសាលារៀន៖** មាន ២.៦០% មិនសំខាន់ ១៣% សំខាន់តិចតួច ២៤.៤០% មធ្យម ៣៤% សំខាន់ និង ២៤% សំខាន់ណាស់
- **កម្មវិធីអប់រំពិសេស** ៖ មាន ២.៥០% មិនសំខាន់ ១៨% សំខាន់តិចតួច ៣២% មធ្យម ៣០% សំខាន់ និង ១៧.៥០% សំខាន់ណាស់
- **កម្មវិធីអាហារូបករណ៍សិស្សក្រីក្រ** ៖ មាន ១% មិនសំខាន់ ២៣% សំខាន់តិចតួច ១៩.៧០% មធ្យម ៤៣% សំខាន់ និង ១៣.៣០% សំខាន់ណាស់
- **កម្មវិធីអប់រំសុខភាព និងអនាម័យ** ៖ មាន ៦% មិនសំខាន់ ១៦% សំខាន់តិចតួច ៣១% មធ្យម ៣០% សំខាន់ និង ១៧% សំខាន់ណាស់
- **ការងារក្រុមប្រឹក្សាកុមារ** ៖ មាន ៩% មិនសំខាន់ ១១.៥០% សំខាន់តិចតួច ៣១.៥០% មធ្យម ៣០% សំខាន់ និង ១៨% សំខាន់ណាស់
- **ការអប់រំកាយ និងកីឡា** ៖ មាន ៦% មិនសំខាន់ ១៣% សំខាន់តិចតួច ៣៧% មធ្យម ៣២% សំខាន់ និង ១២% សំខាន់ណាស់

*ក្រាហ្វិក ៦.២.៦.២. ស្ថានភាពនៃការអនុវត្តកម្មវិធីគាំទ្រការអប់រំអនុវិស័យបឋមសិក្សា*




| | កម្មវិធីពហុភាសារ | កម្មវិធីពន្លឿនការសិក្សា | កម្មវិធីស្បៀងអាហារតាមសាលារៀន | កម្មវិធីអប់រំពិសេស | កម្មវិធីអាហាររូបករសិស្សក្រីក្រ | កម្មវិធីអប់រំសុខផាពនិងអនាម័យ | កម្មវិធីក្រុមប្រឹក្សាកុមារ | កម្មវិធីអប់រំកាយនិងកីឡា |
|---|---|---|---|---|---|---|---|---|
| មិនសំខាន់ | 5 | 2.8 | 2.6 | 2.5 | 1 | 6 | 9 | 6 |
| សំខាន់តិចតួច | 12 | 13 | 13 | 18 | 23 | 16 | 11.5 | 13 |
| ធម្មតា | 33 | 32.7 | 24.4 | 32 | 19.7 | 31 | 31.5 | 37 |
| សំខាន់ | 38 | 41.4 | 34 | 30 | 43 | 30 | 30 | 32 |
| សំខាន់ណាស់ | 12 | 10.1 | 24 | 17.5 | 13.3 | 17 | 18 | 12 |

មិនសំខាន់ សំខាន់តិចតួច ធម្មតា សំខាន់ សំខាន់ណាស់

## ៣. ទស្សនៈយល់ឃើញចំពោះការងារគ្រប់គ្រងគ្រូបឋមសិក្សា

ផ្អែកតាមក្រាហ្វិក **៦.២.៦.៣.** បានបង្ហាញថា អ្នកផ្តល់ព័ត៌មានជានាយក/នាយិកាសាលាបឋមសិក្សា ចំនួន **៦៩១នាក់** បានបង្ហាញអំពីការយល់ឃើញដូចលទ្ធផលខាងក្រោម៖

- **ការសុំច្បាប់ឈប់សម្រាក៖** មាន ៦% មិនពេញចិត្តសោះ ៣៣% មិនពេញចិត្ត ៩% ធម្មតា ២៧% ពេញចិត្ត ២៥% ពេញចិត្តខ្លាំង
- **ការតម្លើងកាំ៖** មាន ៥% មិនពេញចិត្តសោះ ២៣% មិនពេញចិត្ត ២៨% ធម្មតា ២៧% ពេញចិត្ត ១៧% ពេញចិត្តខ្លាំង
- **ការតែងតាំងឋានន្តរស័ក្តិ៖** មាន ៥% មិនពេញចិត្តសោះ ២០% មិនពេញចិត្ត ៣២% ធម្មតា ២១% ពេញចិត្ត ២២% ពេញចិត្តខ្លាំង
- **ការលំហែមាតុភាព៖** មាន ២% មិនពេញចិត្តសោះ ១៨% មិនពេញចិត្ត ៣០% ធម្មតា ២៩% ពេញចិត្ត ២១% ពេញចិត្តខ្លាំង
- **ការផ្លាស់ប្តូរ៖** មាន ៧% មិនពេញចិត្តសោះ ៩% មិនពេញចិត្ត ៤៨% ធម្មតា ២៦% ពេញចិត្ត ១០% ពេញចិត្តខ្លាំង
- **ការដាក់ពិន័យ៖** មាន ៥% មិនពេញចិត្តសោះ ១៩% មិនពេញចិត្ត ៤៣% ធម្មតា ២២% ពេញចិត្ត ១១% ពេញចិត្តខ្លាំង។

ក្រាហ្វិក ៦.២.៦.៣. កម្រិតយល់ឃើញចំពោះការងារគ្រប់គ្រងគ្រូបឋមសិក្សា




| | សុំច្បាប់ឈប់សម្រាក | ការតម្លើងកាំ | ការតែងតាំងឋានន្តរសក្តិ | ការលំហែមាតុភាព | ការផ្លាស់ប្តូរ | ការដាក់ពិន័យ |
|---|---|---|---|---|---|---|
| មិនពេញចិត្តសោះ | 6 | 5 | 5 | 2 | 7 | 5 |
| មិនពេញចិត្ត | 33 | 23 | 20 | 18 | 9 | 19 |
| ធម្មតា | 9 | 28 | 32 | 30 | 48 | 43 |
| ពេញចិត្ត | 27 | 27 | 21 | 29 | 26 | 22 |
| ពេញចិត្តខ្លាំង | 25 | 17 | 22 | 21 | 10 | 11 |

មិនពេញចិត្តសោះ　មិនពេញចិត្ត　ធម្មតា　ពេញចិត្ត　ពេញចិត្តខ្លាំង

## ៤. ការប្រើប្រាស់កញ្ចប់ថវិកាសម្រាប់ដំណើរការសាលារៀនធៀបទៅនឹងផែនការ និងតម្រូវការជាក់ស្តែង

ផ្អែកតាមក្រាហ្វិក **៦.២.៦.៤.** បានបង្ហាញ អ្នកផ្តល់ព័ត៌មានជានាយក/នាយិកាសាលាបឋមសិក្សាចំនួន **៦៣៨នាក់** បានបង្ហាញថា ការយល់ឃើញអំពីការប្រើប្រាស់មូលនិធិដំណើរការសាលារៀនធៀបទៅនឹងផែនការ និងតម្រូវការជាក់ស្តែង នាពេលកន្លងមក មានចំនួន ៣.៩០% ប្រើប្រាស់បានតិចតួច ១៥.៨០% មធ្យម ៣៧.៥០% បានបង្គួរ និង ៤២.៨០% បានពេញលេញ។

ក្រាហ្វិក ៦.២.៦.៤.




## ៥. ការប្រើប្រាស់មូលនិធិក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ជួយគាំទ្រដល់ដំណើរការសាលារៀន

ផ្អែកតាមក្រាហ្វិក **៦.២.៦.៥.** បានបង្ហាញអំពីការយល់ឃើញរបស់ក្រុមអ្នកផ្តល់ព័ត៌មានជានាយក/នាយិកាសាលាបឋមសិក្សាចំនួន **៦៣៦នាក់** បានលើកឡើងអំពីការប្រើប្រាស់ថវិកាពីមូលនិធិរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ដើម្បីជួយគាំទ្រដល់សាលារៀន ដែលក្នុងនោះរួមមាន ៣.២០% ប្រើប្រាស់បានពេញលេញ ៥.៥០% បង្គួរ ៤.៥០% មធ្យម ២៦.៤០% ប្រើប្រាស់បានតិចតួច និង៦០.៤០% មិនបានប្រើប្រាស់។

ក្រាហ្វិក ៦.២.៦.៥.



## ៦. ការដាក់បញ្ចូលផែនការសកម្មភាពជាអាទិភាពនានានៃវិស័យអប់រំទៅក្នុងផែនការអភិវឌ្ឍន៍ ០៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ក្រុង ស្រុក ខណ្ឌនៅក្នុងឆ្នាំ២០២៣

ផ្អែកតាមក្រាហ្វិក **៦.២.៦.៦.** បានបង្ហាញថា អ្នកផ្តល់ព័ត៌មានជានាយក/នាយិកាសាលាបឋមសិក្សាចំនួន **៦១៣នាក់** បានលើកឡើងថា ផែនការសកម្មភាពនានារបស់វិស័យអប់រំ យុវជន និងកីឡាបានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍០៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ រួមមាន៖

- ផែនការយុទ្ធសាស្រ្ត និងផែនការប្រតិបត្តិការប្រចាំឆ្នាំស្តីពីការអប់រំបឋមសិក្សាមានចំនួន ៧៩.៦០%
- ផែនការអភិវឌ្ឍន៍សាលារៀនសម្រាប់ការអប់រំបឋមសិក្សាមានចំនួន ៦១.៨០%
- ផែនការអភិឌ្ឍន៍សមត្ថភាពគ្រូបង្រៀនមានចំនួន ២៨.៤០%។

*ក្រាហ្វិក ៦.២.៦.៦.*




## ៧. ការអនុវត្តផែនការជាក់ស្តែងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

ផ្អែកតាមក្រាហ្វិក ៦.២.៦.៧. អ្នកផ្តល់ព័ត៌មានជានាយក/នាយិកាសាលាបឋមសិក្សាចំនួន ៦៦៤នាក់ បានលើកឡើងថារដ្ឋបាលក្រុង ស្រុក ខណ្ឌបានអនុវត្តផែនការជាក់ស្តែងមានលទ្ធផលដូចខាងក្រោម៖

១) **ផែនការប្រតិបត្តិការប្រចាំឆ្នាំស្តីពីការអប់រំបឋមសិក្សា៖** ៤% បានតិចតួច ៤៩% មធ្យម ២៤% បានបង្គួរ ២៣% បានពេញលេញ

២) **ផែនការអភិវឌ្ឍន៍សាលារៀនសម្រាប់ការអប់រំបឋមសិក្សា៖** ៥% បានតិចតួច ២៥% មធ្យម ៥៣% បានបង្គួរ និង ១៧% បានពេញលេញ

៣) **ផែនការអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀន៖** ១៣% បានតិចតួច ៣០% មធ្យម ៤៩% បង្គួរ និង ៨% បានពេញលេញ។

**ក្រាហ្វិក ៦.២.៦.៧. ការអនុវត្តផែនការជាក់ស្តែងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ**



### ៨. ទំនាក់ទំនងការងាររវាងសាលាបឋមសិក្សា និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់

ផ្អែកតាមក្រាហ្វិក **៦.២.៦.៨.** អ្នកផ្តល់ព័ត៌មានជានាយក/នាយិកាសាលាបឋមសិក្សាចំនួន **៦៥៣នាក់** បានលើកឡើងអំពីទំនាក់ទំនងការងាររវាងសាលាបឋមសិក្សាជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់មានលទ្ធផលដូចខាងក្រោម៖

- **ទំនាក់ទំនងជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ**៖ ១% មិនពេញចិត្តសោះ ៣% ពេញចិត្តតិចតួច ៣៤% មធ្យម ៥០% ពេញចិត្ត និង ១២% ពេញចិត្តខ្លាំង
- **ទំនាក់ទំនងជាមួយរដ្ឋបាលឃុំ សង្កាត់** ៖ ២% មិនពេញចិត្តសោះ ២% ពេញចិត្តតិចតួច ៣៣% មធ្យម ៥២% ពេញចិត្ត និង ១១% ពេញចិត្តខ្លាំង។

ក្រាហ្វិក ៦.២.៦.៨. ទំនាក់ទំនងការងាររវាងសាលារៀនបឋមសិក្សា និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់




### ៩. បញ្ហាប្រឈមនានាក្នុងការទំនាក់ទំនងការងាររវាងសាលារៀន និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់

ផ្អែកតាមការផ្តល់ព័ត៌មានពីនាយក/នាយិកាសាលាបឋមសិក្សាចំនួន **៦៥៣នាក់** បានបង្ហាញថាមានបញ្ហាប្រឈមជាគន្លឹះមួយចំនួនក្នុងទំនាក់ទំនងការងាររវាងសាលារៀនជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ រួមមានដូចខាងក្រោម៖

- ទម្រង់លិខិតរដ្ឋបាលនៅមិនទាន់កំណត់ច្បាស់លាស់ និងនីតិវិធីរដ្ឋបាលមានលក្ខណៈស្មុគស្មាញ
- កិច្ចសហការ ការចូលរួមគាំទ្រ និងការយកចិត្តទុកដាក់ពីរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់មួយចំនួនលើការងារសាលារៀននៅមានកម្រិត
- រដ្ឋបាលស្រុកមួយចំនួននៅមិនយកចិត្តទុកដាក់ក្នុងការដាក់បញ្ចូលផែនការអាទិភាពនានារបស់សាលារៀនទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- សាលារៀននៅពុំទាន់យល់ច្បាស់អំពីខ្សែគណនេយ្យភាព និងការទទួលខុសត្រូវរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ការអន្តរាគមន៍របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការដោះស្រាយបញ្ហាប្រឈមមួយចំនួននៅសាលារៀននៅមិនទាន់ឆ្លើយតបទៅតាមតម្រូវការ។

ជារួម ការកែសម្រួល និងការពង្រឹងយន្តការគាំទ្រ ការអភិវឌ្ឍសមត្ថភាព ការតាមដានត្រួតពិនិត្យដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីជានាឱ្យការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំដែលបាន

ផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌអាចអនុវត្តបានដោយរលូនប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ជាពិសេសធានាបាននូវគុណភាពសេវាអប់រំកាន់តែល្អប្រសើរជាលំដាប់។

### ១០.ការគ្រប់គ្រង និងការគាំទ្ររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ចំពោះមុខងារការអប់រំបឋមសិក្សាកន្លងមក

ផ្អែកតាមក្រាហ្វិក **៦.២.៦.៩.** អ្នកផ្តល់ព័ត៌មានជានាយក/នាយិកាសាលាបឋមសិក្សាចំនួន **៣១៥នាក់** បានលើកឡើងថា ការគ្រប់គ្រងនិងគាំទ្ររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌចំពោះមុខងារអប់រំបឋមសិក្សាមានដូចលទ្ធផលខាងក្រោម៖

- **ការរៀបចំផែនការ ៖** ៥% មិនបានគាំទ្រ ១៤% គាំទ្រតិចតួច ៤១% មធ្យម ៣៥% គាំទ្រច្រើន និង ៥% គាំទ្រច្រើនណាស់
- **ការពិនិត្យតាមដាន និងវាយតម្លៃ** ៖ ៥% មិនបានគាំទ្រ ១៤% គាំទ្រតិចតួច ៤០% មធ្យម ៣៦% គាំទ្រច្រើន និង ៥% គាំទ្រច្រើនណាស់
- **ការគ្រប់គ្រងគ្រូបង្រៀនបឋមសិក្សា ៖** ៥% មិនបានគាំទ្រ ១៣.៥០% គាំទ្រតិចតួច ៤១% មធ្យម ៣៥% គាំទ្រច្រើន និង ៥.៥០% គាំទ្រច្រើនណាស់
- **ការគ្រប់គ្រងហិរញ្ញវត្ថុ ៖** ៦.៥០% មិនបានគាំទ្រ ១៣% គាំទ្រតិចតួច ៣៨% មធ្យម ៣៦% គាំទ្រច្រើន និង ៦.៥០% គាំទ្រច្រើនណាស់
- **ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ** ៖ ៧% មិនបានគាំទ្រ ១៣% គាំទ្រតិចតួច ៣៥% មធ្យម ៣៨% គាំទ្រច្រើន និង ៧% គាំទ្រច្រើនណាស់
- **សន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ និងបរិស្ថាននៅតាមសាលារៀន** ៖ ៤% មិនបានគាំទ្រ ១៣.៥០% គាំទ្រតិចតួច ៣៥.៥០% មធ្យម ៣៦% គាំទ្រច្រើន និង ១១% គាំទ្រច្រើនណាស់
- **ការកៀរគរធនធានសម្រាប់ការអភិវឌ្ឍសាលារៀន** ៖ ៨% មិនបានគាំទ្រ ១៥% គាំទ្រតិចតួច ៣៤% មធ្យម ៣៣% គាំទ្រច្រើន និង ១០% គាំទ្រច្រើនណាស់។

ក្រាហ្វិក ៦.២.៦.៩. ការគាំទ្ររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌចំពោះមុខងារអប់រំបឋមសិក្សាកន្លងមក



### ៦.២.៧. ក្រុមអ្នកផ្តល់ព័ត៌មានជាប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍

#### ១. ការដឹកនាំ គ្រប់គ្រង និងចាត់ចែងកម្មវិធីអប់រំក្រៅប្រព័ន្ធ (ឆ្នាំ២០២៣)

ផ្អែកតាមក្រាហ្វិក **៦.២.៧.១.** បង្ហាញថាអ្នកផ្តល់ព័ត៌មានជាប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន **៦០នាក់** បានលើកឡើងថា ការដឹកនាំគ្រប់គ្រង និងចាត់ចែងកម្មវិធីអប់រំក្រៅប្រព័ន្ធមាន ៣.៤០% មិនពេញចិត្ត ៥% ពេញចិត្តតិចតួច ៥% ធម្មតា ៦៣.៣% ពេញចិត្ត និង ២៣.៣០% ពេញចិត្តខ្លាំង។




#### ២. ការប្រើប្រាស់ថវិកាមូលនិធិក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ជួយគាំទ្រដល់កម្មវិធីអប់រំក្រៅប្រព័ន្ធ

ផ្អែកតាមក្រាហ្វិក **៦.២.៧.២.** អ្នកផ្តល់ព័ត៌មានជាប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន **៦១នាក់** បានលើកឡើងអំពីការប្រើប្រាស់ថវិកាមូលនិធិក្រុង ស្រុក ខណ្ឌ និងឃុំសង្កាត់ ដើម្បីគាំទ្រក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធនាពេលកន្លងមករួមមានដូចខាងក្រោម៖ ៦២.៣០% មិនបានប្រើថវិកាគាំទ្រ ១៨% ប្រើតិចតួច ៧% ប្រើមធ្យម ៩.៨០% ប្រើបង្គួរ និង ២.៩០% បានគាំទ្រពេញលេញ។




#### ៣. ផែនការសកម្មភាពដែលបានដាក់បញ្ចូលទៅក្នុងសកម្មភាពអាទិភាពវិស័យអប់រំនៃផែនការវិនិយោគបីឆ្នាំរំកិលរបស់ក្រុង ស្រុក ខណ្ឌ

ផ្អែកតាមក្រាហ្វិក **៦.២.៧.៣.** បានបង្ហាញថា អ្នកផ្តល់ព័ត៌មានជាប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន **៥៥នាក់** បានលើកឡើងថា សកម្មភាពអាទិភាពវិស័យអប់រំត្រូវបានដាក់បញ្ចូលទៅក្នុងផែនការវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ រួមមានដូចខាងក្រោម៖

- ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំឆ្នាំស្តីពីការអប់រំក្រៅប្រព័ន្ធ ៣៨.២០%
- ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍ ៦០%
- ផែនការប្រើប្រាស់គ្រូជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ ៥៦.៤០%។




### ៤. ការអនុវត្តផែនការជាក់ស្ដែងនៅក្នុងឆ្នាំ២០២៣កន្លងមក

ផ្អែកតាមតារាង **៦.២.៧.៤.** បានបង្ហាញថា អ្នកផ្ដល់ព័ត៌មានជាប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន **៥៥នាក់** បានលើកឡើងពីកម្រិតយល់ឃើញនៃការអនុវត្តផែនការជាក់ស្ដែងដូចមានក្នុងតារាងខាងក្រោម៖

**តារាង ៦.២.៧.៤៖ កម្រិតយល់ឃើញនៃការអនុវត្តផែនការជាក់ស្ដែងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ**

| ល.រ | ប្រភេទផែនការ | បានតិចតួច (ភាគរយ) | មធ្យម (ភាគរយ) | បានបង្គួរ (ភាគរយ) | បានពេញលេញ (ភាគរយ) |
|---|---|---|---|---|---|
| ១ | ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំឆ្នាំស្ដីពីការអប់រំក្រៅប្រព័ន្ធ | ១៩.៥០ | ៣៧.៥៨ | ៤៣.០០ | 0.00 |
| ២ | ផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍ | ១៨.០៥ | ៣៥.៥១ | ៤៣.០០ | ៣.៤៤ |
| ៣ | ផែនការប្រើប្រាស់គ្រូកិច្ចសន្យាអប់រំក្រៅប្រព័ន្ធ | ១៣.៥៤ | ២៩.៨៦ | ៤៨.០០ | ៨.៦០ |

### ៥. ទំនាក់ទំនងការងាររវាងរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់

ផ្អែកតាមក្រាហ្វិក **៦.២.៧.៥.** បានបង្ហាញថា អ្នកផ្ដល់ព័ត៌មានជាប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន **៤៥នាក់** បានលើកឡើងថា ទំនាក់ទំនងការងាររវាងរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ អំពីការងារអប់រំក្រៅប្រព័ន្ធ រួមមានដូចខាងក្រោម៖

- **ទំនាក់ទំនងជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ** ៖ ២% មិនពេញចិត្តសោះ ៣៨% មិនពេញចិត្ត ៤០.៣៨% ធម្មតា ៤០.៣៨% ពេញចិត្ត និង ១៣.១៦% ពេញចិត្តខ្លាំង

- **ទំនាក់ទំនងជាមួយរដ្ឋបាលឃុំ សង្កាត់** ៖ ១.៨០% មិនពេញចិត្តសោះ ៣.៦% មិនពេញចិត្ត ៣៨% ធម្មតា ៣៨.៣៦% ពេញចិត្ត និង ១៨.១៨% ពេញចិត្តខ្លាំង។

**ក្រាហ្វិក ៦.២.៧.៥. ទំនាក់ទំនងរវាងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងការងារអប់រំក្រៅប្រព័ន្ធ**




### ៦. បញ្ហាប្រឈមជាគន្លឹះក្នុងទំនាក់ទំនងការងាររវាងសាលារៀន និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់

អ្នកផ្តល់ព័ត៌មានជាប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន **៤៥នាក់** បានលើកឡើងអំពីបញ្ហាប្រឈមជាគន្លឹះមួយចំនួនក្នុងការងារទំនាក់ទំនងរវាងសាលារៀន និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់រួមមាន៖

- ទំនាក់ទំនងការងារនៅមានកម្រិត ព្រោះមិនសូវបានយកចិត្តទុកដាក់លើការងារអប់រំក្រៅប្រព័ន្ធ
- ខ្វះការផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក
- កិច្ចសហការរវាងរដ្ឋបាលក្រុង ស្រុក រដ្ឋបាលឃុំ សង្កាត់ និងមជ្ឈមណ្ឌលសិក្សាសហគមន៍នៅមិនទាន់ល្អប្រសើរ។

## ៦.២.៨. ក្រុមអ្នកផ្តល់ព័ត៌មានជាគ្រូបង្រៀន

### ១. ការធ្វើសមាហរណកម្មការិយាល័យអប់រំ យុវជន និងកីឡាទៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌកន្លងមក

ផ្អែកតាមក្រាហ្វិក **៦.២.៨.១.** បានបង្ហាញថា អ្នកផ្តល់ព័ត៌មានជាគ្រូបង្រៀនចំនួន **១,៣៦៩នាក់** មានមតិលើកឡើងថា ការធ្វើសមាហរណកម្មការិយាល័យអប់រំ យុវជន និងកីឡាទៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ រួមមានលទ្ធផល៖ ២.៥០% មិនត្រឹមត្រូវ ៣៤.១០% ធម្មតា និង ៦៣.៤០% ត្រឹមត្រូវ។

ក្រាហ្វិក ៦.២.៨.១.



## ២. ការងារពាក់ព័ន្ធទៅនឹងការងារគ្រប់គ្រងបុគ្គលិក (គ្រូបង្រៀន)

ផ្អែកតាមក្រាហ្វិក **៦.២.៨.២.** បានបង្ហាញថាអ្នកផ្តល់ព័ត៌មានជាគ្រូបង្រៀនចំនួន **១,៣៦០នាក់** បានលើកឡើងអំពីទស្សនៈយល់ឃើញចំពោះការងារពាក់ព័ន្ធទៅនឹងការងារគ្រប់គ្រងបុគ្គលិក រួមមានលទ្ធផលដូចខាងក្រោម៖

- **ការសុំច្បាប់ឈប់សម្រាក៖** មានចំនួន ១% មិនពេញចិត្តសោះ ៤% មិនពេញចិត្ត ៤៣% ធម្មតា ៤៨% ពេញចិត្ត និង ៤% ពេញចិត្តខ្លាំង
- **ការតម្លើងកាំប្រាក់៖** មានចំនួន ២% មិនពេញចិត្តសោះ ១១% មិនពេញចិត្ត ១៥% ធម្មតា ៥៨% ពេញចិត្ត និង ៤% ពេញចិត្តខ្លាំង
- **ការតែងតាំងឋានន្តរស័ក្តិ៖** មានចំនួន ១% មិនពេញចិត្តសោះ ៦% មិនពេញចិត្ត ៣៨% ធម្មតា ៤៤% ពេញចិត្ត និង ១១% ពេញចិត្តខ្លាំង
- **ការសម្រាកលំហែមាតុភាព៖** មានចំនួន ១% មិនពេញចិត្តសោះ ៣% មិនពេញចិត្ត ៣៩% ធម្មតា ៤៧% ពេញចិត្ត ១០% ពេញចិត្តខ្លាំង
- **ការផ្លាស់ប្តូរ៖** មានចំនួន ១% មិនពេញចិត្តសោះ ៩% មិនពេញចិត្ត ៥៥% ធម្មតា ៣១% ពេញចិត្ត និង ៤% ពេញចិត្តខ្លាំង
- **ការដាក់ពិន័យ៖** មានចំនួន ២% មិនពេញចិត្តសោះ ១៣% មិនពេញចិត្ត ៥៦% ធម្មតា ២៦% ពេញចិត្ត និង ៣% ពេញចិត្តខ្លាំង។

ក្រាហ្វិក ៦.២.៨.២. ការងារពាក់ព័ន្ធទៅនឹងការគ្រប់គ្រងបុគ្គលិក (គ្រូបង្រៀន)




## ៣. ការចូលរួមគាំទ្រអន្តរាគមន៍ពាក់ព័ន្ធនឹងការងារគ្រប់គ្រងរបស់សាលារៀន

### ក. ការងារគ្រប់គ្រងសិស្ស

ផ្អែកតាមក្រាហ្វិក **៦.២.៨.៣.** បានបង្ហាញថាអ្នកផ្តល់ព័ត៌មានជាគ្រូបង្រៀនចំនួន **១,៣៧១នាក់** បានលើកឡើងថារដ្ឋបាលក្រុង ស្រុក ខណ្ឌ បានចូលរួមគាំទ្រច្រើនពាក់ព័ន្ធទៅនឹងការងារគ្រប់គ្រងរបស់សាលារៀន ដែលមានលទ្ធផលដូចខាងក្រោម៖

- **ការគ្រប់គ្រងទិន្នន័យកុមារដល់វ័យសិក្សា៖** មានចំនួន ៤% បានគាំទ្រតិចតួច ២៣% មធ្យម ៤៤% បានបង្គួរ និង ២៩% បានពេញលេញ
- **យុទ្ធនាការប្រមូលកុមារចូលរៀន៖** មានចំនួន ២% បានគាំទ្រតិចតួច ១១% មធ្យម ៣៧% បានបង្គួរ និង ៥០% បានពេញលេញ
- **ការជួយកុមារ សិស្សជួបការលំបាកនិងងាយបោះបង់ការសិក្សា៖** មានចំនួន ១% មិនបានគាំទ្រសោះ ៥% បានតិចតួច ២៦% មធ្យម ៤៩% បានបង្គួរ និង ១៩% បានពេញលេញ។




## ខ. ការងារគ្រប់គ្រងគ្រូបង្រៀន

ផ្អែកតាមក្រាហ្វិក **៦.២.៨.៤.** មានបង្ហាញថា អ្នកផ្ដល់ព័ត៌មានជាគ្រូបង្រៀនចំនួន **១,៣៧១នាក់** បានលើកឡើងអំពីការចូលរួមគាំទ្ររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌពាក់ព័ន្ធនឹងការងារគ្រប់គ្រងគ្រូបង្រៀន រួមមានលទ្ធផលដូចខាងក្រោម៖

- **ការបំពេញការងាររបស់គ្រូបង្រៀន (វត្តមាន)៖** មានចំនួន ២% មិនបានគាំទ្រសោះ ៤% បានតិចតួច ២៥% មធ្យម ៣៩% បានបង្គួរ និង ៣០% បានពេញលេញ
- **ការគ្រប់គ្រងទិន្នន័យគ្រូបង្រៀន (លើស ឬខ្វះ)៖** មានចំនួន ២% មិនបានគាំទ្រសោះ ៤% បានតិចតួច ២៥% មធ្យម ៣៩% បានបង្គួរ និង ៣០% បានពេញលេញ
- **ការងារជួយលោកគ្រូ អ្នកគ្រូ (កន្លែងស្នាក់នៅសម្រាប់គ្រូបង្រៀនចេញថ្មីដែលជួបការលំបាក)៖** មានចំនួន ១៦% មិនបានគាំទ្រសោះ ១៤% បានតិចតួច ២៨% មធ្យម ២៣% បានបង្គួរ និង ១៩% បានពេញលេញ។



### គ. ការងារផែនការហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់សាលារៀន

ផ្អែកតាមក្រាហ្វិក **៦.២.៨.៥.** បានបង្ហាញថាអ្នកផ្ដល់ព័ត៌មានជាគ្រូបង្រៀនចំនួន **១,៣៧១នាក់** បានលើកឡើងអំពីការចូលរួមគាំទ្ររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌពាក់ព័ន្ធទៅនឹងការងារផែនការ ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់សាលារៀន រួមមានដូចខាងក្រោម៖

- **ចូលរួមធ្វើផែនការផ្សេងៗរបស់សាលារៀន៖** មានចំនួន ១% មិនបានគាំទ្រសោះ ៥% បានតិចតួច ១៧% មធ្យម ៤៤% បានបង្គួរ និង ៣៣% បានពេញលេញ
- **ពិនិត្យតាមដានការប្រើប្រាស់មូលនិធិដំណើរការសាលារៀន៖** មានចំនួន ១% មិនបានគាំទ្រសោះ ៤% បានតិចតួច ១៧% មធ្យម ៣៦% បានបង្គួរ និង ៤២% បានពេញលេញ
- **ពិនិត្យតាមដានការប្រើប្រាស់ទ្រព្យសម្បត្តិរបស់សាលារៀន៖** មានចំនួន ១% មិនបានគាំទ្រសោះ ៤% បានតិចតួច ១៨% មធ្យម ៤០% បានបង្គួរ និង ៣៧% បានពេញលេញ
- **ការធ្វើរបាយការណ៍ជូនអ្នកពាក់ព័ន្ធ៖** មានចំនួន ១% មិនបានគាំទ្រសោះ ៤% បានតិចតួច ១៨% មធ្យម ៤០% បានបង្គួរ និង ៣៧% បានពេញលេញ
- **ការអនុវត្តស្តង់ដាសាលារៀនគំរូ៖** មានចំនួន ១% មិនបានគាំទ្រសោះ ៦% បានតិចតួច ២៨% មធ្យម ៣៨% បានបង្គួរ និង ២៧% បានពេញលេញ។

ក្រាហ្វិក ៦.២.៨.៥. ការងារផែនការ ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់សាលា



### ៦.២.៩. ក្រុមអ្នកផ្តល់ព័ត៌មានមកពីមេឃុំ ចៅសង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់

#### ១. ការយល់ដឹងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីគោលនយោបាយ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ

ផ្អែកតាមក្រាហ្វិក **៦.២.៩.១.** បានបង្ហាញកម្រិតនៃការយល់ដឹងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ **ចំនួន ៨៩នាក់** អំពីគោលនយោបាយ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ រួមមាន៖ ១៩.១០% យល់ដឹងតិចតួច ៥២.៨០% យល់ដឹងមធ្យម ២១.៣០% យល់ដឹងបង្គួរ និង ៦.៨០% យល់ដឹងពេញលេញ។



ក្រាហ្វិក ៦.២.៩.១.

#### ២. ការយល់ដឹងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ចំពោះផែនការយុទ្ធសាស្ត្រ សូចនាករមុខងារអប់រំ

ផ្អែកតាមក្រាហ្វិក **៦.២.៩.២.** បានបង្ហាញថាអ្នកផ្តល់ព័ត៌មានជាក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន **៩៧នាក់** បានលើកឡើងអំពីកម្រិតយល់ដឹងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ចំពោះផែនការយុទ្ធសាស្ត្រ សូចនាករមុខងារអប់រំទាំងបី រួមមានដូចខាងក្រោម៖

- **ការគ្រប់គ្រងការអប់រំកុមារតូច៖** មានចំនួន ៩% មិនយល់ ២៣% យល់ដឹងតិចតួច ៤៦% យល់ដឹងមធ្យម និង ២២% យល់ដឹងបង្គួរ
- **ការគ្រប់គ្រងការអប់រំបឋមសិក្សា៖** មានចំនួន ៩% មិនយល់ ២២% យល់ដឹងតិចតួច ៤០% យល់ដឹងមធ្យម ៣៨.៣៦% យល់បង្គួរ និង ២% យល់ដឹងច្រើន
- **ការគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ៖** មានចំនួន ៩% មិនយល់ ៣៦% យល់ដឹងតិចតួច ៤២% យល់ដឹងមធ្យម និង ២៧% យល់បង្គួរ។

ក្រាហ្វិក ៦.២.៩.២. កម្រិតយល់ដឹងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់លើផែនការយុទ្ធសាស្ត្រ សូចនាករមុខងារទាំងបី



## ៣. ការចូលរួមគាំទ្រអន្តរាគមន៍នៃរដ្ឋបាលឃុំ សង្កាត់លើកម្មវិធីនានាពាក់ព័ន្ធទៅនឹងអនុវិស័យការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ

### ក. ការអប់រំកុមារតូច

ផ្អែកតាមក្រាហ្វិក **៦.២.៩.៣.ក.** បានបង្ហាញថា អ្នកផ្តល់ព័តមានជាមេឃុំ ចៅសង្កាត់ចំនួន **៧៩នាក់** បានលើកឡើងអំពីការចូលរួមគាំទ្ររបស់រដ្ឋបាលឃុំ សង្កាត់លើការងារគ្រប់គ្រងកម្មវិធីមត្តេយ្យសិក្សារដ្ឋ រួមមានដូចខាងក្រោម៖

- **ការគ្រប់គ្រងកម្មវិធីមត្តេយ្យសិក្សារដ្ឋ**៖ មានចំនួន ២១% មិនបានគាំទ្រ ៥០% បានគាំទ្រ ១ដង ១៥% បានគាំទ្រ ២ដង ១០% បានគាំទ្រ ៣ដង និង ១៧% បានគាំទ្រច្រើនជាង ៤ដង
- **កម្មវិធីអប់រំបរិយាបន្ន និងពហុភាសា**៖ មានចំនួន ២៨% មិនបានគាំទ្រ ១៨% បានគាំទ្រ ១ដង ២៥% បានគាំទ្រ ២ដង ៣០% បានគាំទ្រ ៣ដង និង ២៧% បានគាំទ្រច្រើនជាង ៤ដង
- **កម្មវិធីអាហារូបត្ថម្ភ**៖ មានចំនួន ២៣% មិនបានគាំទ្រ ២៣% បានគាំទ្រ ១ដង ២៦% បានគាំទ្រ ២ដង ៣០%បានគាំទ្រ ៣ដង និង ២៥% បានគាំទ្រច្រើនជាង ៤ដង
- **កម្មវិធីជួយកុមារក្រីក្រ**៖ មានចំនួន ១៣% មិនបានគាំទ្រ ៣% បានគាំទ្រ ១ដង ១៨% បានគាំទ្រ ២ដង ១៥% បានគាំទ្រ ៣ដង និង ១៤% បានគាំទ្រច្រើនជាង ៤ដង
- **កម្មវិធីអប់រំមាតាបិតា**៖ មានចំនួន ១៥% មិនបានគាំទ្រ ៦%បានគាំទ្រ ១ដង ១៦% បានគាំទ្រ ២ដង ១៥% បានគាំទ្រ ៣ដង និង ១៧% បានគាំទ្រច្រើនជាង ៤ដង។

ក្រាហ្វិក ៦.២.៩.៣.ក. ការអប់រំកុមារតូច




### ខ. ការអប់រំបឋមសិក្សា

ផ្អែកតាមក្រាហ្វិក **៦.២.៩.៣.ខ.** បានបង្ហាញថា អ្នកផ្តល់ព័តមានជាមេឃុំ ចៅសង្កាត់ចំនួន **៧៩នាក់** បានលើកឡើងអំពីការចូលរួមគាំទ្ររបស់រដ្ឋបាលឃុំ សង្កាត់លើការងារគ្រប់គ្រងកម្មវិធីបឋមសិក្សារដ្ឋ រួមមានដូចខាងក្រោម៖

- **កម្មវិធីអប់រំពហុភាសា**៖ មានចំនួន ៤៩% មិនគាំទ្របាន ១៧% បានគាំទ្រ ១ដង ២៨% បានគាំទ្រ ២ដង និង ៦% បានគាំទ្រច្រើនជាង ៤ដង

- **កម្មវិធីពន្លឿនការសិក្សា៖** មានចំនួន ២៣% មិនបានគាំទ្រ ២១% បានគាំទ្រ ១ដង ៣៧% បានគាំទ្រ ២ដង ៨% បានគាំទ្រ ៣ដង និង ១១% បានគាំទ្រច្រើនជាង ៤ដង
- **កម្មវិធីផ្តល់អាហារតាមសាលារៀន៖** មានចំនួន ២៥% មិនបានគាំទ្រ ២៥% បានគាំទ្រ ១ដង ២២% បានគាំទ្រ ២ដង ១៣% បានគាំទ្រ ៣ដង និង ១៥% បានគាំទ្រច្រើនជាង ៤ដង
- **កម្មវិធីអប់រំពិសេស** ៖ មានចំនួន ១៨.៥០% មិនបានគាំទ្រ ២៥% បានគាំទ្រ ១ដង ២១% បានគាំទ្រ ២ដង ១៨.៥០% បានគាំទ្រ ៣ដង និង ១៧% បានគាំទ្រច្រើនជាង ៤ដង
- **កម្មវិធីផ្តល់អាហារូបករណ៍សិស្សក្រីក្រ៖** មានចំនួន ១៨.៥០% មិនបានគាំទ្រ ២៥% បានគាំទ្រ ១ដង ២១% បានគាំទ្រ ២ដង ១៨.៥០% បានគាំទ្រ ៣ដង និង ១៧% បានគាំទ្រច្រើនជាង ៤ដង
- **កម្មវិធីសុខភាពនិងអនាម័យ៖** មានចំនួន ១៨.៥០% មិនបានគាំទ្រ ២៥% បានគាំទ្រ ១ដង ២១% បានគាំទ្រ ២ដង ១៨.៥០% បានគាំទ្រ ៣ដង និង ១៧% បានគាំទ្រច្រើនជាង ៤ដង។

ក្រាហ្វិក ៦.២.៩.៣.ខ. ការអប់រំបឋមសិក្សា




## គ. ការអប់រំក្រៅប្រព័ន្ធ

ផ្អែកតាមក្រាហ្វិក **៦.២.៩.៣.គ.** បានបង្ហាញថា អ្នកផ្តល់ព័តមានជាមេឃុំ ចៅសង្កាត់ចំនួន **៧៩នាក់** បានលើកឡើងអំពីការចូលរួមគាំទ្ររបស់រដ្ឋបាលឃុំ សង្កាត់លើការងារគ្រប់គ្រងកម្មវិធីអប់រំក្រៅប្រព័ន្ធ រួមមានដូចខាងក្រោម៖

- **ការងារការប្រមូល ការគ្រប់គ្រងសិស្សអ្នកសិក្សា និងអ្នកចូលរួម៖** មានចំនួន ២៧% មិនបានគាំទ្រ ២៣% បានគាំទ្រ ១ដង ១៧% បានគាំទ្រ ២ដង ១៦% បានគាំទ្រ ៣ដង និង ៧% បានគាំទ្រច្រើនជាង ៤ដង
- **កម្មវិធីអក្ខរកម្មវិជ្ជាជីវៈ៖** មានចំនួន ៤១% មិនបានគាំទ្រ ២៣% បានគាំទ្រ ១ដង ២៤% បានគាំទ្រ ២ដង ៨% បានគាំទ្រ ៣ដង និង ៣% បានគាំទ្រច្រើនជាង ៤ដង
- **កម្មវិធីក្រោយអក្ខរកម្ម៖** មានចំនួន ៥៥% មិនបានគាំទ្រ ៨% បានគាំទ្រ ១ដង ១៥% បានគាំទ្រ ២ដង ១២% បានគាំទ្រ ៣ដង និង ០% បានគាំទ្រច្រើនជាង ៤ដង

- **កម្មវិធីសមមូលបឋមសិក្សា៖** មានចំនួន ៣៨% មិនបានគាំទ្រ ២៥% បានគាំទ្រ ១ដង ២០% បានគាំទ្រ ២ដង ១៥% បានគាំទ្រ ៣ដង និង ២% បានគាំទ្រច្រើនជាង ៤ដង
- **កម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិ៖** មានចំនួន ៣៨% មិនបានគាំទ្រ ២៤% បានគាំទ្រ ១ដង ២៤% បានគាំទ្រ ២ដង និង ១៤% បានគាំទ្រ ៣ដង
- **កម្មវិធីបំពេញវិជ្ជា៖** មានចំនួន ៤២% មិនបានគាំទ្រ ៣២% បានគាំទ្រ ១ដង ៨% បានគាំទ្រ ២ដង ៤% បានគាំទ្រ ៣ដង និង ៤% បានគាំទ្រច្រើនជាង ៤ដង
- **កម្មវិធីបង្កើនប្រាក់ចំណូល៖** មានចំនួន ៣៤% មិនគាំទ្របាន ២៥% បានគាំទ្រ ១ដង ១៩% បានគាំទ្រ ២ដង ១២% បានគាំទ្រ ៣ដង និង ១០% បានគាំទ្រច្រើនជាង ៤ដង
- **កម្មវិធីចូលរៀនឡើងវិញ៖** មានចំនួន ២៦% មិនបានគាំទ្រ ៣៤% បានគាំទ្រ ១ដង ៣២% បានគាំទ្រ ២ដង ៥%បានគាំទ្រ ៣ដង និង ៣% បានគាំទ្រច្រើនជាង ៤ដង។

ក្រាហ្វិក ៦.២.៩.៣.គ. ការអប់រំក្រៅប្រព័ន្ធ




## ៤. ការអន្តរាគមន៍របស់រដ្ឋបាលឃុំ សង្កាត់ពាក់ព័ន្ធទៅនឹងការងាររបស់សាលារៀន

ផ្អែកតាមក្រាហ្វិក **៦.២.៩.៤.ក. ៦.២.៩.៤.ខ.** និងក្រាហ្វិក **៦.២.៩.៤.គ.** បានបង្ហាញថា អ្នកផ្ដល់ព័ត៌មានជាមេឃុំ ចៅសង្កាត់ចំនួន **៩៦នាក់** បានលើកឡើងពីកម្រិតនៃការចូលរួមអន្តរាគមន៍ពាក់ព័ន្ធទៅនឹងការងាររបស់សាលារៀន រួមមានដូចខាងក្រោម៖

### ក. ការគ្រប់គ្រងសិស្ស

- **គ្រប់គ្រងទិន្នន័យកុមារមិនបានចូលរៀន៖** មានចំនួន ៨% មិនបានគាំទ្រសោះ ១៣% បានតិចតួច ៣១% មធ្យម ៣២% បានបង្គួរ និង ១៦% បានពេញលេញ
- **យុទ្ធនាការប្រមូលកុមារចូលរៀន៖** មានចំនួន ១៧% មិនបានគាំទ្រសោះ ២២% បានតិចតួច ៣១% មធ្យម ១៩% បានបង្គួរ និង ១១% បានពេញលេញ
- **ការជួយកុមារ សិស្សជួបការលំបាក៖** មានចំនួន ១៩% មិនបានគាំទ្រសោះ ៦% បានតិចតួច ៣៥%មធ្យម ១៨%បានបង្គួរ និង ១២%បានពេញលេញ។

ក្រាហ្វិក ៦.២.៩.៤.ក. ការគ្រប់គ្រងសិស្ស




**ខ. ការងារគ្រប់គ្រងគ្រូបង្រៀន**

- **ការបំពេញការងាររបស់គ្រូបង្រៀន៖** មានចំនួន ១៧% មិនបានគាំទ្រសោះ ២២% បានតិចតួច ៣១% មធ្យម ១៩% បានបង្គួរ និង ១១% បានពេញលេញ
- **គ្រប់គ្រងទិន្នន័យរបស់គ្រូបង្រៀន (លើសឬខ្វះ)៖** មានចំនួន ១៧% មិនបានគាំទ្រសោះ ២៤% បានតិចតួច ៣០% មធ្យម ២៣% បានបង្គួរ និង ៦% បានពេញលេញ
- **ការជួយគ្រូបង្រៀន (កន្លែងស្នាក់នៅ សម្រាប់គ្រូបង្រៀនចេញថ្មី ជួបការលំបាក)៖** មានចំនួន ១៣% មិនបានគាំទ្រសោះ ២៣% បានតិចតួច ៣៥% មធ្យម ២០% បានបង្គួរ និង ៩% បានពេញលេញ។

ក្រាហ្វិក ៦.២.៩.៤.ខ. ការងារគ្រប់គ្រងគ្រូបង្រៀន




**គ. ការងារផែនការ ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់សាលារៀន**

- **ការចូលរួមធ្វើផែនការផ្សេងៗរបស់សាលារៀន៖** មានចំនួន ១៩% មិនបានគាំទ្រសោះ ១៤% បានតិចតួច ៤៣% មធ្យម ១៧% បានបង្គួរ និង ៧% បានពេញលេញ
- **ពិនិត្យតាមដានការប្រើប្រាស់មូលនិធិដំណើរការសាលារៀន៖** មានចំនួន ២៣% មិនបានគាំទ្រសោះ ២៦% បានតិចតួច ២៨% មធ្យម ១៨% បានបង្គួរ និង ៥% បានពេញលេញ
- **ពិនិត្យតាមដានការប្រើប្រាស់ទ្រព្យសម្បត្តិសាលារៀន៖** មានចំនួន ២១% មិនបានគាំទ្រសោះ ១៩% បានតិចតួច ៣១% មធ្យម ២៣% បានបង្គួរ និង ៦% បានពេញលេញ

- **ការធ្វើរបាយការណ៍ជូនអ្នកពាក់ព័ន្ធ៖** មានចំនួន ១៨% មិនបានគាំទ្រសោះ ១៨% បានតិចតួច ៣៥% មធ្យម ២១% បានបង្គួរ និង ៨% បានពេញលេញ
- **ការអនុវត្តការងាររបស់សាលារៀន៖** មានចំនួន ១៧% មិនបានគាំទ្រសោះ ២៧% បានតិចតួច ៣៤%មធ្យម ១៥% បានបង្គួរ និង ៧% បានពេញលេញ ។

ក្រាហ្វិក ៦.២.៩.៤.គ. ការងារផែនការ ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់សាលារៀន




## ៥. ការធ្វើប្រតិភូកម្មការងារអប់រំពីរដ្ឋបាលក្រុង ស្រុក ខណ្ឌទៅឱ្យរដ្ឋបាលឃុំ សង្កាត់ និងកម្រិតនៃការអនុវត្ត

ផ្អែកតាមក្រាហ្វិក **៦.២.៩.៥.** បានបង្ហាញថា អ្នកផ្តល់ព័ត៌មានជាមេឃុំ ចៅសង្កាត់ចំនួន **៧៩នាក់** មានមតិ ៣៦.៧០% បានលើកឡើងថារដ្ឋបាលក្រុង ស្រុក ខណ្ឌ មិនបានធ្វើប្រតិភូកម្មការងារអប់រំទៅឱ្យរដ្ឋបាលឃុំ សង្កាត់ទេ និងមានមតិ ៦៣.៣០% លើកឡើងថា បានធ្វើប្រតិភូកម្មការងារអប់រំពីរដ្ឋបាលក្រុង ស្រុក ខណ្ឌ ទៅឱ្យរដ្ឋបាលឃុំ សង្កាត់ ។




*ក្រាហ្វិក ៦.២.៩.៥.*

## ៦. ការធ្វើប្រតិភូកម្មការងារអប់រំពីរដ្ឋបាលក្រុង ស្រុក ខណ្ឌទៅឱ្យរដ្ឋបាលឃុំ សង្កាត់

ផ្អែកតាមក្រាហ្វិក **៦.២.៩.៦.** បានបង្ហាញថា អ្នកផ្តល់ព័ត៌មានជាមេឃុំ ចៅសង្កាត់ចំនួន **៥២នាក់** បានលើកឡើងថា ការងារអប់រំដែលគួរត្រូវបានធ្វើប្រតិភូកម្មពីរដ្ឋបាលក្រុង ស្រុក ខណ្ឌទៅឱ្យរដ្ឋបាលឃុំ សង្កាត់ រួមមានដូចខាងក្រោម៖

- ការអប់រំកុមារតូច៖ មានចំនួន៧០.៧០%




*ក្រាហ្វិក ៦.២.៩.៦.*

- ការអប់រំបឋមសិក្សា ៖ មានចំនួន៨២.៨០%
- ការងារការអប់រំក្រៅប្រព័ន្ធ ៖ មានចំនួន ៥១.៧០%។

### ៦.២.១០. អ្នកផ្តល់ព័ត៌មានជាប្រធានគណៈកម្មការគ្រប់គ្រងសាលារៀន

#### ១. ការចូលរួមអនុវត្តសកម្មភាពការងារអប់រំនានារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

ផ្អែកតាមក្រាហ្វិក **៦.២.១០.១.** បានបង្ហាញថាអ្នកផ្តល់ព័ត៌មានជាប្រធានគណៈគ្រប់គ្រងសាលារៀនចំនួន **៣២៦នាក់** បានលើកឡើងថារដ្ឋបាលក្រុង ស្រុក ខណ្ឌបានចូលរួមក្នុងការអនុវត្តសកម្មភាពការងារអប់រំដូចជា ការប្រមូលនឹងជំរុញកុមារឱ្យចូលរៀន កម្មវិធីអាហារូបត្ថម្ភ ការអប់រំសុខភាពនិងអនាម័យ ការអប់រំកាយនិងកីឡា និងការផ្តល់ជំនួយដល់កុមារដែលជួបការលំបាក ដូចមានក្នុងលទ្ធផលខាងក្រោម៖

- **ការប្រមូលនឹងជំរុញកុមារឱ្យចូលរៀន៖** មានចំនួន ៤% មិនបានចូលរួម ៦% តិចតួច ១៨% មធ្យម ៤២% បង្គួរ និង ៣០% ចូលរួមច្រើន
- **កម្មវិធីអាហារូបត្ថម្ភ៖** មានចំនួន ១៨% មិនបានចូលរួម ៧% តិចតួច ៣១% មធ្យម ២៤% បង្គួរ និង ២០% ចូលរួមច្រើន
- **ការអប់រំសុខភាព និងអនាម័យ៖** មានចំនួន ៧% មិនបានចូលរួម ១០% តិចតួច ២៥% មធ្យម ៣៦% បង្គួរ និង ២២% ចូលរួមច្រើន
- **ការអប់រំកាយនិងកីឡា៖** មានចំនួន ៤% មិនបានចូលរួម ៨% តិចតួច ៣៦% មធ្យម ៣២% បង្គួរ និង ២០% ចូលរួមច្រើន
- **ជំនួយដល់កុមារដែលជួបការលំបាក៖** មានចំនួន ៤% មិនបានចូលរួម ៧% តិចតួច ៣៦% មធ្យម ៣៣% បង្គួរ និង ២០% ចូលរួមបានច្រើន។

**ក្រាហ្វិក ៦.២.១០.១.**



## ២. ការចូលរួមរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌចំពោះសកម្មភាពការងារអប់រំសំខាន់ៗ

ផ្អែកតាមក្រាហ្វិក **៦.២.១០.២.** បានបង្ហាញថា អ្នកផ្តល់ព័ត៌ជាប្រធានគណៈកម្មការគ្រប់គ្រងសាលារៀនចំនួន **៣២៦នាក់** បានលើកឡើងថារដ្ឋបាលក្រុង ស្រុក ខណ្ឌ បានចូលរួមក្នុងសកម្មភាពការងារអប់រំសំខាន់ៗ ដូចជា ការរៀបចំផែនការ កៀរគរធនធាន និង ការត្រួតពិនិត្យវាយតម្លៃ រួមមានដូចខាងក្រោម៖

- **ការរៀបចំផែនការ៖** មានចំនួន ៤% មិនបានចូលរួម ៨% មិនសូវសកម្ម ៣១% មធ្យម ៣៨% សកម្មបង្គួរ និង ១៩% សកម្មខ្លាំង
- **កៀរគរធនធាន៖** មានចំនួន ៦% មិនបានចូលរួម ៨% មិនសូវសកម្ម ៣៧% មធ្យម ៣០% សកម្មបង្គួរ និង ១៩% សកម្មខ្លាំង
- **ការត្រួតពិនិត្យនិងវាយតម្លៃ៖** មានចំនួន ៥% មិនបានចូលរួម ៨% មិនសូវសកម្ម ៣៣% មធ្យម ៣៧% សកម្មបង្គួរ និង ១៧% សកម្មខ្លាំង។




## ៣. គុណភាពនៃសេវាការអប់រំ (ការអប់រំកុមារតូច បឋមសិក្សា និងអប់រំក្រៅប្រព័ន្ធ) សំដៅលើការអភិវឌ្ឍប្រព័ន្ធអប់រំ ការដឹកនាំ ការគ្រប់គ្រង និងយន្តការត្រួតពិនិត្យនិងវាយតម្លៃក្នុងស្ថានភាពមុនផ្ទេរ

ផ្អែកតាមក្រាហ្វិក **៦.២.១០.៣.** បានបង្ហាញថា អ្នកផ្តល់ព័ត៌មានជាប្រធានគណៈកម្មការគ្រប់គ្រងសាលារៀនចំនួន **៣៥១នាក់** បានលើកឡើងអំពីការផ្តល់សេវា និងគុណភាពនៃសេវាអប់រំចំពោះរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងស្ថានភាពមុនផ្ទេរ រួមមានដូចខាងក្រោម៖

- **ការផ្តល់សេវាអប់រំ ទាំង៣អនុវិស័យ (ការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងអប់រំក្រៅប្រព័ន្ធ)៖** មានចំនួន ១% មិនពេញចិត្ត ៥% ពេញចិត្តតិចតួច ២៣% មធ្យម ៤៨% ពេញចិត្ត និង ២៣% ពេញចិត្តខ្លាំង
- **គុណភាពនៃសេវាអប់រំទាំងបីអនុវិស័យ (ការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងអប់រំក្រៅប្រព័ន្ធ)៖** មានចំនួន ៤% មិនពេញចិត្ត ៤% ពេញចិត្តតិចតួច ២៥% មធ្យម ៥១% ពេញចិត្ត និង ១៦% ពេញចិត្តខ្លាំង។




## ៤. សកម្មភាពការងារដែលបានចូលរួមចំណែកធ្វើឱ្យប្រសើរឡើងដល់គុណភាពសេវាអប់រំ

ផ្អែកតាមក្រាហ្វិក **៦.២.១០.៤.** បានបង្ហាញថា អ្នកផ្តល់ព័ត៌ជាប្រធានគណៈកម្មការគ្រប់គ្រងសាលារៀនចំនួន **៣២៦នាក់** បានលើកឡើងថាសកម្មភាពការងារដែលបានចូលរួមចំណែកធ្វើឱ្យប្រសើរឡើងដល់គុណភាពសេវាអប់រំ រួមមានដូចខាងក្រោម៖

- សកម្មភាពជំរុញសិស្សឱ្យចូលរៀន មានចំនួន ៧៨.៨០%
- កៀរគរ និងចូលរួមធនធានសម្រាប់អភិវឌ្ឍសាលារៀន និងសេវាអប់រំ មានចំនួន ៧៩.១០%
- តាមដានការបង្រៀនរបស់គ្រូបង្រៀននៅតាមសាលារៀន មានចំនួន ៦៣.៩០%។

*ក្រាហ្វិក ៦.២.១០.៤.*




## ៧. សេចក្តីសន្និដ្ឋាននៃរបកគំហើញ

ផ្អែកតាមរបកគំហើញពីការសិក្សាទិន្នន័យដើមគ្រាលើគុណភាពមុខងារវិស័យអប់រំទាំងបីអនុវិស័យមុនផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្រុមការងារបច្ចេកទេសអន្តរក្រសួងអាចសន្និដ្ឋានជារួមបានថា ស្ថានភាពមុនផ្ទេរ និងបច្ចុប្បន្នក្នុងការអនុវត្តមុខងារវិស័យអប់រំទាំងបីអនុវិស័យនៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារការអប់រំទាំងនោះពុំសូវមានបញ្ហាណាមួយគួរឱ្យកត់សម្គាល់ឡើយ។ ទន្ទឹមនឹងនេះ ស្ថានភាពនៃការគ្រប់គ្រងនៅតាមសាលារៀន ជាពិសេសសាលារៀនដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗក្នុងរាជធានី ខេត្តគោលដៅទាំង៦ ក្នុងនោះរួមមាន៖ រាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ មណ្ឌលគិរី ស្វាយរៀង កំពត និងសៀមរាប ដែលបានធ្វើការស្ទង់មតិ និងពិភាក្សាផ្តោតការយកចិត្តទុកដាក់ខ្ពស់ក្នុងការគ្រប់គ្រង ការចាត់ចែង ការតាមដាន

ត្រួតពិនិត្យ និងការដោះស្រាយបញ្ហាប្រឈមនានាក្នុងការអនុវត្តមុខងារអប់រំទាំងបីអនុវិស័យបានយ៉ាងឆាប់រហ័ស និងទាន់ពេលវេលាព្រមទាំងបានកៀរគរការគាំទ្រ និងបានជំរុញឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធរួមទាំងរដ្ឋបាលឃុំ សង្កាត់ សហគមន៍មូលដ្ឋាន និងសប្បុរសជននានាក្នុងការផ្តល់សេវាអប់រំដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានកាន់តែសកម្ម និងកាន់តែផុសផុលថែមទៀត។

ផ្អែកតាមផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-២០២៣ ក៏បានជំរុញឱ្យមានកំណែទម្រង់សំខាន់ៗក្នុងវិស័យអប់រំរបស់កម្ពុជា ជាពិសេសអនុវិស័យអប់រំទាំងបី គឺការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ ផែនការទាំងនេះបានជួយសម្រួលដល់សមិទ្ធផលគួរឱ្យកត់សម្គាល់ ដូចជាការបង្កើនការចុះឈ្មោះចូលរៀននៅគ្រប់កម្រិតនៃការអប់រំ ធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានសម្រាប់កុមារដែលជួបការលំបាក ការពង្រឹងអភិបាលកិច្ចនៅក្នុងស្ថាប័នអប់រំ និងការពង្រីកកម្មវិធីអាហារូបករណ៍សម្រាប់សិស្សក្រីក្រ។ ក្រសួងអប់រំ យុវជន និងកីឡាបានផ្តោតលើការលើកកម្ពស់គុណភាព និងការឆ្លើយតបនៃការអប់រំផ្អែកតាមលទ្ធផលនៃការសិក្សាទិន្នន័យដើមគ្រាលើគុណភាពអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

តាមរយៈការផ្ទេរមុខងារក្នុងវិស័យអប់រំនេះ នឹងផ្តល់ការទទួលខុសត្រូវ និងភាពម្ចាស់ការដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារក្នុងវិស័យអប់រំដែលបានផ្ទេរទៅនោះឱ្យកាន់តែមានប្រសិទ្ធភាព ប្រសិទ្ធផល និងចូលរួមចំណែកសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់មូលធនមនុស្សនៅព្រះរាជាណាចក្រកម្ពុជា។

### ៧.១. ការអប់រំកុមារតូច

អនុវិស័យការអប់រំកុមារតូចនៅកម្ពុជា សម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្នុងការពង្រីកលទ្ធភាពទទួលបាន និងលើកកម្ពស់គុណភាពនៃការរៀនសូត្រដំបូង។ សមិទ្ធផលសំខាន់ៗរួមមាន ការកើនឡើងនៃគ្រឹះស្ថានអប់រំកុមារភាព ការធ្វើឱ្យប្រសើរឡើងនូវអត្រាចុះឈ្មោះចូលរៀន កម្មវិធីសិក្សាថ្មីៗ និងកម្មវិធីបណ្តុះបណ្តាលគ្រូឱ្យប្រសើរឡើង។ ក្នុងនោះដែរ កម្មវិធីគាំទ្រ និងភាពជាដៃគូក៏បានរួមចំណែកដល់លទ្ធផលវិជ្ជមានទាំងនេះផងដែរ។

ផ្អែកលើសូចនាករស្នូលនៃអនុវិស័យការអប់រំកុមារតូច (EMIS 2022-2023) ឃើញថាមានការកើនឡើងគួរឱ្យកត់សម្គាល់នៃចំនួនសាលាមត្តេយ្យសិក្សាគ្រប់រូបភាព។ ការកើនឡើងនេះមានគោលបំណងផ្តល់លទ្ធភាពកាន់តែទូលំទូលាយសម្រាប់ឱកាសសិក្សាដំបូងសម្រាប់កុមារនៅទូទាំងប្រទេសកម្ពុជា។ កិច្ចខិតខំប្រឹងប្រែងនេះ ត្រូវបានធ្វើឡើងដើម្បីបង្កើនលទ្ធភាពទទួលបានការអប់រំកុមារតូចដែលបានបង្កើនលទ្ធផលអត្រាចុះឈ្មោះចូលរៀន។

កម្រិតនៃការយល់ដឹងរបស់ក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក ខណ្ឌ លើគោលនយោបាយផែនការយុទ្ធសាស្ត្រគ្រប់គ្រងកុមារតូចនៅមានកម្រិតនៅឡើយជាក់ស្តែង ៣៣% យល់ដឹងតិចតួច និង ៤៥% យល់ដឹងមធ្យមលើគោលនយោបាយ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ យល់ដឹងអំពីគោលនយោបាយកំណែទម្រង់សាលារៀនរបស់ក្រសួងអប់រំ យុវជន និងកីឡា សាលារៀនមត្តេយ្យសិក្សា និងយល់ដឹងតិចតួច ២៥%

អំពីស្ថានភាពកិច្ចការនានារបស់សាលារៀនមត្តេយ្យសិក្សា។ រដ្ឋបាលក្រុង ស្រុក ខណ្ឌបានផ្តោតការយកចិត្តទុកដាក់ខ្ពស់ក្នុងការអភិវឌ្ឍលើវិស័យអប់រំក្នុងមូលដ្ឋានរបស់ខ្លួន ជាពិសេសផ្តោតលើអនុវិស័យទាំងបី ការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ។ ជាក់ស្តែងមាន ៧៩.៤% រដ្ឋបាលក្រុង ស្រុក ខណ្ឌបានដាក់បញ្ចូលផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រចាំឆ្នាំស្តីពីការអប់រំកុមារតូចចូលក្នុងផែនការអភិវឌ្ឍន៍០៥ឆ្នាំ ឬកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌនៅក្នុងឆ្នាំ២០២៣។

**ការដឹកនាំ ចាត់ចែង គ្រប់គ្រង និងការគាំទ្ររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌចំពោះមុខងារការអប់រំកុមារតូច៖** ផ្អែកលើការស្ទង់មតិ ភាគច្រើនយល់ឃើញថារដ្ឋបាលក្រុង ស្រុក ខណ្ឌបានគាំទ្រ ៧៧-៨៧% លើកិច្ចការមួយចំនួនដូចជា ការរៀបចំផែនការសាលារៀន ការពិនិត្យតាមដាននិងវាយតម្លៃ ការគ្រប់គ្រងគ្រូមត្តេយ្យសិក្សា ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ និង ៩០% បានគាំទ្រលើការងារសន្តិសុខសណ្តាប់ធ្នាប់ និងអនាម័យបរិស្ថាន និង ៥៥% បានចូលរួមកៀរគរធនធានសម្រាប់អភិវឌ្ឍសាលារៀន។

**ការយល់ឃើញអំពីកម្រិតពេញចិត្តលើគុណភាពសេវាមុខងាររងអនុវិស័យការអប់រំកុមារតូចរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ** ភាគច្រើនបានសាទរចំពោះការផ្តល់សេវា និងគុណភាពសេវាអប់រំសម្រាប់មុខងារអនុវិស័យការអប់រំកុមារតូច ប៉ុន្តែមានមតិមួយចំនួនបានលើកឡើងថា នៅមានកម្រិតនៅឡើយ ដែលចំនួន ៥២% មានការពេញចិត្តមធ្យម ៧% មិនពេញចិត្តសោះ ២៤% ពេញចិត្តតិចតួច និង ១៧% ពេញចិត្តខ្លាំង។

**យន្តការគាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ** សំដៅទៅលើការរៀបចំយន្តការគាំទ្ររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងនោះមានក្រុមប្រឹក្សា និងគណៈអភិបាលដើម្បីផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តកិច្ចការក្នុងវិស័យអប់រំ រួមទាំងការដោះស្រាយបញ្ហានានានៅតាមសាលារៀន។ ជាក់ស្តែង ក្រុមប្រឹក្សា និងគណៈអភិបាលបានប្រើប្រាស់យន្តការត្រួតពិនិត្យវាយតម្លៃរបស់ខ្លួន ៩២.៦% គឺតាមរយៈការចុះតាមដានត្រួតពិនិត្យ ៨៨.៩% តាមរយៈកិច្ចប្រជុំរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ៨២.៥% តាមរយៈរបាយការណ៍ និង ៥៥.៦% បានលើកឡើងថាតាមរយៈយន្តការត្រួតពិនិត្យផ្ទៃក្នុង។

ទន្ទឹមនឹងការសម្រេចបាន ក៏នៅមានបញ្ហាប្រឈមមួយចំនួនដែលទាមទារឱ្យមានការខិតខំប្រឹងប្រែងបន្តការដោះស្រាយថែមទៀត ជាពិសេសទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធ ឧបសគ្គធនធាន និងការធានាឱ្យមានលទ្ធភាពទទួលបានដោយសមធម៌សម្រាប់កុមារទាំងអស់។ ការដោះស្រាយបញ្ហាប្រឈមទាំងនេះតម្រូវទាមទារការខិតខំប្រឹងប្រែងបន្ត និងវិនិយោគក្នុងការងារការអប់រំកុមារតូច ដោយផ្តោតលើការពង្រឹងសម្ភារបរិក្ខារ ការផ្តល់ធនធានគ្រប់គ្រាន់ និងផ្តល់ការបណ្តុះបណ្តាលគ្រូឱ្យបានទូលំទូលាយ។ បញ្ហាប្រឈមជាក់លាក់រួមមានដូចខាងក្រោម៖

- ការចុះឈ្មោះចូលរៀនរបស់កុមារអាយុពី ៣ទៅ ៥ឆ្នាំ ក្នុងគ្រប់ប្រភេទនៃការអប់រំនៅមានកម្រិតនៅឡើយ
- ការពង្រីកហេដ្ឋារចនាសម្ព័ន្ធកម្មវិធីការអប់រំកុមារតូចមិនបានបំពេញតម្រូវការ

- ការអនុវត្តកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សា និងសៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សាមិនទាន់ពេញលេញ
- ការថែទាំកុមារតូច និងការអភិវឌ្ឍក្នុងរយៈពេល ១,០០០ថ្ងៃដំបូង មិនត្រូវបានគេយកចិត្តទុកដាក់
- សមត្ថភាពបុគ្គលិកការអប់រំកុមារតូចមិនទាន់ឆ្លើយតបទៅនឹងក្របខ័ណ្ឌគុណវុឌ្ឍិ។

**ចំពោះបញ្ហាប្រឈមរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការអនុវត្តអនុវិស័យការអប់រំកុមារតូច៖** ត្រូវបានមើលឃើញថាជួបបញ្ហាចម្បងៗគឺ ៣៧% បញ្ហាគាំទ្របច្ចេកទេស ២១% បញ្ហាធនធាន ២៥% យន្តការត្រួតពិនិត្យតាមដាន ២៥% ការបែងចែកតួនាទី និងការទទួលខុសត្រូវ និង ២៦% ការងាររដ្ឋបាល និងខ្សែគណនេយ្យភាព។

៧.២. ការអប់រំបឋមសិក្សា

អនុវិស័យការអប់រំបឋមសិក្សានៅកម្ពុជា បានបោះជំហានទៅមុខយ៉ាងសំខាន់ក្នុងប៉ុន្មានឆ្នាំមកនេះ ជាមួយនឹងសមិទ្ធផលគួរឱ្យកត់សម្គាល់ក្នុងការបង្កើនចំនួនសាលារៀន ការអនុវត្តការគ្រប់គ្រងតាមសាលា និងការលើកកម្ពស់កម្មវិធីគាំទ្រសិស្ស។ ការណែនាំអំពីការអប់រំពហុភាសា និងកម្មវិធីសាលាកុមារមេត្រីក៏បានរួមចំណែកដល់បរិយាកាសសិក្សាដែលរួមបញ្ចូល និងគាំទ្របន្ថែមទៀត។

ជាក់ស្តែងចំនួនសាលាបឋមសិក្សាទាំងរដ្ឋ និងឯកជនបានកើនឡើងពី ៧,២៣៦ ក្នុងឆ្នាំសិក្សា ២០១៣-២០១៤ ដល់ ៨,០៦៧ ក្នុងឆ្នាំសិក្សា ២០២២-២០២៣។ ចំណែកសាលាបឋមសិក្សាឯកជនមានការកើនឡើងគួរឱ្យកត់សម្គាល់រហូតដល់ ២០០% ក្នុងរយៈពេល ១០ឆ្នាំ។ ដោយឡែក ចំពោះការអនុវត្តការគ្រប់គ្រងតាមសាលារៀនមានការកើនឡើងគួរឱ្យកត់សម្គាល់ ជាពិសេសក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩ ជាមួយនឹងវិធានការជាក់ស្តែង ដោយផ្តល់ការសិក្សាតាមរយៈប្រព័ន្ធបញ្ជូនសារ និងរូបភាពពីចម្ងាយ និងការរៀនតាមបណ្តុំសម្រាប់ទីកន្លែងដែលមានហានិភ័យទាបជាដើម។ ចំនួនសាលាបឋមសិក្សាដែលអនុវត្តកម្មវិធីការគ្រប់គ្រងតាមសាលារៀន បានកើនឡើងទ្វេដងក្នុងរយៈពេល ២ឆ្នាំ និងកើនឡើងបីដងនៅឆ្នាំសិក្សា២០២២-២០២៣។ ចំនួនសិស្សដែលបានទទួលអាហារនៅតាមសាលារៀន បានកើនឡើងក្រោមការគាំទ្ររបស់រាជរដ្ឋាភិបាល និងកម្មវិធីស្បៀងអាហារពិភពលោក។ កម្មវិធីនេះ មានគោលបំណងកែលម្អអាហារូបត្ថម្ភ និងលក្ខខណ្ឌសិក្សា ជាពិសេសសម្រាប់សិស្សដែលជួបការលំបាក។

ចំនួនសិស្សអាហារូបករណ៍ក៏បានកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ ពី ៦៨,២៣៤ ក្នុងឆ្នាំសិក្សា ២០១៤-២០១៥ ដល់ ១៤៨,៩០១ ក្នុងឆ្នាំសិក្សា២០២២-២០២៣ ដែលលើសពីគោលដៅចុងក្រោយ និងបង្ហាញពីការខិតខំប្រឹងប្រែងយ៉ាងខ្លាំងឆ្ពោះទៅរកការលើកកម្ពស់សមធម៌នៃការអប់រំបឋមសិក្សា (EMIS 2022-2023)។

ទន្ទឹមនឹងមានការរីកចម្រើនដូចរៀបរាប់ខាងលើ ក៏មានបញ្ហាប្រឈមមួយចំនួនដូចជា អត្រាបោះបង់ការសិក្សា អត្រាត្រួតថ្នាក់ អត្រាបញ្ចប់ការសិក្សាមានការប្រែប្រួល មិនទាន់សម្រេចបានចំណុចដៅដែលបានគ្រោងទុក និងទាមទារឱ្យមានការខិតខំបន្ថែមទៀត ដើម្បីរកដំណោះស្រាយជាបន្ទាន់។ ក្រសួងអប់រំ យុវជន និងកីឡាបាននឹងបន្តកិច្ចខិតខំប្រឹងប្រែង ជាមួយផែនការយុទ្ធសាស្ត្រ និងគោលដៅ គឺចាំបាច់ដើម្បី

ដោះស្រាយបញ្ហាប្រឈមទាំងនេះ និងបន្តលើកកម្ពស់វឌ្ឍនភាពដែលបានធ្វើឡើងដើម្បីធានាថាកុមារទាំងអស់នៅក្នុងប្រទេសកម្ពុជាមានលទ្ធភាពទទួលបានការអប់រំបឋមសិក្សាប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន។

ផ្អែកតាមទិន្នន័យ (EMIS 2022-2023) បានបង្ហាញពីវឌ្ឍនភាពគួរឱ្យកត់សម្គាល់សម្រាប់ស្ថិតិ និងសូចនាករស្នូលក្នុងការអនុវត្តមុខងារការអប់រំបឋមសិក្សា។ ទន្ទឹមនឹងការសម្រេចបានក៏មានបញ្ហាប្រឈមមួយចំនួនដែលទាមទារឱ្យមានការខិតខំប្រឹងប្រែងក្នុងការដោះស្រាយបន្ត។ បញ្ហាប្រឈមជាក់លាក់ទាំងនោះរួមមាន:

- កង្វះខាតគ្រូបង្រៀនដែលមានគុណវុឌ្ឍិ ប្រហែលមួយភាគបីនៃចំនួនគ្រូបង្រៀនសរុប
- ការអនុវត្តកញ្ចប់សម្ភារអំណាន និងគណិតវិទ្យាថ្នាក់ដំបូង និងកម្មវិធីប្រឹក្សាគរុកោសល្យទើបបានប្រហែល ២៨% នៃថ្នាក់ទី១ ទី២ និងថ្នាក់ទី៣ ទូទាំងប្រទេសតែប៉ុណ្ណោះ
- សមត្ថភាពគ្រូបង្រៀននៅមានកម្រិតលើវិធីសាស្ត្របង្រៀនភាសាខ្មែរ គណិតវិទ្យា STEM Education
- ការបង្រៀន និងរៀនភាសាបរទេស ICT ពីថ្នាក់ទី៤ ដល់ទី៦ នៅមានកម្រិតនៅឡើយ
- ការបង្រៀន និងរៀនតែមួយពេល និងចំនួនម៉ោងបង្រៀនមិនទាន់បានតាមស្តង់ដាតំបន់ និងអន្តរជាតិ
- ការអនុវត្តការគ្រប់គ្រងសាលារៀននៅតែស្ថិតក្នុងកម្រិតតូចនៅឡើយ ប្រហែល ២២% នៃសាលាបឋមសិក្សាទូទាំងប្រទេស
- ខ្វះខាតអគារសិក្សា និងបន្ទប់សម្រាប់រៀបចំបណ្ណាល័យ មន្ទីរពិសោធន៍ ទីចាត់ការ និងបន្ទប់កុំព្យូទ័រជាដើម
- កង្វះហេដ្ឋារចនាសម្ព័ន្ធសុខភាពនៅតាមសាលារៀន និងការយល់ដឹងអំពីសុខភាព និងអនាម័យនៅមានកម្រិត
- កង្វះហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយសម្រាប់ការសិក្សាពីចម្ងាយ និងការអប់រំតាមប្រព័ន្ធឌីជីថល
- ការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន និងកម្មវិធីអាហារូបករណ៍មានទាន់គ្របដណ្តប់ទូទាំងប្រទេសនៅឡើយ។

### ៧.៣. ការអប់រំក្រៅប្រព័ន្ធ

ផ្អែកតាមស្ថិតិ និងសូចនាករអប់រំក្រៅប្រព័ន្ធ (ឆ្នាំ២០២៣) អនុវិស័យការអប់រំក្រៅប្រព័ន្ធក្នុងប្រទេសកម្ពុជា បានមើលឃើញថាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងការពង្រីក និងលើកកម្ពស់ឱកាសសិក្សាសម្រាប់កុមារ យុវជន និងមនុស្សពេញវ័យដែលនៅក្រៅសាលា។ សមិទ្ធផលសំខាន់ៗរួមមាន ការអភិវឌ្ឍ និងការអនុវត្តកម្មវិធីអក្ខរកម្មវិជ្ជាជីវៈ កម្មវិធីក្រោយអក្ខរកម្ម កម្មវិធីចូលរៀនឡើងវិញ កម្មវិធីសមមូល កម្មវិធីបំពេញវិជ្ជា កម្មវិធីបង្កើនប្រាក់ចំណូល ការកសាងសមត្ថភាពសំខាន់ៗសម្រាប់អ្នកអប់រំ និងការប្រែក្លាយមជ្ឈមណ្ឌលសិក្សាសហគមន៍ទៅជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត។ ជាក់ស្តែង នៅក្នុងអនុវិស័យការអប់រំក្រៅប្រព័ន្ធក្នុងឆ្នាំសិក្សា២០២២-២០២៣ មានរាជធានី ខេត្តចំនួន២៥ បានអនុវត្តកម្មវិធីចំនួន០៣

រួមមានអក្ខរកម្មវិជ្ជាជីវៈ បង្កើនប្រាក់ចំណូល និងសមមូលបឋមសិក្សា ១៩រាជធានី ខេត្តបានអនុវត្តកម្មវិធីបំពេញវិជ្ជា ១៥រាជធានី ខេត្តបានអនុវត្តកម្មវិធីក្រោយអក្ខរកម្ម ១១រាជធានី ខេត្តបានអនុវត្តកម្មវិធីចូលរៀនឡើងវិញ និងកម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិ មានតែ ០៦ខេត្តប៉ុណ្ណោះដែលបានអនុវត្ត។ អត្រាអក្ខរកម្មសម្រាប់មនុស្សពេញវ័យ (អាយុចាប់ពី ១៥ឆ្នាំឡើងទៅ) មានភាពប្រសើរឡើង គាំទ្រដោយមានការយកចិត្តទុកដាក់ពីអ្នកសិក្សា ស្ថាប័នពាក់ព័ន្ធដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ជាមួយនឹងការបង្កើតមជ្ឈមណ្ឌលសិក្សាសហគមន៍ និងមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត។ ចំនួននៃមជ្ឈមណ្ឌលទាំងនេះ បានកើនឡើងយ៉ាងខ្លាំងដោយសារតែកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍។ ដោយឡែក ចំពោះកម្មវិធីសមមូលក៏ឃើញមានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ ដូចជា ក្នុងការចុះឈ្មោះដោយផ្តល់ឱកាសសម្រាប់ការអប់រំបន្ថែម និងការទទួលបានជំនាញវិជ្ជាជីវៈនានា។ នេះរួមបញ្ចូលទាំងគំនិតផ្តួចផ្តើមដូចជាការរៀនពីចម្ងាយ និងការបង្រៀនតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់យុវជននៅក្រៅសាលាផងដែរ។

ចំនួនសិស្សនៅក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធមានការប្រែប្រួល ដោយមានសិស្សចំនួន **៧០,៧៤១នាក់** ក្នុងឆ្នាំសិក្សា២០១២-២០១៣ និង **៤៧,១៧៣នាក់** ក្នុងឆ្នាំសិក្សា២០២២-២០២៣។ អត្រាបញ្ចប់ការសិក្សាក៏មានការប្រែប្រួលផងដែរ ដោយសិស្សចំនួន **៥៥,៨០៨នាក់** បានបញ្ចប់កម្មវិធីក្នុងឆ្នាំ២០១២-២០១៣ និង **៤៤,៣៧៣នាក់** ក្នុងឆ្នាំ២០២២-២០២៣។ ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) បានពង្រឹងសមត្ថភាពស្ថាប័ន តាមរយៈវិធានការផ្សេងៗ រួមទាំងការបង្កើនប្រាក់កម្រៃសម្រាប់គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ និងផ្តល់ការលើកទឹកចិត្តសម្រាប់ការអនុវត្តឆ្នើម។ កិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើងដើម្បីធ្វើបច្ចុប្បន្នភាព និងកែលម្អកម្មវិធីសិក្សា សៀវភៅសិក្សា និងលិខិតបទដ្ឋានគតិយុត្ត។

ផ្អែកតាមរបកគំហើញពីការសិក្សាទិន្នន័យដើមគ្រាលើគុណភាពវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្រុមការងារសិក្សាវាយតម្លៃទិន្នន័យដើមគ្រាអាចសន្និដ្ឋានជារួមបានថា ស្ថានភាពគ្រប់គ្រង ចាត់ចែងកិច្ចការទូទៅមុនផ្ទេរមុខងារអប់រំទាំងបីអនុវិស័យទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌពុំមានបញ្ហាមិនប្រក្រតីណាមួយធ្ងន់ធ្ងរគួរឱ្យកត់សម្គាល់ឡើយ។ ផ្ទុយមកវិញ ស្ថានភាពនៃការគ្រប់គ្រងទូទៅនៅតាមសាលារៀននីមួយៗ ជាពិសេសសាលារៀនដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌគោលដៅទាំង៣១ ដែលបានស្ទង់មតិ មានស្ថានភាពល្អប្រសើរឡើង ដោយសារថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុកមានឆន្ទៈ និងការទទួលខុសត្រូវប្រកបដោយភាពម្ចាស់ការ និងបានផ្តោតការយកចិត្តទុកដាក់ខ្ពស់ក្នុងការគ្រប់គ្រង ការចាត់ចែង ការតាមដានត្រួតពិនិត្យ និងការដោះស្រាយបញ្ហាប្រឈមនានាក្នុងការអនុវត្តមុខងារអប់រំទាំងបីអនុវិស័យនោះបានយ៉ាងឆាប់រហ័ស និងទាន់ពេលវេលា ព្រមទាំងបានកៀរគរការគាំទ្រ និងការជំរុញឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធ រួមទាំងរដ្ឋបាលឃុំ សង្កាត់ សហគមន៍មូលដ្ឋាន និងសប្បុរសជននានាក្នុងការផ្តល់សេវាអប់រំដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានកាន់តែសកម្ម និងផុលផុសទៀតផង។

ចំពោះទំនាក់ទំនងការងារនានារវាងមន្ទីរអប់រំ យុវជន និងកីឡាជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌក្រោយសមាហរណកម្ម ក្រុមសិក្សាវាយតម្លៃមើលឃើញថាមានកិច្ចសហការល្អគួរឱ្យកត់សម្គាល់ ជាពិសេសការងាររបាយការណ៍ ដោយឡែកចំពោះការងារពិនិត្យនីត្យានុកូលភាព ការធ្វើសេចក្តីសម្រេចនានា ការងារ

គាំទ្របច្ចេកទេស ការអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនៅមានកម្រិតនៅឡើយដាក់ស្តែង ៦០% កម្រិតបង្គួរ និង ៤០% មានកម្រិតមធ្យម។

ទោះជាយ៉ាងនេះក្តី កម្រិតនៃការគ្រប់គ្រង ការចាត់ចែង និងយល់ដឹងពីកិច្ចការមួយចំនួនក្នុងវិស័យអប់រំដែលបានក្រោយសមាហរណកម្មទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌក៏បានជួបបញ្ហាប្រឈមជាគន្លឹះមួយចំនួនពាក់ព័ន្ធនឹងកម្រិតនៃសិទ្ធិអំណាច កិច្ចការរដ្ឋបាល និងការគ្រប់គ្រងធនធាន រួមមានទាំងធនធានហិរញ្ញវត្ថុ និងធនធានមនុស្សដែលទាមទារឱ្យមានការពិនិត្យ និងកែសម្រួលរួមជាមួយនឹងការពង្រឹងយន្តការគាំទ្រ ការអភិវឌ្ឍសមត្ថភាព ការតាមដានត្រួតពិនិត្យដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការដោះស្រាយបញ្ហាប្រឈមនានាឱ្យបានឆាប់រហ័សទាន់ពេលវេលា ដើម្បីធានាឱ្យការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌអាចអនុវត្តបានដោយរលូនប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ជាពិសេសធានាបាននូវគុណភាពអប់រំល្អប្រសើរជាលំដាប់។

**ការធ្វើវិមជ្ឈការមុខងារអប់រំ៖** សម្រាប់ធានាដល់ការលើកកម្ពស់គុណភាពសេវាអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ នោះគឺការបង្វិតសេវាឱ្យទៅកៀកជិតប្រជាពលរដ្ឋដែលអនុញ្ញាតឱ្យមានការគ្រប់គ្រង ចាត់ចែងនៅតាមមូលដ្ឋាន និងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។ ទោះជាយ៉ាងណាក៏ដោយ អ្នកសិក្សាវាយតម្លៃបានមើលឃើញថា នៅមានភាពខ្វះខាតមួយចំនួនក្នុងការអនុវត្ត និងសមត្ថភាពយល់ដឹងអំពីមុខងារអប់រំទាំងបីអនុវិស័យនៅទូទាំងក្រុង ស្រុក ខណ្ឌ។

**ការបែងចែកធនធាន៖** ការបែងចែកធនធានប្រកបដោយប្រសិទ្ធភាពនៅតែជាបញ្ហាប្រឈម ជាពិសេសក្នុងការធានាថាគ្រប់ក្រុង ស្រុក ខណ្ឌទាំងអស់មានថវិកា និងបុគ្គលិកទទួលបានការបណ្តុះបណ្តាលគ្រប់គ្រាន់ (ទាំងផ្នែករដ្ឋបាល ប្រតិបត្តិការទូទៅ និងចំណេះដឹង) ដើម្បីគ្រប់គ្រងចាត់ចែងមុខងារដែលបានផ្ទេរប្រកបដោយប្រសិទ្ធភាព។

**ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព៖** ការបណ្តុះបណ្តាលជាបន្តបន្ទាប់ និងការកសាងសមត្ថភាពសម្រាប់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ បុគ្គលិកអប់រំ និងអ្នកពាក់ព័ន្ធផ្សេងទៀត គឺមានសារៈសំខាន់ណាស់។ ក្រុង ស្រុក ខណ្ឌជាច្រើនបានទាមទារឱ្យមានការគាំទ្របន្ថែមទៀតពីរដ្ឋបាលរាជធានី ខេត្ត ក្រសួងវិស័យពាក់ព័ន្ធ ដើម្បីដោះស្រាយការបង្កើនទំនួលខុសត្រូវ ជាពិសេសក្នុងការអនុវត្តមុខងារអប់រំក្រៅប្រព័ន្ធ។

**ការចូលរួមពីសហគមន៍៖** ការបង្កើនការចូលរួមរបស់សហគមន៍ គឺចាំបាច់ដើម្បីធានាថាប្រព័ន្ធអប់រំតាមបែបវិមជ្ឈការបានបំពេញតាមតម្រូវការក្នុងក្រុង ស្រុក ខណ្ឌ។ ដើម្បីអនុវត្តកិច្ចការនេះបានតម្រូវឱ្យមានការចូលរួមពីសំណាក់អាណាព្យាបាល គណៈកម្មការទ្រទ្រង់សាលារៀន និងអ្នកពាក់ព័ន្ធសំខាន់ៗផ្សេងទៀតនៅតាមមូលដ្ឋានក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនានា។

**ការលើកកម្ពស់គណនេយ្យភាពរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌចំពោះប្រជាពលរដ្ឋក្នុងការអនុវត្តការងារអប់រំ៖** រាល់កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌតែងតែលើកយកបញ្ហាអប់រំមកពិនិត្យ ពិភាក្សា និងដោះស្រាយជាប្រចាំ។ ថ្នាក់ដឹកនាំរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗបានយកចិត្តទុកដាក់ផ្តល់ការអន្តរាគមន៍ គាំទ្រ និងដោះស្រាយបញ្ហាប្រឈមនានានៅតាមសាលារៀន។ ក្នុងវេទិកាសាធារណៈនានា ថ្នាក់ដឹកនាំនៃរដ្ឋបាលក្រុង ស្រុកតែងតែបានចូលរួមផ្សព្វផ្សាយ ពិគ្រោះយោបល់ និងប្រមូលសំណើសំណូមពររបស់ប្រជាពលរដ្ឋ និងសហគមន៍អំពីបញ្ហាពាក់ព័ន្ធនឹងសេវាអប់រំ។ រដ្ឋបាលក្រុង ស្រុកបានសម្របសម្រួល និងជំរុញការចូលរួមពីរដ្ឋបាលឃុំ សង្កាត់ សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធក្នុងសកម្មភាពអប់រំ ព្រមទាំងបានសម្របសម្រួល និងកៀរគរធនធានពីសប្បុរសជន អង្គការសង្គមស៊ីវិល មាតាបិតាសិស្សដើម្បីអភិវឌ្ឍសាលារៀនដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនជាប្រចាំ។

ជារួម ក្នុងខណៈពេលដែលការផ្ទេរមុខងារអប់រំទាំងបីអនុវិស័យទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌបានបង្ហាញការសន្យាក្នុងការលើកកម្ពស់គុណភាពសេវាអប់រំ តាមរយៈការគ្រប់គ្រងនៅមូលដ្ឋាន និងការខិតខំប្រឹងប្រែងប្រកបដោយនិរន្តរភាពក្នុងការកសាងសមត្ថភាពជាបណ្តើរៗ ការបែងចែកធនធាន និងផ្តល់ឱកាសឱ្យមានការចូលរួមពីសហគមន៍ និងវិស័យឯកជន គឺចាំបាច់ណាស់ដើម្បីដោះស្រាយបញ្ហាប្រឈមនានា និងវិសមភាពដែលមានស្រាប់នៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌមួយចំនួន។

យើងអាចធ្វើការសន្និដ្ឋានបានថា ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌមានការយល់ដឹងអំពីគោលនយោបាយ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងកម្មវិធីកំណែទម្រង់សាលារៀនត្រឹមកម្រិតមធ្យមនៅឡើយ ប៉ុន្តែក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌបានយកចិត្តទុកយ៉ាងខ្លាំងក្នុងការអភិវឌ្ឍលើវិស័យអប់រំក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបន្ទាប់ពីការផ្ទេរមុខងារវិស័យអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ទន្ទឹមនឹងនេះ ការយល់ដឹងអំពីស្វ័យភាពរបស់សាលានៅមានកម្រិតទាប ហើយក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌយល់ឃើញថា ការគាំទ្របច្ចេកទេសក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារនៅមានកម្រិតខ្លាំង និងមានបញ្ហាប្រឈមជាច្រើនទៀតផងដែរ។ ដោយឡែក អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌមានការយល់ដឹងអំពីគោលនយោបាយ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងកម្មវិធីកំណែទម្រង់សាលារៀនត្រឹមកម្រិតមធ្យមនៅឡើយ ប៉ុន្តែអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌបានយកចិត្តទុកយ៉ាងខ្លាំងក្នុងការអភិវឌ្ឍលើវិស័យអប់រំក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបន្ទាប់ពីការផ្ទេរមុខងារវិស័យអប់រំមកឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ដោយឡែកសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌបានចូលរួមចំណែកក្នុងការកៀរគរធនធានពីប្រភពនានាដើម្បីគាំទ្រដល់ការអនុវត្តមុខងារនៃអនុវិស័យអប់រំទាំងបី។ ទន្ទឹមនេះ ចំណុចវិជ្ជមានខាងលើនេះ ការយល់ដឹងអំពីស្វ័យភាពរបស់សាលានៅមានកម្រិតទាប ហើយគណៈអភិបាលក្រុង ស្រុក ខណ្ឌយល់ឃើញថា ការគាំទ្របច្ចេកទេសក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារអនុវិស័យអប់រំទាំងបីនៅមានកម្រិត និងមានបញ្ហាប្រឈមជាច្រើនទៀតផងដែរ ដែលទាមទាឱ្យមានការតម្រង់ទិសផ្នែកបច្ចេកទេស ពង្រឹងសមត្ថភាពបន្ថែមទៀតដល់មន្ត្រីការិយាល័យអប់រំ យុវជន និងកីឡា និងមន្ត្រីពាក់ព័ន្ធចំណុះរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

## ឯកសារយោង

១. លិខិតបទដ្ឋានគតិយុត្ត
២. ឯកសារផ្សេងៗ

## តារាងឧបសម្ព័ន្ធ

| ល.រ | ឈ្មោះឯកសារ |
|---|---|
| ឧបសម្ព័ន្ធទី១៖ បញ្ជីអ្នកចូលរួមសម្ភាសន៍ កម្មវិធីសម្ភាសន៍ និងកម្រងបញ្ជីសំណួរ | |
| ១ | តារាងទីតាំងគោលដៅ និងក្រុមគោលដៅ |
| ២ | តារាងកាលវិភាគសម្ភាសន៍ |
| ៣ | កម្រងបញ្ជីសំណួរ |